# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE


ឆ្នាំទី ៣៤ លេខ ៩ ខែ កញ្ញា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា*      បញ្ជីរឿង      ទំព័រ

– ធម្មវិចារណកថា ព្រះសាសនមុនី កឹម-ទួរ រៀបរៀង . . . . . . . . . . ៩៦៣
– គោលច្បាប់ព្រះពុទ្ធសាសនា លោក ហេង-សមអាន តែងនិងរៀបរៀង (ត) . . . ៩៧៩
– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) លោកប៊ូ-ប៊ូ ប្រែរៀបរៀង (ត) . . . . . . ៩៨៨
– មធុរសវាហិណី សម្ដេចព្រះធម្មលិខិត ល្វី-ឯម ឧត្ដមប្រឹក្សា ប្រែរៀបរៀង (ត) . . . ៩៩៦
– មហោសថជាតក (ត) . . . . . . . . . . . . . . ១០០៦

*ផ្នែកអក្សរសាស្ត្រ*

– បែបអក្សរខ្មែរ សម័យសិលាចារឹកហាទ់ផ័យ . . . . . . . . . . . ១០១៩
– ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ "ក" (ត) . ១០២៨
– វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង (ត) . . . . . . ១០៣០
– រឿងសាមកុក អ្នកឧកញ៉ា នូ-កន ប្រែរៀបរៀង (ត) . . . . . . . . . ១០៣១
– រឿងព្រេងចិន លោក ភ័យ-ប៊ុក ភូឈួយខែត្រតាកែវ ប្រែរៀបរៀង (ត) . . . . ១០៤១
– រឿងទាក់ដំរី នៃក្រុមទំនៀមទម្លាប់ខ្មែរ . . . . . . . . . . . . . ១០៤៧

*កំណត់និងប្រវត្តិការណ៍*

– សុន្ទរកថានៃលោករដ្ឋលេខាធិការ ក្រសួងធម្មការ . . . . . . . . . . ១០៦១
– សន្និសីទស្ដីពីពុទ្ធសាសនានៃលោកបណ្ឌិតជាតិជប៉ុន . . . . . . . . ១០៦៦

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០

34è Année — N° 9 — Septembre 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

## SOMMAIRE

### Partie religieuse

—Dhammavicharanakatha par le Vénérable KEM-TO . . . . . . 963
—Principes bouddhiques par M. HENG-SAM-AN (suite) . . . . . 979
—Préah Abhidhammapitaka «Kampir Préah Yamaka» par M. BOU-PO (suite) . . . . . . . . . . . . . . . . 988
—Madhurasavahini par S.Em. Préah Dhammalikhita LOUIS-EM Haut Conseiller (suite) . . . . . . . . . . . . . . . . 996
—Mahosotha Jataka (suite) . . . . . . . . . . . . . . . 1006

### Partie littéraire

—Les caractères Khmèrs à l'époque de Hanchey par M. DIK-KEAM 1019
—Activité de la Commission Culturelle chapitre «Ka» (suite) . . . 1028
—Dictionnaire Sanscrit-Khmer par Vén. PANG-KHAT (suite) . . . 1030
—Histoire de Sam-Kok traduite par Oknha NOU-KAN (suite) . . . 1031
—Légende Chinoise traduite par M. RAY-BOUC Phouchhouykhèt de TAKEO. (suite) . . . . . . . . . . . . . . . . 1041
—Histoire de Prise des éléphants par la Commission des mœurs et coutumes Khmer . . . . . . . . . . . . . . . . 1047

### Notes et chroniques

—Discous prononcépar M. le Seerétaire d'Etat anx cultes le 3-9-62 à l'occasion de la Conférence conscrnant la religion Bouddhique 1061
—Texte de Conférence relative à l'évolution de la réligion Bouddhique par M. le Docteur Dut . . . . . . . . . . . 1066

Prix d'Abonnement annuel (comprenant 12 numéros) : 230$ 00

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ ។
ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

## ធម្មវិហារណកថា

### នមត្ថុ រតនត្តយស្ស

សូមនមស្ការ ចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្តីគោរព ។

បន្ទាប់ពីនេះ សូមលើកយកបញ្ហាធម៌ខ្លះ ដែលគេតែងពោលឡើងថា បណ្តាមនុស្សក្នុងលោក មនុស្សខ្លះ ប្រព្រឹត្តធ្វើតែអំពើអាក្រក់ ដោយកាយ វាចា ចិត្ត អ្នកផងឃើញថា មនុស្សនោះ បានទទួលសេចក្តីទុក្ខលំបាក រហូតអស់ជីវិតសមទៅតាមអំពើរបស់គេនោះក៏មាន មនុស្សខ្លះប្រព្រឹត្តធ្វើតែអំពើល្អដោយកាយ វាចា ចិត្ត អ្នកផងឃើញថា មនុស្សនោះបានទទួលសេចក្តីសុខចំរើន រហូតអស់ជីវិតសមទៅតាមអំពើរបស់គេនោះ ក៏មាន ប៉ុន្តែផ្ទុយពីនេះទៅវិញ គឺមានមនុស្សខ្លះ ប្រព្រឹត្តធ្វើតែអំពើ

អាក្រក់ដោយកាយ វាចា ចិត្ត តែម្យ៉ាងសោះទេ តែមនុស្សនោះ ត្រឡប់ទៅជាបានទទួលសេចក្តីសុខ ចំរើនរុងរឿង រហូតអស់ជីវិតទៅក៏មាន មនុស្សខ្លះ ប្រព្រឹត្តធ្វើតែអំពើល្អដោយ កាយ វាចា ចិត្ត តែម្យ៉ាងសោះទេ តែមនុស្សនោះ ត្រឡប់ទៅជាបានជួបប្រទះ នឹងសេចក្តីទុក្ខលំបាកកុំរ៉ៃ រហូតអស់ជីវិតទៅក៏មាន ព្រោះហេតុអ្វី?

ក្នុងផ្នែកអត្ថបទធម៌នេះ សូមអធិប្បាយវែកញែកចំពោះតែមនុស្ស ២ ពួកខាងចុងគឺ មនុស្សដែលប្រព្រឹត្តធ្វើតែអំពើអាក្រក់ ហើយត្រឡប់ទៅជាបានទទួលសេចក្តី សុខ-ចំរើនមួយពួក នឹងមនុស្សដែលប្រព្រឹត្តធ្វើតែអំ-ពើល្អ ហើយត្រឡប់ជាបានទទួលសេចក្តីទុក្ខលំបាកមួយពួក ។ មនុស្សទាំង ២ ពួកនេះ ខ្ញុំសូមលើកយកបាលីពុទ្ធភាសិតពីវគ្គ ក្នុងគម្ពីរខុទ្ទកនិ-កាយធម្មបទ មកធ្វើជាគោលនៃបញ្ហា ដើម្បីអធិប្បាយវែកញែកដោះស្រាយបំភ្លឺសេចក្តីឲ្យឃើញហេតុផល បាលីពុទ្ធភាសិតនោះដូច្នេះ ៖

បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ

យទា ច បច្ចតី បាបំ អថ បាបោ បាបានិ បស្សតិ

ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ

យទា ច បច្ចតី ភទ្រំ អថ ភទ្រោ ភទ្រានិ បស្សតិ ។

ប្រែថា មនុស្សបាប ដរាបណាបើបាបមិនទាន់ឲ្យផលទេ ដរាបនោះរមែងជួបប្រទះតែនឹងអំពើល្អ លុះតែកាលណាបាបឲ្យផល កាល

នោះមនុស្សបាប ទើបជួបប្រទះនឹងបាប ៗ មនុស្សល្អ ដរាបណាបើអំពើល្អមិនទាន់ឲ្យផលទេ ដរាបនោះរមែងជួបប្រទះតែនឹងអំពើអាក្រក់ លុះតែកាលណាអំពើល្អឲ្យផល កាលនោះមនុស្សល្អ ទើបជួបប្រទះនឹងអំពើល្អ ៗ

## មនុស្សបាបជួបនឹងអំពើល្អ

អធិប្បាយពង្រីកសេចក្តីតាមអត្ថន័យក្នុងភាសិតនេះថា អ្នកណាដែលប្រព្រឹត្តធ្វើអំពើអាក្រក់ ដោយកាយទ្វារមានបាណាតិបាតជាដើម ប្រព្រឹត្តធ្វើអំពើអាក្រក់ ដោយវចីទ្វារ មានមុសាវាទជាដើម ប្រព្រឹត្តធ្វើអំពើអាក្រក់ ដោយមនោទ្វារ មានអភិជ្ឈាជាដើម អ្នកនោះហៅថា មនុស្សបាប ឬ មនុស្សលាមកអាក្រក់ ៗ មនុស្សដែលប្រព្រឹត្តធ្វើអំពើអាក្រក់នោះ សូម្បីអ្នកដទៃក៏គេដឹងឮឃើញថាជាមនុស្សប្រព្រឹត្តធ្វើតែអំពើអាក្រក់មែនៗ ប៉ុន្តែមនុស្សនោះ បែរត្រឡប់ជាបានទទួលនូវសេចក្តីសុខ-ចំរើនរុងរឿង ដោយសម្បត្តិមានលាភសក្ការៈ និងយសបរិវារជាដើម ក្នុងបច្ចុប្បន្ននេះទៅវិញ ព្រោះហេតុអ្វី? ព្រោះហេតុថាបាបគឺអំពើអាក្រកដែលមនុស្សនោះកំពុងតែធ្វើមិនទាន់ឲ្យផល លុះតែបាបនោះឲ្យផលកាលណា ទើបមនុស្សនោះឯងទទួលរងនូវទុក្ខគឺអំពើអាក្រក់ផ្សេងៗក្នុងបច្ចុប្បន្ន ឬ ក្នុងបរលោកកាលនោះ ៗ

## មនុស្សល្អជួបនឹងអំពើអាក្រក់

ចំណែកខាងអ្នកណា ដែលប្រព្រឹត្តធ្វើអំពើល្អគឺអំពើជាកុសលដោយ

កាយ វាចា ចិត្ត អ្នកនេះហៅថា មនុស្សល្អ ឬមនុស្សបុណ្យ ៗ មនុស្ស ដែលប្រព្រឹត្តធ្វើអំពើល្អនោះ សូម្បីអ្នកដទៃក៏បានដឹងឮឃើញថាជាមនុស្ស ប្រព្រឹត្តធ្វើតែអំពើល្អសុចរិតមែន ៗ ប៉ុន្តែមនុស្សនោះផ្ទុយទៅវិញ បែរ ត្រឡប់ជាបានទទួលនូវសេចក្តីទុក្ខលំបាករហេមរហាម ក្នុងបច្ចុប្បន្នឬក្នុង បរលោកព្រោះហេតុអ្វី? ព្រោះហេតុថាអំពើល្អដែលមនុស្សនោះ កំពុង ប្រព្រឹត្តធ្វើមិនទាន់ឲ្យផល លុះតែអំពើល្អនោះឲ្យផលកាលណា ទើប មនុស្សល្អនោះឯង បានជួបប្រទះទទួលនូវអំពើល្អ គឺសេចក្តីសុខ-ចំរើនរុង-រឿងដោយសម្បត្តិយសស័ក្តិផ្សេង ៗ ក្នុងបច្ចុប្បន្នជាតិនេះ ឬក្នុងបរលោក កាលនោះ ៗ

## អធិប្បាយសេចក្តីដោយរួបរួម

បើមានគេសួរថា មនុស្សខ្លះ ប្រព្រឹត្តធ្វើតែអំពើអាក្រក់សោះទេ ចុះ ហេតុអ្វីបានជាមនុស្សនោះ ត្រឡប់ជាបានសេចក្តីសុខ-ចំរើនរុងរឿងទៅ វិញ ? មនុស្សខ្លះប្រព្រឹត្តធ្វើតែអំពើល្អដោយកាយ វាចា ចិត្ត តែម្យ៉ាង សោះទេ ចុះហេតុអ្វីបានជាមនុស្សនោះ ត្រឡប់ជាបានសេចក្តីទុក្ខលំបាក ដោយហេតុផ្សេង ៗ ទៅវិញ? បញ្ហានេះ គេអាចឆ្លើយបានតែត្រឹមប៉ុណ្ណោះ ថា មនុស្សដែលប្រព្រឹត្តធ្វើតែអំពើអាក្រក់ ហើយត្រឡប់បានទទួលនូវ សេចក្តីសុខ-ចំរើន ៗ នោះកើតឡើងដោយសារសេចក្តីប្រព្រឹត្តល្អចាស់ របស់មនុស្សនោះដែលមានមកពីក្នុងកាលមុនមកផ្តល់ឲ្យ ឯសេចក្តីអាក្រក់

របស់មនុស្សនោះដែលប្រព្រឹត្តធ្វើក្នុងបច្ចុប្បន្ននេះ មិនទាន់ឲ្យផល ថាដូច្នេះក៏បាន ឬថាបើផលដែលកើតអំពីសេចក្តីប្រព្រឹត្តល្អ របស់មនុស្សនោះពីនាយមកគ្មានទេ បើពិតជាគ្មានមែន ហើយមនុស្សនោះនៅតែបានទទួលសេចក្តីសុខចំរើន ត្រង់នេះត្រូវជ្រាបថា មនុស្សនោះមានសម្បត្តិណាមួយក្នុងសម្បត្តិទាំង ៤ យ៉ាងគឺ គតិសម្បត្តិ,(១) ឧបធិសម្បត្តិ(២), កាលសម្បត្តិ(៣) និងបយោគសម្បត្តិ(៤) អាចជួយការពារឃុំគ្រងមនុស្សអាក្រក់នោះ មិនឲ្យទទួលនូវទោសកំហុសរបស់ខ្លួននោះទៅបានដែរ ។ ចំណែកខាងមនុស្សដែលប្រព្រឹត្តធ្វើតែអំពើល្អ គឺឲ្យទានរក្សាសីលជាដើម ហើយត្រឡប់ជាបានទទួលនូវសេចក្តីទុក្ខលំបាកគ្រោះថ្នាក់ ដោយហេតុផ្សេង ៗ ក្នុងបច្ចុប្បន្នទៅវិញ ក៏ព្រោះតែបាបកម្មចាស់របស់មនុស្សនោះដែលបានធ្វើទុកពីក្នុងកាលមុនមកផ្តល់ឲ្យ ឯសេចក្តីល្អដែលមនុស្សនោះប្រព្រឹត្តធ្វើក្នុងបច្ចុប្បន្ននេះមិនទាន់ឲ្យផល ពុំនោះសោត បើបាបកម្មរបស់មនុស្សនោះពីនាយមកគ្មានសោះទេ ត្រង់នេះគួរជ្រាបថា មនុស្សនោះប្រកបដោយវិបត្តិណាមួយក្នុងវិបត្តិទាំង ៤ យ៉ាងគឺ គតិវិបត្តិ ឧបធិវិបត្តិ កាលវិបត្តិនិងបយោគវិបត្តិ មកកាំងមិនឲ្យមនុស្សប្រព្រឹត្តល្អនោះ បានទទួលនូវសេចក្តីសុខ ចំរើនទៅបាន ។

---

១- ការដល់ព្រមដោយគតិ គឺកើតក្នុងសុគតិភព ។ ២- ការដល់ព្រមដោយឧបធិ គឺមានរាងកាយសមរម្យ ។ ៣ ការដល់ព្រមដោយកាល គឺកើតក្នុងសម័យដែលសម្បូរដោយអាហារជាដើម ។ ៤- ការដល់ព្រមដោយបយោគ គឺចេះលៃលកទុកដាក់ខ្លួនឲ្យប្រព្រឹត្តទៅតាមកាលៈទេសៈ ។

សេចក្តីឆ្លើយមកនេះ ល្មមស្តាប់បាន ឃើញថាសមហេតុសមផល ហើយ ប៉ុន្តែតែងឮពាក្យអ្នកខ្លះ គេសួរថាអើ ខាងជនជាតិខ្មែរយើង គេសង្កេតឃើញថា ច្រើនតែជាអ្នកកាន់ពុទ្ធសាសនា មានការធ្វើបុណ្យឲ្យទានរក្សាសីលជាដើម អស់កាលជាយូរអង្វែងណាស់មកហើយ ចុះហេតុអ្វីបានជាជនជាតិខ្មែរយើងឃើញច្រើនតែជាអ្នកអន់ខ្សោយខាងជីភាព សេចក្តីសុខនិងសម្បត្តិផ្សេងៗ មានភោគសម្បត្តិជាដើមជាងជនជាតិដទៃ ដែលមិនកាន់ពុទ្ធសាសនាទៅវិញ បើអ្នកសរសើរថា ការកាន់ពុទ្ធសាស-នាគឺធ្វើបុណ្យឲ្យទាន រក្សាសីលជាដើម តែងទទួលអំណោយផលបុណ្យដែលខ្លួនធ្វើនោះនឹងឲ្យទៅជាយ៉ាងនេះ ជាយ៉ាងនោះ តាមបំណងដែលខ្លួនត្រូវការ នេះមិនដូច្នោះ ត្រឡប់ជាផ្ទុយទៅវិញ ត្រង់ជនជាតិខ្មែរអ្នកប្រព្រឹត្តធ្វើបុណ្យទៅជាខ្សត់ខ្សោយ ឯជនជាតិដទៃគេមិនសូវអើពើនឹងពុទ្ធសាសនាធ្វើបុណ្យឲ្យទានប៉ុន្មានផង ម្តេចក៏គេបេះតែកបកល់សម្បូរដោយសេចក្តីសុខ-ចំរើន នឹងភោគទ្រព្យគ្រប់យ៉ាងទៅវិញ ?

ការឆ្លើយតបនឹងសំនួរខាងលើនេះ ឃើញថាមានមតិផ្សេងពីគ្នាជាច្រើនយ៉ាងគឺ អ្នកខ្លះថា បុណ្យដែលគេធ្វើនោះ ឥឡូវនេះមិនទាន់ផ្តល់ឲ្យផលទេ លុះតែដល់សាសនានៃព្រះពុទ្ធទៅខាងមុខទៀត ទើបបានឲ្យផល អ្នកខ្លះថា ទោះបីមនុស្សជាតិខ្មែរ ឬ មនុស្សជាតិដទៃណាក៏ដោយ ដែលបានប្រកបដោយសេចក្តីសុខ.ចំរើនរុងរឿងគ្រប់យ៉ាងទាំងប៉ុន្មាននោះ

គឺមនុស្សអ្នកកាន់ពុទ្ធសាសនាធ្វើបុណ្យឲ្យទាន រក្សាសីលហ្នឹងឯង ដែលទៅកើតជាមនុស្សជាតិអស់ទាំងនោះ អ្នកខ្លះថា ធម្មតាអ្នកកាន់ពុទ្ធសាសនាធ្វើបុណ្យឲ្យទាន រក្សាសីលទាំងប៉ុន្មាន លុះអស់អាយុជីវិតហើយ រមែងបានទៅកើតជាទេវបុត្រទេវធីតា សោយសម្បត្តិទិព្វក្នុងឋានសួគ៌ទេវលោកអស់ទៅហើយ ព្រោះកំណើតរបស់ទេវបុត្រ ទេវធីតាក្នុងឋានសួគ៌នោះមានអាយុវែងៗណាស់ មិនងាយនឹងចាប់ត្រឡប់មកកើតជាមនុស្សវិញទេ ព្រោះហេតុនោះបានជាមិនសូវមានមនុស្សជាតិខ្មែរគ្រាន់បើជាងគេ អ្នកខ្លះថា ជនជាតិខ្មែរជាអ្នកឧស្សាហ៍ធ្វើបុណ្យនេះ ធ្វើបុណ្យនោះជារឿយ ៗ ប្រហែលជាជាតិខ្មែរទៅកាន់និព្វានអស់ទៅហើយទេដឹង? ពីព្រោះជាតិខ្មែរ កាលណាធ្វើបុណ្យម្ដងៗ ច្រើនតែប្រាថ្នាទៅរកនិព្វាន បើមិនដូច្នោះទេ គឺជាតិខ្មែរអ្នកធ្វើបុណ្យក្នុងពុទ្ធសាសនាហ្នឹងឯង ដែលទៅកើតជាជាតិជនអ្នកគ្រាន់បើអស់ទាំងនោះ ។

តាមមតិរបស់អ្នកឆ្លើយដូចខាងលើទាំងអស់នោះ ប្រហែលជាមានជំនឿយល់ថា មានតែជនជាតិខ្មែរទេដែលចេះធ្វើបុណ្យ ឯជនជាតិដទៃគ្មានចេះធ្វើបុណ្យទានអ្វីទេដឹង? ឬយល់ថា ការធ្វើបុណ្យទានមានតែក្នុងពុទ្ធសាសនាទេដឹង? បើយល់ដូច្នោះមែន ឲ្យឈ្មោះថាសេចក្ដីយល់នោះនៅក្នុងផ្នែកនៃសេចក្ដីងងឹតងងល់ចង្អៀតចង្អល់ណាស់ មិនទាន់ឈ្មោះថាមានសេចក្ដីយល់ដ៏ទូលំទូលាយ ឬត្រឹមត្រូវនៅឡើយ ម្ល៉ោះហើយបានជា

មានមនុស្សខ្លះមានគំនិតយល់បែបនេះក៏មាន ទាល់គំនិតគិតមិនឃើញក៏មាន អ្នកខ្លះបើធ្វើបុណ្យរួចចង់ឲ្យបុណ្យនោះជួយឆាប់ៗ តាមគោលបំណងដែលខ្លួនត្រូវការ កាលបើមិនបានសម្រេចដូចបំណងទេ ក៏ក្លាយទៅជាមនុស្សមិច្ឆាទិដ្ឋិ លះបង់នូវការកុសលដែលខ្លួនធ្លាប់ធ្វើមកហើយនោះចោលចេញ ដោយគិតឃើញថា ឯងខំប្រឹងធ្វើសេចក្ដីល្អគឺឲ្យទានរក្សាសីលណាស់ដែរ ប៉ុន្តែនៅតែមានការជួបប្រទះ នឹងទុក្ខទោសគ្រោះថ្នាក់អន្តរាយមិនសូវស្រាកយ៉ាងនេះក៏មាន ។

ក្នុងបញ្ហាខាងលើនេះ សូមជម្រាបថា ការធ្វើបុណ្យកុសលមិនមែនមានចំពោះតែក្នុងពុទ្ធសាសនាប៉ុណ្ណោះទេ សូម្បីក្រៅពីពុទ្ធសាសនាដូចជាសាសនាដទៃខ្លះ ក៏គង់មានការធ្វើកុសលសេចក្ដីល្អ បានបុណ្យខ្លះដែរ ព្រោះថាកុសលចែកជា ៣ ផ្នែកគឺហៅថា កាមាវចរកុសល ១ រូបាវចរកុសល ១ អរូបាវចរកុសល ១ ។ កុសលទាំង ៣ យ៉ាងនេះ មានគេធ្វើកើត ធ្វើបាន តាំងពីមុនពុទ្ធកាល គឺមុនដែលព្រះពុទ្ធមិនទាន់បានត្រាស់ដឹងឡើងក្នុងលោកម្ល៉េះ ។

បណ្ដាកុសលទាំង ៣ យ៉ាងនោះ ត្រង់កាមាវចរកុសលមួយនេះជាកុសលដ៏ទូលំទូលាយណាស់ ទុកជាជាតិណា សាសនាណា ក៏គង់មានគេកាន់ គេប្រព្រឹត្តធ្វើបានខ្លះដែរទោះបីតិចច្រើន ដោយហោចទៅសូម្បីសត្វតិរច្ឆានខ្លះ ក៏អាចធ្វើកាមាវចរកុសលនេះបានដែរ មិនចាំបាច់ទាញ

ុទាហរណ៍លើកមកជាបុគ្គលាធិដ្ឋានជាដូចជាសត្វនេះ ឬសត្វនោះទេ បើជាទឹកពីផែនដីរកដោយខ្លួនឯងទៅក៏គង់ឃើញបានខ្លះពុំខាន ព្រោះហេតុនោះ យើងដែលជាពុទ្ធសាសនិកអ្នកមានជំនឿកាន់ខាងពុទ្ធសាសនា កុំអាលស្មានថាជនជាតិដទៃ មិនឃើញមានធ្វើបុណ្យបានកុសលអ្វីសោះនោះ ប្រហែលជាពុំសូវសមទេ ឬយើងយល់ថា កុសលទាំង ៣ យ៉ាងមានកាមាវចរកុសលជាដើម កើតមានតែក្នុងពុទ្ធសាសនាទេដឹង ? បើយល់ដូច្នេះមែន ទុកជាសេចក្ដីយល់នោះ ជាការខុសស្រឡះ តួយ៉ាងដូចព្រហ្មញ្ញសាសនា គឺសាសនាព្រាហ្មណ៍ ជាសាសនាចាស់មានមកជាយូរអង្វែងហើយ តាំងពីមុនពុទ្ធកាលម៉្លេះ សាសនានេះក៏មានន័យនិ-យាយពន្យល់ពីដំណើរបុណ្យនឹងបាប ឬពីកុសលផ្សេងៗ មានកាមាវចរកុសលជាដើម ស្របគ្នានឹងពុទ្ធសាសនាខ្លះដែរ មានបរិស័ទអ្នកកាន់សាសនានេះ គេធ្វើបុណ្យឲ្យទាន សង្គ្រោះស្មូមយាចកអ្នកកំសត់ទុគ៌តរក្សាសីលសង្រួមកាយវាចា ទោះបីដឹងដល់ក្ដី មិនដឹងដល់ក្ដី ទាំងនេះក៏រាប់ថា ជាកុសលមួយហៅថាកាមាវចរកុសលដែរ ដោយអំណាចកាមាវចរកុ-សលនេះ គង់គេបានទៅកើតក្នុងសុគតិភពណាមួយពុំខាន មិនតែប៉ុណ្ណោះមានយោគី ឬតាបសខ្លះ ជាអ្នកបួសពួកមួយខាងក្រៅពុទ្ធសាសនាទេ ប៉ុន្តែជាកម្មវទីបុគ្គល គេអាចតាំងព្យាយាមប្រព្រឹត្តតបធម៌ស្ងប់ស្ងាត់យ៉ាងតឹងរឹង រហូតដល់ញ៉ាំងរូបសមាបត្តិ ឬអរូបសមាបត្តិនឹងអភិញ្ញាជាន់ខ្ពស់ឲ្យ

កើត ដូចអាឡារតាបសនឹងឧទ្ទកតាបសជាតួយ៉ាង ។ កុសលចិត្តដែលកើតឡើងដោយអំណាចសមាបត្តិទាំងនេះ ហៅថារូបាវចរកុសល ឬអរូបាវចរកុសល ជាកុសលអាចញុំាងយោគី ឬតាបសពួកនោះឲ្យទៅកើតក្នុងជាន់រូបព្រហ្មនឹងអរូបព្រហ្មបាន ។

មានជនជាតិដទៃខ្លះទៀត មិនប្រាកដថាជាអ្នកកាន់សាសនាអ្វីទេ ប៉ុន្តែគេមានចិត្តប្រកបដោយសប្បុរិសធម៌ ចំណាយទ្រព្យធន កសាងរបស់ជាប្រយោជន៍សាធារណៈដូចសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពានស្រះទឹក អណ្តូងទឹកជាដើម អំពើទាំងអស់នេះ តើយើងយល់ថាមិនមែនជាបុណ្យកុសលទេឬ ? មួយទៀត ដូចជនជាតិចិនដែលយើងធ្លាប់ឃើញស្រាប់ហើយ គេមានកតញ្ញូកតវេទិតាធម៌ចំពោះមាតាបិតារបស់គេ តាំងពីនៅរស់រហូតដល់អស់ជីវិតទៅហើយ កាលបើដល់រដូវ គេទៅជម្រះទីផ្នូរសព លើកដីថ្មីពូនបន្ថែមឲ្យស្អាត ហើយគេរៀបចំគ្រឿងសក្ការៈផ្សេងៗ ដាក់សែនឧទ្ទិសទឹកត្ពោះទៅករមាតាបិតា ឬជីដូនជីតារបស់គេដោយភាពជាអ្នកមានកតញ្ញូកតវេទិតាធម៌ពិតៗ ត្រង់ការបានឬមិនបានដល់ឬមិនដល់នោះយើងកុំបាច់និយាយចុះ គឺនិយាយចំពោះតែត្រង់អាការដែលគេធ្វើដោយចិត្តស្មោះសរដៅទៅរកអ្នកដ៏មានគុណនោះ ដូច្នេះតើយើងអាចថាត់ថាជាកុសលឬទេ ? យើងយល់ថាពិតជាកុសលរបស់គេជាប្រាកដ ។ កុសលចិត្តនេះឯងហើយ ដែលអាចញុំាងគេឲ្យបាន

ទទួលនូវអានិសង្សឬសម្បត្តិផ្សេង ៗ មានសេចក្តីសុខ-ចំរើន ក្នុងមនុស្សលោកនេះជាដើម កាលបើដូច្នេះ យើងនឹងពោលថាគេគ្មានធ្វើបុណ្យបានអ្វីសោះ គឺដូចជាពុំសមសោះ ឯយើងដែលប្រកាសខ្លួនថាជាអ្នកពុទ្ធសា-សនិកនោះ ប្រហែលជាយល់ថាបុណ្យកុសលមានតែក្នុងពុទ្ធសាសនាតែម្យ៉ាងទេដឹង ឬយល់ថា លុះតែចូលវត្តក៏ធ្វើបុណ្យបានចំពោះព្រះសង្ឃទើបហៅថាធ្វើបុណ្យទេដឹង ? បើយល់ដូច្នេះមែន ឈ្មោះថាយល់ឃើញខ្លី ឬយល់ឃើញតែម្ខាង ៗ ព្រោះកាមាវចរកុសលនេះ ដូចបានពណ៌នាពីខាងដើមរួចមកហើយថាជាកុសលដ៏ទូលំទូលាយងាយធ្វើ កុំបាច់និ-យាយឡើយចំពោះទានដែគេធ្វើដល់មនុស្ស សូម្បីគេធ្វើដល់សត្វតិរច្ឆានក៏ឈ្មោះថាបានបុណ្យខ្លះដែរ ។

ខ្ញុំនិយាយរៀបរាប់មកនេះ មិនមែននិយាយប្រកបដោយអគតិ លំ-អៀងទៅកាន់ជើងសាសនាណា ឬ ជាតិណាមួយទេ គឺគ្រាន់តែនិយាយវែកញែកឲ្យឃើញជាសេចក្តីតាមការណ៍ពិតប៉ុណ្ណោះ ៗ ត្រង់ការធ្វើបុណ្យឲ្យបានជាសាធារណៈ ទូទៅមិនចំពោះបដិគ្គាហកៈខាងក្នុងពុទ្ធសាសនាឬខាងក្រៅពុទ្ធសាសនានោះ ទោះឲ្យដល់មនុស្សថ្នាក់ខ្ពស់ ឬ ទាប ឬក៏ឲ្យដល់សត្វតិរច្ឆាន មានគុណធម៌ក្តី ឥតគុណធម៌ក្តី ពិតមែនដែលថាបានបុណ្យ ប៉ុន្តែសូមឲ្យអ្នកមានវិចារណញាណដ៏ល្អ ក៏គួរតែពិចារណារិះរេវៃលលកផងដែរ ថ្វីដ្បិតតែថាបានបុណ្យ ដូចគ្នានឹងអ្នកធ្វើស្រែ ៗ បើចង់

បានផលស្រូវច្រើនជាទីពេញចិត្ត ក៏គួរពិនិត្យមើលពូជនឹងដីស្រែផង ទើបអាចសម្រេចផលតាមគោលបំណងដែលខ្លួនត្រូវការនោះបាន ។

សូមអធិប្បាយបញ្ជាក់អំពីផលនៃទានមួយទៀតថា បុគ្គលអ្នកធ្វើទាននឹងត្រូវបានទទួលអំណោយផលានិសង្សនៃទាននោះ ឲ្យទៅជាអ្នកមានភោគសម្បត្តិក្នុងជាតិនេះ ឬ ក្នុងជាតិណាមួយ ក្នុងភពមុខនោះនឹងមានជាប្រាកដ ប៉ុន្តែឯផលទានដែលត្រូវបានក្នុងជាតិណាមួយក្នុងភពមុខនោះ ខ្ញុំមិនបានលើកយកមកពណ៌នាបញ្ជាក់ក្នុងទីនេះទេ គឺនិយាយចំពោះតែផលដែលថាត្រូវផ្តល់ឲ្យក្នុងជាតិនេះ ។ ចុះផលរបស់ទាន ដែលត្រូវផ្តល់ឲ្យក្នុងជាតិនេះ តើនឹងផ្តល់ឲ្យដោយវិធីណា? បើផលរបស់ទាននោះ បំរុងតែនឹងចេញមុខឲ្យផលដល់យើងជាម្ចាស់ទានពិតមែន ប៉ុន្តែបើយើងជាមនុស្សខ្ជិលច្រអូសនៅតែស្ងៀម គ្មានកាយវិការប្រារព្ធការងារអ្វីមួយសោះ តើអំណោយផលរបស់ទាននោះ នឹងអាចឲ្យផលកើតដែរឬទេ?. ពិតជាមិនកើតទេ ព្រោះហេតុអ្វី? ព្រោះគ្មានហេតុជាបច្ច័យនាំអាទិឲ្យកើត ។ ដំណើរនេះគួរជ្រាបថា ខ្លួនយើងត្រូវផ្តើមពីខ្លួនយើងជាមុន គឺត្រូវប្រារព្ធការងារណាមួយឲ្យជាហេតុឡើងសិន ប៉ុន្តែបើការងារដែលផ្តើមធ្វើនោះ ជាការងាររប៉ិចរប៉ុចតិចតួច ក៏មិនអាចឲ្យសម្រេចប្រយោជន៍ដ៏ធំដុំបានដែរ ។ ឧទាហរណ៍ដូចអ្នកធ្វើរបរកសិកម្ម គឺមានត្រឹមតែដីស្រែអំពកមួយឬពីរ ឬក៏មានដីចំការត្រឹមតែមួយក្បាលតូចប៉ុណ្ណោះ បើខាងរបរ

ពាណិជ្ជកម្ម (ការជួញ) គឺមានតែជំនួញរចុចរប៉ុរលៀបរលាប ទាំងមិនសមទំនងទៅតាមកាលៈទេសៈផង ពុំនោះសោតបើទុកជាមានដីស្រែចំការ ឬរបរជំនួញច្រើនលើសពីនោះក៏ដោយ ប៉ុន្តែខ្លួនជាមនុស្សលែនលនខ្ជិលច្រអូស គ្មានការតស៊ូ មិនប៉ុនប្រសប់ក្នុងការងារ មានចរិយាថោកទាប ខ្វះសម្បទាទាំង៤ យ៉ាងមានឧដ្ឋានសម្បទាជាដើម បើប្រកបដោយហេតុដូចជាមកនេះ ចំណែកខាងបុណ្យ ដែលបំរុងនឹងឧបត្ថម្ភផ្តល់ផលឲ្យនោះ ក៏នឹងរកឱកាសឲ្យផលពុំកើតដែរ ប្រៀបដូចមនុស្សណាមួយ ជាអ្នកខ្ជិលច្រអូសផង គ្មានសច្ចធម៌ក្នុងខ្លួនផង ល្ងង់ខ្លៅផង មានចរិយាថោកទាបផង ហើយទៅពឹងពាក់ប្រាស្រ័យនឹងអ្នកមានទ្រព្យសម្បត្តិឲ្យគេជួយឧបត្ថម្ភខ្លួនដោយប្រាក់កាស ដើម្បីប្រកបការងាររកស៊ី អ្នកមានទ្រព្យសម្បត្តិនោះ កាលបើគេដឹងឮ ឃើញថាមនុស្សនេះ ជាអ្នកទន់ខ្សោយខ្វះសមត្ថភាពគ្រប់យ៉ាងហើយ គេគ្រាន់តែមានមេត្តាចិត្តទៅរកប៉ុណ្ណោះ ប៉ុន្តែគេមិនចេញទ្រព្យសម្បត្តិ ជួយឧបត្ថម្ភទៅតាមសំណូមរបស់ខ្លួនផងពុំបាន យ៉ាងណា ពុំនោះសោត ប្រៀបដូចរាជសីហ៍ ជាស្តេចនៃម្រឹគទាំងអស់ ជាសត្វមានឥទ្ធានុភាពខ្លាំងពូកែអស្ចារ្យ ឯសត្វទ្វេបាទ ចតុប្បាទដទៃគ្រាន់តែក្រឡេកឃើញរាជសីហ៍ ក៏ភិតភ័យតក់ស្លុតរន្ធត់ញ័រចំប្រប់ ស្ទើរតែក្សិណក្ស័យជីវិត ប៉ុន្តែបើរាជសីហ៍ ដោយអាងថាអញជាស្តេចនៃម្រឹគហើយដេកសម្ងំស្ងៀម ហាមាត់ចន្ទ្រន ដើម្បីឲ្យសត្វម្រឹគបោលមកចូល

ក្នុងមាត់ឲ្យជាអាហាររបស់ខ្លួននោះ ប្រាកដជាគ្មានម្រឹគណាមួយព្រមស្មុះចិត្តរត់ទៅចូលក្នុងមាត់រាជសីហ៍ឲ្យស្លាប់ខ្លួនទទេ ៗ នោះឡើយ រាជសីហ៍នោះលុះមានកាយវិការ ប្រកបដោយព្យាយាមស្វែងរកជន ទើបបានម្រឹគនោះមកជាអាហាររបស់ខ្លួន យ៉ាងណាមិញ ចំណែកខាងផលបុណ្យដែលបំរុងនឹងផ្តល់ឲ្យ ក៏ត្រឡប់ជាផ្អកខានផ្តល់ផលឲ្យទៅវិញ ក៏ដូច្នោះដែរ ។

ត្រង់ពាក្យមួយម៉ាត់ខាងដើម ដែលបាននិយាយមកហើយថា សូម្បីក្នុងសាសនាដទៃខ្លះក្រៅពីពុទ្ធសាសនាដែលជាកម្មវាទី ក៏មាននិយាយពីការបំពេញកុសលផ្សេង ៗ ចំពោះតែកាមាវចរកុសល រូបាវចរកុសល អរូបាវចរកុសល ដូចជាក្នុងពុទ្ធសាសនាដែរ ហើយមានគេពេញចិត្តជ្រះថ្លាធ្វើបុណ្យឲ្យទានរក្សាសីលហើយ បានទាំងទៅកើតក្នុងសុគតិភពជាមនុស្ស ឬជាទេវតាណាមួយដោយកម្លាំងនៃកាមាវចរកុសលនោះក៏មាន មានយោគី តាបសខ្លះឬសខាងក្រៅពុទ្ធសាសនា ព្យាយាមប្រព្រឹត្តតបធម៌យ៉ាងតឹងរ៉ឹងថ្នាក់ទុក្រិដ្ឋដែលហៅថាធ្វើសមាធិ អាចញ៉ាំងឈានទីងអភិញ្ញាឲ្យកើតឡើង លុះដល់ទីបំផុតនៃជីវិត ក៏បានកើតក្នុងជាន់រូបព្រហ្ម ឬអរូបព្រហ្ម ដោយកម្លាំងរូបាវចរកុសល ឬអរូបាវចរកុសលនោះក៏មាន បើតាមសេចក្តីអធិប្បាយនេះ សឲ្យឃើញថា ខាងក្រៅពុទ្ធសាសនាក៏គង់មានផ្លូវធ្វើសេចក្តីប្រតិបត្តិអាចឈោងចាប់យកត្រឹមសម្បត្តិសួគ៌ សម្បត្តិព្រហ្ម ឬសម្បត្តិមនុស្សដូចពុទ្ធសាសនាបានដែរ គ្រាន់តែមិនមានអរិយ-

មគ្គ អរិយផលប៉ុណ្ណោះ ពីព្រោះព្រហ្មញ្ញសាសនានេះ ជាសាសនានៅប្រ-ចាំលោកគឺមានមកតាំងអំពីកាល ដែលទើបនឹងកើតផែនដីឡើងជាដំបូង ហើយបន្ទាប់មកមានមនុស្សកើតឡើង ឯសាសនាក៏កើតឡើងក្នុងសម័យដែលមានមនុស្សនោះដែរ ព្រោះមូលហេតុដែលនាំឲ្យកើតសាសនាមាន ៣ យ៉ាងគឺ

១- សេចក្តីខ្លាច

២- សេចក្តីត្រូវការ

៣- សេចក្តីខ្វះខាត ។

សេចក្តីខ្លាច ជាមូលហេតុនាំឲ្យកើតសាសនា ដូចម្តេច ? ធម្មតាមនុស្សក្នុងលោក សុទ្ធតែមានសេចក្តីស្រឡាញ់ជីវិតគឺការចង់រស់នៅជាប្រក្រតី កាលបើមានហេតុអ្វីជាសត្រូវកើតឡើង បំរុងនឹងប៉ះពាល់ដល់ជីវិតរបស់ខ្លួន រមែងមានសេចក្តីភិតភ័យតក់ស្លុតដោយហេតុតែខ្លាចវិ-នាស ម្ល៉ោះហើយក៏ស្វះស្វែងរកវត្ថុស័ក្តិសិទ្ធិ សម្រាប់ឃុំគ្រងការពារកំដរកុំឲ្យជីវិតវិនាសដោយហេតុណាមួយ ដូចមានពុទ្ធដីកាក្នុងគម្ពីរធម្មបទជាភស្តុតាងស្រាប់ថា :

ពហុំ វេ សរណំ សន្តិ បព្វតានិ វនានិ ច

អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា

សេចក្តីថា មនុស្សមានចំនួនច្រើន កាលបើត្រូវភ័យគម្រាមសម្លុត

ហើយ រមែងតែទៅរកយកភ្នំក៏មាន យកព្រៃឈើក៏មាន យកសួនច្បារក៏មាន យកដើមឈើជាចេតិយក៏មាន ជាទីពឹងឬជាបង្អែក (នៃជីវិតរបស់ខ្លួន) ។ សេចក្ដីភ័យខ្លាចនេះឯង ជាមូលហេតុនាំឲ្យកើតសាសនា ។

សេចក្ដីត្រូវការ ជាមូលហេតុនាំឲ្យកើតសាសនា ដូចម្ដេច? ធម្មតាមនុស្សនីមួយ ៗ នឹងបណ្ដោយឲ្យនៅតាមទំនើងចិត្ត ពោលតែឯកឯង គ្មានពិធីកម្មណាមួយជាច្បាប់សម្រាប់ឃុំគ្រង ដើម្បីឲ្យមានរបៀបរៀបរយពុំបាន កាលបើធ្វើជាមនុស្សនៅទំនេរ ឥតមានច្បាប់ឃុំគ្រងជួយការពារទេ រមែងក្លាយទៅជាមនុស្សឥតសណ្ដាប់ធ្នាប់ព្រហើនកោងកាច ហ៊ានប្រព្រឹត្តអំពើអាក្រក់ផ្សេង ៗ មានការសម្លាប់ជីវិតគេ បៀតបៀនយកទ្រព្យសម្បត្តិគេជាដើម ដោយហេតុថាអំពើអាក្រក់មិនជាទីស្រឡាញ់ពេញចិត្តនៃមនុស្សសត្វទូទៅ ទើបគេត្រូវការតែងតាំងបទបញ្ញត្តិជាច្បាប់សម្រាប់គ្រប់គ្រងការពារ ដើម្បីឲ្យមនុស្សមានចរិយាសណ្ដាប់ធ្នាប់ល្អរវាងគ្នានឹងគ្នាឡើង សេចក្ដីត្រូវការនេះឯង ជាមូលហេតុនាំឲ្យកើតសាសនា ។

(នៅមានត)

# គោលច្បាប់នៃព្រះពុទ្ធសាសនា

# បាកធម្មបទ – ខុទ្ទកនិកាយ

លោក ហោង-សមអាង រៀបរៀង

( តមក )

ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ កាមេសុមិច្ឆាចារ ដែលបុគ្គលបានធ្វើហើយ ជាអំពើប្រព្រឹត្តទៅដើម្បីអបាយ នាំជនទាំងឡាយដល់នូវសេចក្ដីវិនាស ក្នុងបច្ចុប្បន្ន គឺ : វិនាសទ្រព្យសម្បត្តិដែលរកបានមកល្មមប្រើប្រាស់គ្រប់គ្រាន់ ក៏ត្រឡប់ជាមិនគ្រប់គ្រាន់វិញ ព្រោះអំពើនេះត្រូវតែងតួហួសហេតុ ចាយវាយហួសខ្នាត ។ វិនាសញាតិ-មិត្រទាំងឡាយដែលធ្លាប់រាប់អាន ទុកចិត្តស្និទ្ធស្នាល ព្រោះមនុស្សដែលប្រព្រឹត្តកាមេសុមិច្ឆាចារនេះ រមែងតែតែហ៊ានឡើងៗ ដកបដល់ក្រុមមិត្រ ឥតគិតចិត្តនរណាសោះ ប្រពន្ធ-កូននរណាក៏ដោយ ឲ្យតែរូបល្អ កាលបើដូច្នោះ នឹងធ្លាក់ខ្លួនទៅជាព្រាននារីគ្មាននរណាចូលចិត្ត ។ វិនាសខ្លួនប្រាណ ដែលធ្លាប់មានកម្លាំង ធ្លាប់មានសាច់ឈាមល្អ ធ្លាប់ជាអ្នកមិនមានរោគ ក៏ត្រឡប់ទៅជាមនុស្សមានកាមរោគ ខូចខ្លួនអសារឥតការ លុះស្លាប់ទៅទៀតតែទៅកើតក្នុងនរក រួចពីនរកមកកើតជាប្រេត រួចពីប្រេតមកកើតជាអសុរកាយ

រូបពីអសុរកាយ មកកើតជាតិរច្ឆាន រូបពីតិរច្ឆាន មកកើតជាមនុស្សខ្ទើយ រូបពីខ្ទើយមកកើតជាមនុស្សស្រី មានប្ដីនៅជាមួយគ្នាមិនបាន (១) ។

កាមេសុមិច្ឆាចារកម្ម លោកឲ្យឈ្មោះថា " ទោស " ជាអំពើមិនត្រូវធ្វើឡើយ ។

## វចីកម្ម

វចីកម្ម គឺអំពើដែលធ្វើអាក្រក់ដោយសំដី មាន ៤ យ៉ាងគឺ : មុសាវាទ ១ បិសុណាវាទ ១ ផរុសវាទ ១ សម្ផប្បលាបវាទ ១ :

៤- មុសាវាទ គឺការពោលនូវពាក្យកុហក ។

ពាក្យកុហក ធ្វើឲ្យអ្នកដទៃវិនាសទ្រព្យសម្បត្តិក៏មាន វិនាសយសសក្តិក៏មាន វិនាសជីវិតក៏មាន ឲ្យកើតសេចក្ដីលំបាកផ្សេងៗក៏មាន ។ មុសាវាទនេះ ទុកជាអ្នកស្ដាប់មិនជឿ មិនធ្វើតាមក៏ឈ្មោះថា ពោលពាក្យកុហក ជាហេតុធ្វើឲ្យអ្នកដទៃ មិនជឿពាក្យសំដីទាំងអស់ គឺគេដឹងថា អ្នកនោះធ្លាប់កុហក ថ្ងៃក្រោយនិយាយត្រង់ក៏គេមិនជឿ ។ អំពើកុហកនេះ បើមានកម្លាំងច្រើនក៏អាចធ្វើឲ្យឃើញទោសក្នុងបច្ចុប្បន្ននេះ ឧទាហរណ៍ដូចជា៖

---

១- អង្គុត្តរនិកាយ អដ្ឋកថានិបាតសព្វលហុសូត្រ ។

# រឿងនាងចិញ្ចមាណវិកា

កាលព្រះបរមសាស្ដាចារ្យនៃមនុស្សទាំងទេវតា ទ្រង់គង់ក្នុងវត្តជេតពន នាក្រុងសាវត្ថីនៃដែនកោសល ព្រះអង្គគង់លើរតនបល្ល័ង្ក សំដែងព្រះធម៌ ដោយមានពុទ្ធបរិស័ទទាំង ៤ ពួកគឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អង្គុយគាល់ស្ដាប់ព្រះធម៌ទេសនា ៗ នាងចិញ្ចមាណវិកាបានទទួលបញ្ជាពីពួកនិគ្រន្ថតិរ្ថិយ ទៅនិយាយកុហកបង្កាច់ព្រះសាស្ដាចារ្យ ដោយមេថុនធម្ម ចំពោះមុខពុទ្ធបរិស័ទ ៗ តែដោយបារមីព្រះអង្គ មានព្រះឥន្ទមកជួយក្នុងរឿងនោះ នាងចិញ្ចមាណវិកាក្លែងបោះបង្កាច់មិនបាន ត្រឡប់ជាមានទោស គឺពួកមហាជនវាយធាក់ហៀបនឹងស្លាប់ ៗ លុះគេបផុតពីទីនោះទៅ ទើបតែផុតកន្ទុយព្រះនេត្រព្រះសម្ពុទ្ធ ផែនដីមិនអាចទ្រនាំងបាន ក៏ស្រុបទម្លាក់ចុះទៅក្នុងអវិចីមហានរក រងទុក្ខវេទនា រហូតសព្វថ្ងៃនេះ ៗ

ព្រោះហេតុនោះ ព្រះមានព្រះភាគបរមគ្រូទ្រង់ត្រាស់ថា « ម្នាលភិក្ខុទាំងឡាយ ! មុសាវាទ ដែលបុគ្គលបានពោលហើយ ជាអំពើប្រព្រឹត្តទៅដើម្បីអបាយ (គឺឲ្យវិនាសអន្តរាយទ្រព្យសម្បត្តិក៏មាន ឲ្យថោកទាបដល់ខ្លួនក៏មាន ជួនកាលស្លាប់ខ្លួនក៏មាន ) លុះស្លាប់ទៅ ទៀងតែទៅកើតក្នុងនរក រួចពីនរកមកកើតជាប្រេត រួចពីប្រេតមកកើតជាអសុរកាយ រួចពីអសុរកាយមកកើតជាតិរច្ឆាន រួចពីតិរច្ឆានមកកើតជា

មនុស្ស តែជាមនុស្សត្រូវគេបង្កាច់បង្ខូចដរាប គឺជាកំហុសបុគ្គលដទៃសោះ ស្រាប់តែកំហុសនោះធ្លាក់មកខ្លួនវិញ ហើយជាមនុស្សមាត់ឆែបវៀច-ស្អុយ[1]” ។

មុសាវាទ ជាពាក្យអាក្រក់ លោកឲ្យឈ្មោះថា បាប ជាពាក្យមិនត្រូវពោលឡើយ ។

៤- បិសុណាវាទ កិរិយាពោលនូវពាក្យញុះញង់ សិកសៀត បំបែកបំបាក់អ្នកដទៃ ។

ពាក្យញុះញង់សិកសៀត គឺរើសយករឿងខាងម្ខាង ទៅប្រាប់ដល់ម្ខាង ដោយចេតនាប្រាថ្នានឹងឲ្យគេស្អប់ខ្ពើមមនុស្សដែលខ្លួនមិនត្រូវចិត្ត។ បើរឿងនិយាយញុះញង់ជាពាក្យពិត ក៏គ្រាន់តែជាបិសុណាវាចតែម្យ៉ាងប៉ុណ្ណោះ បើរឿងនិយាយញុះញង់ជាពាក្យមិនពិតផង ក៏ជាមុសាវាទថែមទៀត ។

ពាក្យញុះញង់សិកសៀត ជាពាក្យនាំឲ្យអ្នកស្តាប់បែកចេញពីគ្នា ឈ្មោះវិវាទបង់ពៀរនឹងគ្នា ។ មិនតែប៉ុណ្ណោះ ធ្វើទាំងអ្នកនិយាយនោះឲ្យកើតសេចក្តីក្តៅក្រហាយដល់ខ្លួនវិញក្នុងជាតិនេះក៏មាន ទឹងជាតិខាងមុខក៏មាន ឧទាហរណ៍ដូចជា ៖

---

[1]- អង្គុត្តរនិកាយ អដ្ឋកនិបាត សព្វលហុសូត្រ ។

# រឿងសូករប្រេត (១)

ក្នុងសាសនកាលនៃព្រះពុទ្ធព្រះនាម កស្សប មានភិក្ខុពីររូបរួមអាវាសជាមួយគ្នា ព្រះមហាថេរបួសបាន ៦០ វស្សា អនុថេរ បួសបាន ៥៩ វស្សា ស្រឡាញ់គ្នាដូចជាបងប្អូនបង្កើត ។

គ្រានោះ មានភិក្ខុជាធម្មកថិក ១ រូប បានមកនៅអាវាសនោះ ឃើញវត្តនោះសម្បូណ៌ចង្ហាន់ឆាន់ ក៏ចង់និយាយញុះញង់បំបែកព្រះថេរៈទាំងពីរឲ្យបែកគ្នា ទើបនិយាយថា "បពិត្រលោកម្ចាស់ដ៏ចំរើន តាំងពីខ្ញុំព្រះករុណាមកដល់ អនុថេរតែងនិយាយនឹងព្រះករុណាថា ម្នាលលោកសប្បុរស លោកជាកុលបុត្រ ឯមហាថេរជាភិក្ខុអលជ្ជី គ្មានសីលជាទីស្រឡាញ់ឡើយ បើលោករួមឆាន់ជាមួយមហាថេរនោះ ត្រូវពិចារណាសិន" ។ ព្រះធម្មកថិក ពោលញុះញង់ព្រះមហាថេរហើយ ក៏ទៅនិយាយញុះញង់អនុថេរដូច្នោះទៀត ។ ព្រះថេរៈទាំងពីរបែកចិត្តគ្នាក៏ដើរចេញពីវត្តនោះទៅទីទៃពីគ្នា ។

លុះកន្លងចំនួន ១០០ វស្សា ក៏បានជួបគ្នាហើយនិយាយប្រាប់គ្នានឹងគ្នា ដឹងថាមិនមែនដូច្នោះ ក៏ស្រុះស្រួលគ្នាទៅបណ្ដេញព្រះធម្មកថិកចេញពីវត្តនោះទៅ ។

---

១ ធម្មបទដ្ឋកថាមលវគ្គ

សមណធម៌ ដែលព្រះធម្មកថិកបានធ្វើហើយ ២ ហ៊ឺនឆ្នាំ ក៏មិនអាចទ្រទ្រង់ព្រះធម្មកថិកបានឡើយ លុះព្រះធម្មកថិកនោះអស់ព្រះជន្មាយុ បានទៅកើតក្នុងមហាអវិចិនរកអស់១ ពុទ្ធន្តរ ដល់មកសាសនាព្រះពុទ្ធ-គោតមយើងនេះ សត្វនរកនោះមកកើតជាប្រេតឈ្មោះ សូករ នៅនាភ្នំគិជ្ឈកូដ មានសរីរៈដូចជាមនុស្ស មានកំពស់ ៣ គាវុត(១) មានក្បាលដូចជាជ្រូក មានកន្ទុយចេញពីមាត់ ហើយមានដង្កូវហូរចេញពីមាត់នោះជាច្រើន ។

ព្រោះហេតុនោះ ព្រះសក្យមុនីជាម្ចាស់ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កិរិយាញុះញង់ដែលបុគ្គលបានពោលហើយ ជាអំពើប្រព្រឹត្តទៅដើម្បីអបាយ គឺនាំឲ្យវិនាសសេចក្ដីសុខផ្ទាល់ខ្លួន ទឹងសេចក្ដីសុខសម្រាប់ស្រុកទេស ព្រោះថាបុគ្គលណាពោលញុះញង់បំបែកបំបាក់គេ សេចក្ដីបែកបាក់នោះនឹងធ្លាក់មកលើខ្លួនវិញ ហើយឥតមានសាមគ្គីជាកម្លាំងប្រទេសឡើយ ។

ម្យ៉ាងទៀត ប្រទេសណាមានមនុស្សប្រព្រឹត្តញុះញង់គ្នា ប្រទេសនោះមិនសូវបានសន្តិសុខទេ ច្រើនតែមានរឿងហេតុនាំឲ្យខូចប្រយោជន៍ នាំឲ្យជោកតាបដល់ជាតិនិងប្រទេស ។ មនុស្សប្រព្រឹត្តនូវពាក្យញុះញង់នោះ លុះស្លាប់ទៅទៀងតែទៅកើតក្នុងនរក រួចពីនរកមកកើតជាប្រេត

---

១ មាត្រាវាស់មានចំនួនពីរពាន់ព្យាម ត្រូវជាមួយរយសិន ។

រូបពីប្រេតមកកើតជាអសុរកាយ រូបពីអសុរកាយមកកើតជាតិរច្ឆាន រូបពីតិរច្ឆានមកកើតជាមនុស្ស តែជាមនុស្សត្រូវបែកបាក់មិត្រសម្លាញ់ ឥតមានទីណាស្រឡាញ់ចូលចិត្តខ្លួនឡើយ ។

បិសុណាវាចា ជាពាក្យអាក្រក់ លោកឲ្យឈ្មោះថា ចាប ជាអំពើមិនត្រូវពោលឡើយ

៦- ផរុសវាចា កិរិយាពោលនូវពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃ ។

បុគ្គលដែលមានបំណងនឹងឲ្យអ្នកដទៃអប្បយស ហើយនិយាយបន្តុះបង្អាប់ថា "អាឯងជាជាតិពាល" ឬនិយាយចំអកថា "អើបាឯងជាជាតិបណ្ឌិតហើយ ដូច្នេះជាដើម ហៅថាសំដីទ្រគោះ សំដីទ្រគោះនេះឯងតែងធ្វើអ្នកដែលស្តាប់ឲ្យប្រទូសតទង ហើយជេរប្រទេចផ្តាសាមកវិញ កាលបើតបតគ្នាទៅវិញទៅមកហើយ ក៏រាលដាលធំធ្ងោសឡើង ជាកបចងពៀរដល់គ្នានឹងគ្នាតទៅបាន ។ សូមពិនិត្យអ្នកដែលឈ្លោះវិវាទទាស់ទែងខ្វែងគំនិតគ្នា ដែលធ្លាប់ឃើញមកហើយនោះចុះ ។ បើជេរប្រទេចផ្តាសាចំពោះបុគ្គលមានគុណច្រើនជាងខ្លួន មានទោសធ្ងន់ បើមានគុណវិសេសតិចជាងខ្លួន ទោសនោះក៏ស្រាល ដូចជាកោកាលិកភិក្ខុ ដែលធរណីស្រូបធ្លាក់ទៅកន្លង បទុមនរក នោះក៏ព្រោះតែទោសដែលជេរប្រទេចព្រះអគ្គសាវក ។

ពាក្យទ្រគោះដេរប្រទេចផ្ដាសានេះ សូម្បីតែសត្វតិរច្ឆានក៏មិនពេញចិត្តឡើយ ឧទាហរណ៍ដូចជា៖

## រឿងគោនន្ទិវិសាល[១]

មនុញ្ញំ ឯវ ភាសេយ្យ នាមនុញ្ញំ កុទាចនំ
មនុញ្ញំ ភាសមានស្ស គរុភារំ ឧទព្វហិ
ធនញ្ច នំ អលាភេសិ តេន ចត្តមនោ អហុ[២] ។

"គ្រប់ពេលទិវានិងរាត្រី បុគ្គលប្រុសស្រីទាំងក្មេងចាស់ ត្រូវពោលពាក្យផ្អែមពីរោះច្បាស់ មិនត្រូវពោលផ្ដាសប្រាសល្អឡើយ ។ កាលព្រាហ្មណ៍ពោលពាក្យស្នេហ៍ស្និទ្ធស្នាល គោនន្ទិវិសាលមិនកន្ដើយ ទំអូសរទេះជូនបានហើយ គោញ៉ាំងព្រាហ្មណ៍ឲ្យបានមាសប្រាក់" ។

ក្នុងអតីតកាល ព្រះពោធិសត្វយកកំណើតកើតជាគោឈ្មោះ គោនន្ទិវិសាល នៅក្នុងក្រុងតក្កសិលានៃប្រទេសគន្ធារៈ ។ ព្រាហ្មណ៍ជាម្ចាស់នៃគោនន្ទិវិសាល មានសេចក្ដីពបអានស្រឡាញ់ពេញចិត្តណាស់ ហាក់ដូចជាកូនបង្កើតរបស់ខ្លួន តែងឲ្យចំណីអាហារ ដល់គោបរិភោគជាពល់ថ្ងៃ ។ គោនន្ទិវិសាលមានសេចក្ដីអនុគ្រោះដល់ព្រាហ្មណ៍ក៏និយាយថា « បពិត្រព្រាហ្មណ៍ ! សូមអ្នកនិយាយថា គោខ្ញុំ ១ អាចអូស

១–ព្រះបរមសាស្ដាទ្រង់តិះដៀលបញ្ចវគ្គិយភិក្ខុ ដែលពោលនូវផរុសវាចា ទើបនាំអតីតនិទាននេះមកសំដែង

២–ជាតកនន្ទិវិសាលជាតក ឯកនិបាត

រទេះ ១០០ ដែលចងជាប់គ្នា ហើយអ្នកចុះប្តេជ្ញាតាំងភ្នាល់នឹងគោវិន្ទសេដ្ឋី ដាក់ប្រាក់ ១០០០ កហាបណៈចុះ" ។ ឯព្រាហ្មណ៍ជាម្ចាស់ ក៏ទៅនិយាយដូច្នោះហើយផ្ទុកនូវរទេះ ១០០ ដោយភារៈដ៏ធ្ងន់ មានដីខ្សាច់ក្រួសនិងថ្មជាដើម រៀបចំតាមលំដាប់ ចងភ្ជាប់ដោយខ្សែព្រួរដ៏មាំ ទើបនាំគោឈ្មោះនន្ទិវិសាលមកទឹម ហើយអង្គុយលើទូករទេះ លើកដងជន្ទូញឡើងស្រែកគម្រាមនន្ទិវិសាល ដែលមិនមែនជាគោកៀចថា : នែគោកៀច! ចូលឯងទំប្រឹងអូសរទេះនេះទៅ នែគោកៀច ! ចូរឯងប្រឹងអូសភារៈធ្ងន់នេះទៅ"។ គោនន្ទិវិសាលបានស្តាប់សំដីមិនជាទីគាប់ចិត្ត ក៏ទប់ទ្រឹងនឹងនៅក្នុងទីនោះគ្មានកំរើក ។ ព្រាហ្មណ៍ចាញ់អស់ប្រាក់ ១០០០ កហាបណៈ ហើយត្រឡប់ទៅផ្ទះវិញ មានសេចក្តីស្តាយពេកណាស់ ក៏ដេកសន្លឹកសន្លៃតែម្នាក់ឯង ។

( នៅមានត )

ព្រះអភិធម្មបិដក

# គម្ពីរព្រះយមកៈ

*លោក ប៊ូ - ប៊ូ ប្រែរៀបរៀង*

( ៣មក )

---

## ចិត្តយមក

យស្ស ចិត្តំ ឧប្បជ្ជតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន និរុជ្ឈិស្សតិ យស្ស និរុជ្ឈតិ តស្ស ឧប្បជ្ជិស្សតីតិ ន ឧប្បជ្ជិស្សតីតិ ។ អាមន្តា យស្ស ឧប្បជ្ជតិ តស្ស និ-រុជ្ឈិស្សតិ យស្ស និរុជ្ឈតិ តស្ស ឧប្បជ្ជិស្សតីតិ ។

*លំដាប់នេះ សូមវិសជ្ជនាក្នុងចិត្តយមកតទៅ ដំណើរសេចក្តីថា សត្ថា សម្តេចព្រះបរមសាស្តាលោកុត្តមាចារ្យ ធម្មាធម្មេសុ កោ-វិទោ ព្រះអង្គទ្រង់ព្រះប្រាជ្ញាញាណក្នុងធម៌និងមិនមែនធម៌ កាលត្រាស់ទេសនាអនុសយយមករួចហើយ ក្នុងលំដាប់នោះ ទើបត្រាស់ទេសនានូវចិត្តយមកៈតទៅទៀត ដោយបុច្ឆានិងវិសជ្ជនាជាគូៗ គ្នា ទ្រង់ត្រាស់បុច្ឆាថា យស្ស ចិត្តំ ឧប្បជ្ជតិ ចិត្តនៃបុគ្គលណាកើតឡើង ចិត្តនៃបុគ្គលនោះរលត់ទៅ ឬថាមិនបានរលត់ទេ ចិត្តនៃបុគ្គលណារលត់ទៅ*

ចិត្តនៃបុគ្គលនោះកើតឡើងឬ ឬថាមិនបានកើតឡើងទេ ចិត្តនៃបុគ្គលណាកើតឡើង ចិត្តនៃបុគ្គលនោះ រមែងរលត់ទៅក្នុងបច្ចុប្បន្នឬ ឬថានឹងរលត់ទៅក្នុងអនាគតកាល ចិត្តនៃបុគ្គលណារលត់ទៅក្នុងបច្ចុប្បន្ន ចិត្តនៃបុគ្គលនោះរមែងកើតឡើងក្នុងបច្ចុប្បន្នឬ ឬថានឹងកើតឡើងក្នុងអនាគតកាល ?

ទ្រង់ត្រាស់បុច្ឆាដូច្នេះហើយ ទើបត្រាស់វិសជ្ជនាថា អាមន្តា អើ ! ចិត្តនៃបុគ្គលណាកើតឡើង ចិត្តនៃបុគ្គលនោះឯងរលត់ទៅ ចិត្តដែលកើតឡើងហើយនឹងមិនរលត់ទៅវិញនោះគ្មានទេ ចិត្តនៃបុគ្គលណារលត់ទៅ ចិត្តនៃបុគ្គលនោះឯងដែលនឹងមិនកើតឡើងវិញគ្មានទេ ចិត្តនៃបុគ្គលណាកើតឡើងក្នុងបច្ចុប្បន្ន ចិត្តនៃបុគ្គលនោះឯងតែងរលត់ទៅក្នុងបច្ចុប្បន្ន ចិត្តនៃបុគ្គលណាកើតឡើងក្នុងអនាគត ចិត្តនៃបុគ្គលនោះក៏រលត់ទៅវិញក្នុងអនាគត ចិត្តដែលកើតឡើងក្នុងអតីតកាល ក៏មានកំណត់ថារលត់ទៅហើយក្នុងអតីតកាល ការកើតនឹងរលត់នោះជារបស់គ្នា ចិត្តកើតឡើងក្នុងកតពណា ក៏រលត់ទៅវិញក្នុងកតពនោះ ចិត្តដែលកើតឡើងហើយមិនបានរលត់ទៅវិញនោះគ្មានទេ ចិត្តដែលរលត់ទៅហើយនឹងមិនកើតឡើងវិញនោះក៏គ្មានដែរ សមតាមបាលីថា អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ ជាអាទិ ។

សង្ខារទាំងឡាយមិនទៀងទាត់ទេ ព្រោះហេតុអ្វី ព្រោះហេតុថា

កើតឡើងហើយតែងរលត់ទៅវិញ មានការកើតនឹងរលត់ជាធម្មតា ដែលថាកើតហើយរលត់ទៅវិញជាធម្មតានោះ ព្រោះហេតុថា កើតឡើងហើយរលត់ទៅវិញ ។

ប្រការមួយទៀត សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ថា ចិត្តំ លហុបរិវត្តំ ចិត្តនោះកើតក៏រហ័សរលត់ក៏រហ័ស ។ ហេតុនោះបានជាពោលថា ចិត្តនៃបុគ្គលណាកើតឡើង ចិត្តនៃបុគ្គលនោះតែងរលត់ទៅវិញ ចិត្តនៃបុគ្គលណារលត់ទៅហើយ ចិត្តនៃបុគ្គលនោះតែងកើតឡើងវិញ ។

គម្ពីរព្រះអភិធម្មត្ថសង្គហៈពោលថា ចិត្តមានបួនប្រការ គឺកាមាវ-ចរចិត្ត ១ រូបាវចរចិត្ត ១ អរូបាវចរចិត្ត ១ លោកុត្តរចិត្ត ១ ។

កាមាវចរចិត្តមាន ៥៤ គឺអកុសលចិត្តមាន ១២ អហេតុកចិត្តមាន១៨ កាមាវចរកុសលចាត់ជាសោភណចិត្តមាន ២៤ រួមជាកាមាវចរចិត្ត ៥៤ ។ រូបាវចរកុសលមាន ៥ ។ អរូបាវចរកុសលមាន ៤ ។ លោកុត្តរកុសល-ចិត្តមាន ៤ ។

អកុសលចិត្ត ១២ នោះ គឺលោភចិត្ត ៨ ទោសចិត្ត ២ មោហចិត្ត ២ រួមចូលគ្នាជា ១២ ដួង ។

អហេតុកចិត្ត ១៨ នោះ គឺអកុសលវិបាកអហេតុក ៧ មហាវិបាកចិត្ត ៨ អហេតុកកិរិយាចិត្ត ៣ រួមចូលគ្នាជា ១៨ ដួង ។

កាមាវចរសោភណចិត្ត ២៤ នោះគឺមហាកុសល ៨ មហាវិបាក៨ មហាកិរិយា ៨ រួមចូលគ្នាជា ២៤ ដួង ។

រូបាវចរកុសល ៥ នោះគឺចិត្តក្នុងបឋមជ្ឈាន ១ ចិត្តក្នុងទុតិយជ្ឈាន១ ចិត្តក្នុងតតិយជ្ឈាន១ ចិត្តក្នុងចតុត្ថជ្ឈាន ១ ចិត្តក្នុងបញ្ចមជ្ឈាន ១ រួមចូលគ្នាជា ៥ ដួង ។ បើពោលដោយពិស្តាររូបាវចរកុសលមាន ១៥ ដួង បន្ថែម ១០ មកទៀត គឺរូបាវចរវិបាកចិត្ត ៥ រូបាវចរកិរិយាចិត្ត ៥ រួមនឹងចិត្តក្នុងឈាន ៥ ខាងដើមផង ត្រូវជា ១៥ ដួង ។

អរូបាវចរចិត្ត៤នោះ គឺអាកាសានញ្ចាយតនចិត្ត ១ អាកិញ្ចញ្ញាយ-តនចិត្ត១ វិញ្ញាណញ្ចាយតនចិត្ត ១ នេវសញ្ញានាសញ្ញាយតនចិត្ត ១ ។ អរូបាវចរចិត្តនេះចែកចេញទៅទៀតមាន ១២ គឺបន្ថែមវិបាកចិត្ត៤ នឹងកិរិយាចិត្ត ៤ ទៀត ផ្សំនឹងអរូបាវចរចិត្ត ៤ ខាងដើមផង ត្រូវជា ១២ ដួង។

លោកុត្តរចិត្ត ៤ នោះ បើពោលដោយប្រភេទមាន ៨ ប្រការ គឺចិត្តដើម ៤ ជាមគ្គចិត្ត បន្ថែមផលចិត្ត ៤ ទៀត ផ្សំគ្នាជា ៨ ដួង ។

ចិត្តដែលឈ្មោះថា កាមាវចរ នោះ មានពាក្យព្រះអដ្ឋកថាចារ្យពោលទុកដោយបទវិគ្រោះថា កាមេ អាវចរតីតិ កាមាវចរំ ចិត្តចំពូកណារមែងប្រព្រឹត្តទៅក្នុងកាមាវចរភព ចិត្តចំពូកនោះឈ្មោះ កាមាវចរចិត្ត ។ ចិត្តជាកាមាវចរមាន ១១ ប្រការ ព្រោះហេតុបង្កើតក្នុងកាមាវចរភូមិ ១១ ។ ឯកាមាវចរភូមិនោះ ខាងក្រោមរាប់តាំងពីមហា

អវិចិនរកឡើងមកដរាបដល់ជាន់បរនិម្មិតវសវតី ឈ្មោះថាកាមគត ព្រោះហេតុជាទីបង្កើតនៃកិលេសកាមនិងវត្ថុកាម ។

ចិត្តចំពួកណាប្រព្រឹត្តទៅក្នុងកាមាវចរភូមិទាំង ១១ ជាន់នោះ ចិត្តចំពួកនោះឈ្មោះថាកាមាវចរចិត្ត ។

ចិត្តដែលប្រព្រឹត្តទៅក្នុងរូបគត ឈ្មោះ រូបាវចរចិត្ត ។

ចិត្តដែលប្រព្រឹត្តទៅក្នុងអរូបគត ឈ្មោះ អរូបាវចរចិត្ត ។

ចិត្តដែលប្រព្រឹត្តទៅក្នុងលោកុត្តរធម៌ ឈ្មោះ លោកុត្តរចិត្ត ។

អារម្មណំ ចិន្តេសិ ធម្មជាតដែលហៅថាចិត្តនោះ ព្រោះហេតុគិតនូវអារម្មណ៍ ។ ន័យមួយទៀតថា ធ្វើនូវអារម្មណ៍ឲ្យវិចិត្រ ។ ន័យម្យ៉ាងទៀតថា សន្សំនូវសន្តាននៃខ្លួន ដោយអំណាចវិថីនៃជវនៈ ។ ន័យម្យ៉ាងទៀតថា ហេតុវិចិត្រដោយសមគួរដល់ប្រក្រតីនៃខ្លួន និងធ្វើនូវអារម្មណ៍ឲ្យវិចិត្រផ្សេងៗ អធិប្បាយថា ប្រកបដោយរាគៈក៏មាន ប្រកបដោយទោសៈក៏មាន ជួនកាលប្រកបដោយមោហៈក៏មាន ។

ចិត្តនោះជាពួកៗ ដោយឡែកពីគ្នា គឺចិត្តជាកាមាវចរនោះពួកដទៃ ចិត្តជារូបាវចរនោះពួកដទៃ ចិត្តជាអរូបាវចរនោះពួកដទៃ ។ ចិត្តមានរូបារម្មណ៍ជាដើមនោះពួកដទៃ ។ ចិត្តដែលមានរូបារម្មណ៍ជាដើមនោះ ជួនកាលក៏ជាកុសល ជួនកាលក៏ជាអកុសល ។ ឯចិត្តនេះមានច្រើនប្រការណាស់ កម្រនឹងពណ៌នាឲ្យអស់បាន ប៉ុន្តែ អ្នកមានប្រាជ្ញាគប្បីចូលចិត្ត

ថា ចិត្តនេះពោលដោយសង្ខេបមានត្រឹម ៤ ប្រការ គឺ កាមាវចរចិត្ត ១ រូបាវចរចិត្ត ១ អរូបាវចរចិត្ត ១ និងលោកុត្តរចិត្ត ១ ដូចវិសជ្ជនាមកហើយនេះ ។

ចិត្តយមក ចប់ប៉ុណ្ណេះ ។

## ធម្មយមកៈ

ធម្មយមកំ ធរេស្សន្តោ សម្តេចព្រះទ្រង់ព្រះភាគ កាលត្រាស់ទេសនានូវចិត្តយមកចប់ហើយ កន្លងលំដាប់នោះ ទើបត្រាស់ទេសនានូវធម្មយមកតទៅទៀត ។ ក្នុងធម្មយមកនោះ ព្រះអង្គទ្រង់ត្រាស់បុច្ឆានិងវិសជ្ជនាជាគូ ៗ គ្នា ទ្រង់ត្រាស់បុច្ឆាថា កុសលាកុសលធម្មា កុសលទាំងឡាយឈ្មោះថាកុសលធម៌ កុសលធម៌នោះឬឈ្មោះថាកុសល ? អកុសលនោះឬឈ្មោះថាអកុសលធម៌? អកុសលធម៌នោះឬឈ្មោះថាអកុសល?

សម្តេចព្រះបរមសាស្តាត្រាស់ទេសនាក្នុងអព្យាកតធម៌ ក៏ត្រាស់ដូចគ្នានេះដែរ ។ ត្រាស់បុច្ឆាដូច្នេះហើយ ទើបត្រាស់វិសជ្ជនាថា អាមន្តា អើ! កុសលនោះឯងឈ្មោះថាកុសលធម៌ អកុសលនោះឯងឈ្មោះថាអកុសលធម៌ ។ ក្នុងអព្យាកតធម៌នោះ ក៏ត្រាស់វិសជ្ជនាដូច្នេះដែរ ។

មានពាក្យព្រះអដ្ឋកថាចារ្យអធិប្បាយថា សម្តេចព្រះមានព្រះភាគត្រាស់ទេសនាក្នុងធម្មយមកនេះ ទ្រង់ត្រាស់ទេសនាដោយធម៌ ៣ ប្រការ គឺធម៌ជាកុសល ១ ធម៌ជាអកុសល ១ ធម៌ជាអព្យាក្រឹត ១

ធម៌ជាកុសលនោះ បានដល់ចិត្តចេតសិកជាកុសល ។

ធម៌ជាអកុសលនោះ បានដល់ចិត្តចេតសិកជាអកុសល ។

ធម៌ជាអព្យាក្រឹតនោះ បានដល់ចិត្តចេតសិកជាអព្យាក្រឹត ។

ចិត្តជាកុសលនិងជាអកុសលនោះ ដូចចិត្តជាកុសលនិងជាអកុសល ដែលបានសំដែងរួចហើយក្នុងចិត្តយមក ។

ក្នុងធម្មយមកនេះ សំដែងតែចេតសិកជាកុសលនិងជាអកុសល សូមសំដែងក្នុងអកុសលចេតសិកជាមុន ។ ក្នុងអកុសលចេតសិកនោះ គឺ មោហោ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ លោភៈ ទិដ្ឋិ មានៈ ទោសោ ឥស្សា មច្ឆរិយៈ ថីនមិទ្ធៈ វិចិកិច្ឆា ។

ឯមោហោនោះ បានដល់សេចក្ដីវង្វេង ។ អហិរិកៈនោះបានដល់គ្មានសេចក្ដីអៀនខ្មាសអំពីបាប ។ អនោត្តប្បៈនោះ បានដល់គ្មានសេចក្ដីខ្លាចអំពីបាប ។ ឧទ្ធច្ចៈនោះ បានដល់ចិត្តអណ្ដែតអណ្ដូងរាយមាយ ។ លោភៈនោះ បានដល់ចិត្តលោភ ។ ទិដ្ឋិនោះ បានដល់មិច្ឆាទិដ្ឋិ គឺគំនិតយល់ឃើញខុស ៦២ ប្រការ ។ មានៈនោះ បានដល់ការប្រកាន់ខ្លួនមានប្រកាន់ដោយជាតិជាដើម ។ ទោសោនោះ បានដល់សេចក្ដីក្រោធខឹង ។ ឥស្សានោះ បានដល់ចិត្តឫស្សាគីប្រណែនគេ ។ មច្ឆរិយៈនោះ បានដល់សេចក្ដីកំណាញ់ ។ ថីនមិទ្ធៈនោះ បានដល់ចិត្តធុញថប់រួញរាងោកងុយដេក ។ វិចិកិច្ឆានោះ បានដល់សេចក្ដីសង្ស័យ ។

អកុសលចេតសិកធម៌ទាំងពួងនេះ បើកើតមានក្នុងសន្តានៃបុគ្គលណា ក៏ជាហេតុនឹងធ្វើបុគ្គលនោះ ឲ្យវិនាសចាកប្រយោជន៍ក្នុងជាតិនេះនឹងជាតិមុខ ។ ហេតុនោះ សម្តេចព្រះបរមសាស្តាទើបត្រាស់ទេសនារាប់នូវធម៌ទាំងឡាយមានមោហោជាដើមនេះចូលក្នុងអកុសលចេតសិក ។

ឯចេតសិកខាងកុសលនោះ គឺ សទ្ធា សតិ ហិរិ ឱត្តប្ប តត្រមជ្ឈត្តតា ។

សទ្ធានោះ បាននឹងអាការដែលជឿក្នុងព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណ នឹងជឿក្នុងផលទាន ផលសីល ។

សតិនោះ បាននឹងការនឹករឭកក្នុងព្រះពុទ្ធគុណជាដើម ។

ហិរិនោះ បាននឹងសេចក្តីអៀនខ្មាសអំពីបាប ។

ឱត្តប្បៈនោះ បាននឹងសេចក្តីខ្លាចអំពីបាប ។

តត្រមជ្ឈត្តតានោះ បាននឹងឧបេក្ខាទាំង ១០ ប្រការ ។

កុសលចេតសិកទាំងនេះ បើកើតមានក្នុងសន្តានៃបុគ្គលណា តែងនឹងញុំាងបុគ្គលនោះឲ្យដល់នូវសេចក្តីសួស្តីមង្គល ប្រកបដោយប្រយោជន៍ជាសុខក្នុងជាតិនេះនឹងជាតិមុខ ។ ហេតុនោះ សម្តេចព្រះបរមសាស្តាទ្រង់ត្រាស់ទេសនាលើកសទ្ធាឡើងជាអាទិ៍ រាប់ចូលក្នុងចេតសិកខាងកុសលក្នុងធម្មយមកដោយប្រការដូច្នេះ ។

ធម្មយមក ចប់ប៉ុណ្ណេះ ។

---

(នៅមានត)

# មធុរសវាហិណី

## សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

លំដាប់នោះ ព្រះសក្កទេវរាជ ទ្រង់បើកទិព្វចក្ខុរមិលមើលស្ថានមនុស្សលោក បានឃើញនូវអាកប្បកិរិយាដ៏អាក្រក់ ដែលពួកជនជាមិច្ឆាទិដ្ឋិធ្វើដូចនោះ ហើយទ្រង់ដល់នូវសេចក្តីសំវេគស្លុតព្រះហឫទ័យ ក៏ហោះផ្លេកផ្លោះចុះមកកាន់ស្ថានមនុស្សលោកមួយរំពេច ហើយនិមិត្តធ្វើឲ្យព្រះពុទ្ធរូបមានអាការហាក់ដូចជាផ្ទំ និមិត្តធ្វើរូបអ្នកតាឲ្យទូនសិរសាក្រាបថ្វាយបង្គំព្រះបាទទាំងគូនៃព្រះបដិមាដំណាងព្រះមានព្រះភាគដោយគោរពស្រេចហើយ សម្តែងប្រាប់នូវពតិមាននោះដល់ឧបាសកឧបាសិកាទាំងឡាយឲ្យបានដឹងហេតុសព្វគ្រប់ ក៏ហោះទៅកាន់ស្ថានសួគ៌ជាទីលំនៅរបស់ព្រះអង្គវិញហោង ។

លុះដល់ថ្ងៃជាគំរប់ប្រាំពីរ ពេលព្រឹក ពួកឧបាសកឧបាសិកាទាំងនោះ ក៏បបួលគ្នាចូលទៅកាន់សំណាក់ព្រះបរមក្សត្រិយ៍ ហើយលើកកំបង់អញ្ជលីឡើងក្រាបបង្គំទូលយ៉ាងនេះថា ទេវៈបពិត្រព្រះសម្មតិទេព ឥឡូវនេះព្រះឥស្សូរដែលជារូបអ្នកតា របស់ជនជាមិច្ឆាទិដ្ឋិប្រែកាយទូនសិរសា ក្រាបថ្វាយបង្គំព្រះបាទទាំងគូនៃព្រះបដិមាដំណាងព្រះមានព្រះភាគជាម្ចាស់នៃយើងទាំងឡាយទៀបព្រះបាទនោះឯង ។

កាលនោះ សម្តេចព្រះទរិន្ទ្រាធិបតីបរមក្សត្រិយ៍ បានទ្រង់ព្រះសណ្តាប់ពាក្យនៃពុទ្ធបរិស័ទទាំងឡាយហើយ ស្តេចក៏ទ្រង់បញ្ជាឲ្យអាមាត្យទាំងឡាយវាយស្គរភេរីដើយផ្សាយទៅក្នុងនគរទាំងអស់ថា "ឲ្យមហាជនទាំងឡាយមកប្រជុំសន្និបាតក្នុងទីនោះស្រេចហើយ ស្តេចយាងទៅជាមួយនឹងមហាជនទាំងអស់នោះដែរ លុះស្តេចចូលទៅកាន់រោងអ្នកតា ហើយស្តេចទ្រង់ត្រាស់បង្គាប់ឲ្យទំលាយត្រាលើវត្ថុសម្រាប់បិទបាំងបើកទ្វាររោងអ្នកតាហើយ ទ្រង់បញ្ជាឲ្យនាំយកផែនក្តារនោះចេញមក ស្រាយសំពត់សាជកដែលរុំព័ទ្ធព័ន្ធនោះចេញក្នុងគ្រានោះឯង ។

លំដាប់នោះ ព្រះមហាក្សត្រិយ៍ក្តី មហាជនទាំងឡាយក្តី បានឃើញនូវបាដិហារ្យដ៏ប្រសើរជាទីអស្ចារ្យយ៉ាងនោះហើយ ក៏កើតសេចក្តីស្ញប់ស្ញែងក្នុងចិត្តពន់ពេក ទាំងកើតជ្រះថ្លាក្នុងគុណព្រះសាស្តាក្រៃលែង ហើយជនទាំងអស់នោះក៏លះបង់មិច្ឆាទិដ្ឋិ គំនិតដែលគិតឃើញខុស គឺប្រកាន់យករូបអ្នកតាជាទីគោរពនោះចោលជាស្រេចហើយ បានដល់នូវព្រះគុណនៃព្រះបរមគ្រូសាស្តាចារ្យជាម្ចាស់ជាទីពឹងទីរលឹក ឥតមានសេចក្តីសង្ស័យឡើយ ។

គ្រានោះព្រះកូមិន្ទ្រាធិបតីបរមក្សត្រិយ៍ ស្តេចទ្រង់ត្រាស់បញ្ជាសេវកាមាត្យ ឲ្យវាយបំបែកទំលុះទំលាយរោងអ្នកតានោះចោលចេញហើយ ស្តេចបរិច្ចាគទ្រព្យកសាងព្រះវិហារយ៉ាងធំគួរជាទីសប្បាយ ហើយព្រះអង្គ

តែងបំពេញនូវបុញ្ញកម្មផ្សេង ៗ ដរាបដល់អស់ព្រះជន្មក៏បានឡើងទៅកើតក្នុងស្ថានសួគ៌ទេវលោកនាយ សោយនូវទិព្វសម្បត្តិជាសុខក្សេមក្សាន្តដ៏ក្រៃលែង ។

ព្រោះហេតុនោះ ព្រះអរហន្តទាំងឡាយ ដែលបានសម្តែងរឿងនិទាននេះចប់ហើយ លោកពោលជាបទព្រះគាថាថែមទៀតថា :

អច្ចន្តំ សត្ថុ ធរិយមានេ
ការេន្តិ ចិត្វា កុសលានិ ឯត្ថ
យេ តេ មុនិន្ទេ បរិនិព្វុតម្ហិ
ការេន្តិ បុញ្ញានិ មហន្តន្តិ ។

អធិប្បាយថា « កាលដែលព្រះបរមសាស្តាទ្រង់ធរមាននៅ ជនទាំងឡាយណា បានឃើញនូវឥទ្ធិបាដិហារ្យ (នៃព្រះអង្គ) ហើយខ្វល់ខ្វាយចាត់ចែងធ្វើនូវកុសលផ្សេង ៗ អំពើនោះក៏មិនជាអស្ចារ្យឡើយ កាលបើព្រះមុនីមានព្រះភាគជាធំជាងអ្នកប្រាជ្ញ ទ្រង់ចូលព្រះបរមនិព្វានទៅហើយ ជនទាំងឡាយណា បានឃើញនូវឥទ្ធិបាដិហារ្យ (នៃព្រះអង្គ) ហើយជ្រះថ្លាចាត់ចែងធ្វើបុណ្យទាំងឡាយ អំពើនោះហៅពេញជាអស្ចារ្យប្រសើរមែនពិត ។

សម្តែងរឿងនិទានជនអ្នកនៅនាកំពង់ឈ្មោះកាចរៈជាគំរប់ប្រាំ ក្នុងវគ្គទីបី ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះឯង ។

## ៦– ចោរឃាដកវត្តកថា

សម្តែងរឿងនិទានបុរសអ្នកសម្លាប់ចោរគេទៅទៀត ដោយព្រះបាលីថា ឯកស្មឹ កិរ សមយេ ដូច្នេះជាដើម អធិប្បាយថា បានឮរឿងៗមកថា ក្នុងសម័យមួយ ព្រះមានព្រះភាគជាម្ចាស់នៃយើងទ្រង់ប្រទានធម៌ទេសនាពន្យល់នូវស្ថានសួគ៌និងព្រះនិព្វាន ដល់មហាជនហើយព្រះអង្គអាស្រ័យនៅក្នុងវិហារជេតពន ទៀបក្រុងសាវត្ថី ។

សម័យនោះឯង មានចោរប្រាំរយនាក់ចេញមកអំពីដងព្រៃ បានធ្វើចោរកម្ម ក្នុងចំណែករាត្រី ពុំដែលដាច់គឺលួចប្លន់យកទ្រព្យគេ មកចិញ្ចឹមជីវិតខ្លួន ព្រមទាំងកូនប្រពន្ធ ដោយអំពើនោះឯង ។

លុះថ្ងៃមួយជាខាងក្រោយទៀត ចោរទាំងនោះក៏នាំគ្នាចូលទៅកាន់ទីក្រុងដើម្បីធ្វើចោរកម្ម ក៏បានឃើញមនុស្សអ្នកជនបទម្នាក់ជាអ្នកកំសត់អត់ឃ្លានឈរនៅទៀបទ្វារក្រុងហើយសួរថា ម្នាលបុរសដ៏ចំរើន អ្នកឯងអាស្រ័យនៅស្រុកណា ។

ឯបុរសកំសត់នោះ បាននិយាយប្រាប់ថា ខ្ញុំនេះជាអ្នកកំសត់នៅអាស្រ័យក្នុងជនបទឯណោះអ្នក? ។

ចោរទាំងឡាយនោះ និយាយតបទៅនឹងបុរសអ្នកជនបទវិញ ដើម្បីល្បួងបញ្ចុលឲ្យចូលក្នុងពួកខ្លួនថា: អ្នកឯងរស់នៅដោយការចិញ្ចឹមជីវិតទាំងទុក្ខលំបាកយ៉ាងនេះធ្វើអ្វី ត្រូវតែអ្នកចូលមកប្រព្រឹត្តធ្វើចោរកម្មជាមួយ

នឹងពួកយើងហើយចិញ្ចឹមកូនប្រពន្ធដោយអំពើនោះជាការងាយជាងអ្នកមិនត្រូវនៅដោយការចិញ្ចឹមជីវិតដ៏លំបាក មានទុក្ខព្រួយដូចនេះទៀតឡើយ ។

ឯបុរសនោះ ក៏បានទទួលព្រមតាមពាក្យចោរទាំងនោះដោយគំនិតល្ងង់យល់ថា ចោរទាំងឡាយនិយាយនេះគួរស្តាប់បានមែន ដូចនេះត្រូវតែអាត្មាអញរួមគំនិតជាមួយនឹងចោរទាំងនោះចុះ ។

លុះពួកចោរនឹងអ្នកជនបទ យល់ស្របគ្នាហើយ ទើបពួកចោរទាំងនោះក៏និយាយផ្ទួនទៀតថា អ្នកត្រូវចូលមកជាមួយនឹងយើងក្នុងកាលឥឡូវនេះឯង ហើយក៏នាំយកបុរសនោះដើរចូលទៅខាងក្នុងទីក្រុងលួចប្លន់អ្នកក្រុងជាលំដាប់ពីផ្ទះមួយទៅផ្ទះមួយ ៗ តែយ៉ាងនោះឯង ។

មិនយូរប៉ុន្មាន បុរសអ្នកជនបទតែងសន្សំបានទ្រព្យធនជាច្រើន ទើបគិតថា អំពើដែលអាត្មាអញប្រព្រឹត្តធ្វើនេះ ជាអំពើដ៏ប្រសើរដោយពិត លុះគិតយ៉ាងនេះហើយក៏ប្រព្រឹត្តធ្វើអំពើចោរកម្មចិញ្ចឹមជីវិត ជាមួយនឹងពួកចោរទាំងនោះជាដរាប ។

ស្រាប់តែដល់ថ្ងៃជាខាងក្រោយទៀត រាជបុរសទាំងឡាយគេដើរល្បាតចាប់ពួកចោរទាំងនោះបាន គេចងសេកយ៉ាងមាំ នាំយកទៅថ្វាយដល់ព្រះបាទបសេនទិកោសលរាជ សូមស្តេចទ្រង់វិនិច្ឆ័យទោសានុ-ទោសតាមច្បាប់សម្រាប់ព្រះនគរ ។

ឯសម្ដេចព្រះបមបុរី ស្ដេចទ្រង់ទតទៅយល់ពួកចោរទាំងឡាយ ហើយ ទ្រង់មានព្រះរាជឱង្ការត្រាស់យ៉ាងនេះថា នែនាយទាំងអស់គ្នា អើយ ! ក្នុងចំណោមអ្នកទាំងឡាយនេះ តើអ្នកណាអាចសំឡាប់ចោរ ទាំងនេះឲ្យក្សិណក្ស័យជីវិតបាន យើងនឹងឲ្យជីវិតទានដល់អ្នកនោះឯង ។

ឯចោរទាំងអស់នោះ លុះបានស្ដាប់ព្រះរាជឱង្ការត្រាស់សួរដូចនោះ ហើយ ក៏ពុំបានប្រាជ្ញាដើម្បីនឹងសំឡាប់គ្នានឹងគ្នាឡើយ ព្រោះពួកចោរ ទាំងនោះ សុទ្ធតែជាញាតិមិត្តនឹងគ្នាទៅវិញទៅមកយូរយារណាស់ហើយ ទើបពុំអាចសំឡាប់គ្នាឯងបាន ។

ចំណែកឯបុរសអ្នកជនបទនោះ ក៏ក្រាបបង្គំទូលថា: បពិត្រព្រះ សម្មតិទេព ខ្ញុំព្រះករុណាថ្វាយវិសេស អាចនឹងសំឡាប់ពួកចោរទាំងអស់ នេះបានសូមទ្រង់ជ្រាប ។ ស្ដេចក៏ទ្រង់អនុញ្ញាតដល់បុរសនោះ ៗ ក៏សំ-ឡាប់ពួកចោរទាំងអស់នោះ ឥតមានរួញរាឡើយ ។

ព្រះបរមក្សត្រិយ៍ ទ្រង់បានឃើញបុរសនោះអាចហ៊ានសំឡាប់ចោរ ទាំងឡាយបានដូចនោះហើយ ក៏មានព្រះហឫទ័យត្រេកអរពន់ពេក ទ្រង់ ព្រះរាជទាននូវចោរឃាតកម្ម ដំណែងការសម្រាប់សំឡាប់ចោរដល់បុរស នោះតាំងពីថ្ងៃនោះតទៅ ។

លុះបុរសនោះបានទទួលភារៈជាអ្នកសម្លាប់ចោរហើយ ក៏តែងតែ សម្លាប់ចោររាល់ៗថ្ងៃអស់កាលជាអម្រុងយូររង់ ២៥ ឆ្នាំ ក៏ដល់នូវភាព

ចាស់ដកមានកម្លាំងថយ ពុំអាចនឹងប្រហារចោរ តែមួយដងបាន ឡើយ មានតែប្រហារពីរបីដងទើបបានស្លាប់ ព្រោះខ្លួនមានកម្លាំងថយពេកណាស់ ។

ទើបព្រះបាទបសេនទិកោសលរាជ ស្តេចទ្រង់ជ្រាបសេចក្តីនោះហើយ ទ្រង់បានបញ្ជប់បុរសនោះចេញពីមុខដំណែង ហើយទ្រង់ប្រទានដំណែងចោរឃាដកម្មនោះ ដល់បុរសដទៃវិញ ។

ឯចោរឃាដកបុរសនោះ កាលបើស្តេចបានបន្ទយចេញអំពីដំណែងជាអ្នកសម្លាប់ចោរហើយ ក៏ដល់នូវសេចក្តីលំបាកពាល់ក្រ តែងនៅអាស្រ័យក្នុងផ្ទះរបស់ខ្លួនតាមភាពជាអ្នកខ្សត់ខ្សោយនោះ ។

កាលនោះ មានបុរសកំឡោះដទៃម្នាក់ពុំស្គាល់ឈ្មោះជាអ្នកចេះមន្តអាចសម្លាប់មនុស្សដោយគ្រាន់តែរាយមន្តហើយ បញ្ចេញខ្យល់តាមច្រមុះក៏អាចសម្លាប់បាន ។

ឯមន្តនោះសោត បើយើងមានប្រាថ្នាចង់កាត់បំបាក់ ទំលាយបណ្តាអវយវទាំងឡាយ មានដៃ ជើង ត្រចៀក ច្រមុះ នឹង ក្បាលជាដើមអវយវណាមួយហើយ យើងសូត្ររាយមន្តបញ្ចេញផ្សាយមន្តទៅតាមច្រមុះ សំដៅទីត្រង់ណា ទីត្រង់នោះក៏ដាច់ចេញមួយរំពេច ដោយរិទ្ធិអានុភាពនៃមន្តនេះឯង ។

មិនយូរប៉ុន្មាន ស្រាប់តែបុកណាចោរឃាដកាមាត្យចាស់នោះ បាន

ចូលទៅផ្គាប់ផ្គុណបំរើអ្នកគំនោះដែលចេះមន្តហើយសុំរៀនមន្តនោះ បាន ចេះចប់សំរេចដូចបំណងក៏ត្រឡប់មកផ្ទះខ្លួនវិញ ទើបបញ្ជូនចុតហ្មាយ ទៅថ្វាយចំពោះព្រះបរមក្សត្រិយ៍ដើម្បីទ្រង់ជ្រាបសេចក្តីសព្វគ្រប់ថា: ខ្ញុំព្រះករុណាថ្វៃវិសេសនេះ កាលពីមុនតែងធ្វើអំពើកាត់ផ្គាប់ខ្ទអែវយមាន ដៃទឹងជើងជាដើមរបស់ពួកចោរបានទាំងលំបាក ឬការសម្លាប់ចោរដែល គួរសម្លាប់ក៏បានទាំងលំបាកណាស់ ព្រោះខ្វល់ព្រះបន្ទំមានវ័យចាស់ តែ ឥឡូវនេះ ខ្ញុំព្រះអង្គសូមធ្វើទីដំណែងនោះទៀត ព្រោះខ្ញុំព្រះអង្គ បានចេះ មន្តមួយពូកែវិសេសធុតធាប់ណាស់ ខ្ញុំព្រះអង្គអាចនឹងកាត់បំបែកខ្ទម្លាយ ឬសម្លាប់ចោរទាំងឡាយដោយអានុភាពមន្តរបស់ខ្ញុំព្រះអង្គ បានដោយ ងាយ ។

ឯព្រះបរមក្សត្រិយ៍ លុះទ្រង់ព្រះសណ្តាប់សេចក្តីចុតហ្មាយនោះ ហើយ ទ្រង់ក៏ទទួលព្រមថាៈសាធុប្រពៃហើយ ទ្រង់ត្រាស់បង្គាប់ឲ្យហៅ បុរសនោះចូលមកគាល់ ទ្រង់ក៏បានប្រទានទីដំណែងងារដដែលនោះដល់ បុកណេចោរឃាដកាមាត្យនោះដូចប្រក្រតីវិញ ។

អាមាត្យនោះ តែងប្រព្រឹត្តអំពើសំឡាប់ ចារកខ្ទង់ទៅបាន ២៥ ឆ្នាំ ទៀត ។

កន្ទងកាលជាខាងក្រោយនេះ អាមាត្យនោះក៏កាន់តែចាស់ដកពន់ពេក មានអាយុច្រើន មានកំឡាំងថយចុះ មានតែសេចក្តីស្លាប់នៅខាងមុខ

មានជម្ងឺឈឺជាទម្ងន់ដេកបដល់ស្រែកថ្ងូរដោយសម្រែកលាន់ឮខ្លាំង មាន ភ័យយ៉ាងធំបំផុត ព្រោះមរណទុក្ខបៀតបៀនក្រពេក តែអាមាត្យនោះ ធ្មេចភ្នែកទៅ ក៏បានឃើញនិរយបាលទាំងឡាយកាន់ញញួរដែក ដំបង ដែកមានជ្រុងបួនសឹងឆេះភ្លឺរុងរឿងដោយអណ្តាតភ្លើងនរក មុខគួរខ្លាច ស្ញប់ស្ញែងពន់ពេក គាត់ក៏ដេកបំរះនទៀលក្នុងកាលនោះឯង ។

លំដាប់នោះ មនុស្សអ្នកស្និទស្នាលនាផ្ទះជិតខាងនោះ លុះបាន ឮសំឡេងដែលគួរខ្លាចស្ញប់ស្ញែងដូចនោះ ក៏ភ័យញ័ររន្ធត់រត់ចោលផ្ទះចល់- នៅទីទៃៗក្នុងកាលនោះឯង ។

មានសេចក្តីដំណាលថា សម័យមួយនោះ ព្រះសារីបុត្តត្ថេរដ៏មាន អាយុ លោកបានរមិលមើលដោយទិព្វចក្ខុបានឃើញនូវបុរសអ្នកសម្លាប់ ចោរដែលជិតនឹងស្លាប់ លុះស្លាប់ហើយមុខជានឹងទៅកើតក្នុងអវិចីនរក ដោយពិត កាលបើព្រះថេរបានជ្រាបសព្វគ្រប់ហើយ ក៏មានព្រះ ហឫទ័យមេត្តាអាណិតបុរសនោះបានរំពឹងពិចារណាថា ប្រសិនបើអាត្មា អញបានទៅក្នុងទីនោះហើយ ចោរឃាដកាមាត្យនេះ នឹងមានចិត្តជ្រះថ្លា ចំពោះអាត្មាហើយ ក៏ធ្វើកាលកិរិយាក្សិណក្ស័យ នឹងបានឡើងទៅកើតឯ ស្ថានសួគ៌ទេវលោកនាយ ដោយពិត ៗ ព្រះថេរបានគិតតទៅទៀតថាថ្ងៃ នេះត្រូវតែអាត្មាអញធ្វើសេចក្តីអនុគ្រោះចំពោះបុរសនោះទើបគួរ លុះគិត

យ៉ាងនេះហើយ ក៏ទ្រង់ស្បង់ប្រដាប់បាត្រ ក្នុងបុព្វណ្ហសម័យនិមន្តចេញទៅឈរទៀបទ្វារផ្ទះនៃចោរឃាដកបុរសនោះឯង ។

ចំណែកឯបុរសនោះ បានឃើញព្រះថេរហើយ ក៏ក្រោធខឹងជាញឹកញ៉យដូចលេកខ្ញុំប្រាំងមានចិត្តញាប់ញ័រលាន់មាត់ថា: គជ:គជ: ដោយសេចក្ដីក្រោធខ្លាំង គាត់ដេកគិតថា អញនឹងកាយមន្តសំឡាប់សមណកំណាចនេះ ឥឡូវនេះឯង ហើយសូត្រកាយមន្តផ្លាយខ្យល់ចេញទៅតាមច្រមុះ ដើម្បីសំឡាប់ព្រះថេរនោះដូចបំណង ។

ក្នុងខណៈនោះ ព្រះថេរក៏បានចូលកាន់សមាបត្តិ ហើយចេញអំពីសមាបត្តិមួយរំពេច លោកមានរស្មីរុងរឿងពីដូចព្រះអាទិត្យទើបនឹងរះឡើងបានឈរនឹងនៅក្នុងទីដដែលនោះឯង ។

ចំណែកឯចោរឃាដកាមាត្យ ក៏រឹងរិតតែខឹងខ្លាំងហើយសូត្រកាយមន្តផ្លាយខ្យល់ចេញទៅតាមច្រមុះ យ៉ាងនោះពីរដងបីដង ក៏គង់ពុំអាចនឹងធ្វើអវយវៈនីមួយរបស់ព្រះថេរៈឲ្យកម្រើកបានឡើយ ហើយត្រឡប់ជាមានចិត្តគិតសង្វេគស្ញប់ស្ញែងក្រៃពេក ក្នុងគុណព្រះថេរៈក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាជាថ្មីទៀត ទើបចាត់ចែងបុគ្គការិយាឲ្យថ្វាយបាយាសដែលគេតាក់តែងបម្រុងខ្ទុនចំពោះព្រះមហាសារីបុត្តថេរក្នុងកាលនោះឯង ។

(នៅមានត)

(តមក)

មួយទៀតសោត ស្ដេចចុលនីព្រហ្មទត្ត នូវសេនាយោធានោះច្រើន តោះយោបីកាន់នូវខ្សាច់ម្នាក់មួយដៃ ទំលាក់បោះចុះក្នុងគូក៏ពេញឡើងហោង តោះយោបីកាន់ដីដុំមួយដុំម្នាក់ក្ដី បោះចុះជាផ្នូកឡើងប្រមាណស្មើកាតបន្ទាយក៏គប្បីបានហោង មួយទៀតសោតនាបីហៅកលអធិប្បាយ (សេចក្ដីប្រាថ្នា) នោះ សំរឹទ្ធិពួកនាពោធិសត្វទាំងឡាយ គស្មា ព្រោះហេតុដូច្នោះ ឃ កោបិ ជនោ សូម្បីទឹងមានអ្នកណាមួយនាបីហៅទឹងបោះចុះនូវខ្សាច់មួយដៃក្ដី ដុំដីមួយដុំក្ដី ធ្លោះចូលទៅក្នុងនគរនោះគ្មានឡើយ ។ អស់ពលសកលយោធាទាំងឡាយ ក៏ត្រឡប់វិលមកក្រោយហើយទៅកាន់ស្ថានទីតអាត្មាទីទៃ ៗ ហោង ។ កជា គោវដ្ដំ មុច្ចិ គាំ គារោម អាចរិយាតិ ។ ស្ដេចចុលនីព្រហ្មទត្ត បន្ទូលដណ្ដឹងអាចារ្យកេវដ្ដព្រាហ្មណ៍ថា ហៃអាចារ្យអើយ ! តើយើងធ្វើដូចម្ដេច ? ។ ទើបអាចារ្យកេវដ្ដព្រាហ្មណ៍ទូលថា ទេវ បពិត្រអើយ ! រីឯមនុស្សទាំងឡាយក្នុងនគរនោះសោត យើងនឹងក្រវែលចាំសម្លាប់ កុំឲ្យចេញបានដោយនូវទ្វារបន្ទិចដល់តិចឡើយ រីមនុស្សមិនបានទឹងចេញទៅណា ទឹងជាក្រសាលនោះ ផ្សិតគេនឹងបើកទ្វារចេញមកឯងហោង លំដាប់នោះ

អាចារ្យកេវដ្តព្រាហ្មណ៍ថា នាយើងនឹងចាប់ឲ្យបានកជាសត្រូវនេះ ដោយនូវដំរេះកលប្រាជ្ញាយើងហោង ។ ស្តេចចុលនីព្រហ្មទត្តទទួលយល់ព្រមថា ហៃអាចារ្យអើយ ! ឧបាយនេះ យល់ល្អប្រពៃពេកហោង ។ សូមរីរើចៅមហោសថអ្នកប្រាជ្ញ អ្នកដឹងនូវគតិមានដូចយើងស្រដីអំពីមុននោះហោង ពោធិសត្វពឹងគិតថា ទីលែងក៏សត្រូវនេះក៏មកនៅនាឋាននេះលង់ពេកហោង នាបីហៅនឹងជាសុខនាយើងនោះគ្មានឡើយ ថាបើដូច្នោះហើយ គួរហោងអញនឹងបណ្តាញដោយឧបាយកលមួយ ពោធិសត្វថា អញនឹងបណ្តាញស្តេចចុលនីព្រហ្មទត្តនឹងមន្ត្រីទាំងឡាយ ។ ពោធិសត្វថា អញនឹងជ្រើសរើសឲ្យបានអាមាត្យមួយ ឲ្យចេះស្រដីឈ្លាសវៃនូវពាក្យឧបាយល្អក្តាត់ ពោធិសត្វថា អញនឹងបណ្តាញស្តេចចុលនីព្រហ្មទត្ត ពោធិសត្វអ្នកយល់អាចារ្យមួយឈ្មោះ អនុកេវដ្តព្រាហ្មណ៍ ពោធិសត្វអ្នកឲ្យហៅអាមាត្យនោះមកហើយថ្លាថា ហៃអាចារ្យអើយ ! គួរយើងមានអំពើកលអ្វីមួយ អញនឹងធ្វើជាឲ្យព្រះស្តេងឯងចុះគេហើយមកអញគិត ។ អនុកេវដ្តព្រាហ្មណ៍ថា ហៃចៅអ្នកប្រាជ្ញអើយ ! យើងនឹងធ្វើដូចម្តេច ? ចូរអ្នកសំដែងនូវអំពើនោះហោង ។ ពោធិសត្វថា ចូរព្រះស្តេងឯងឡើងទៅបិតលើកាគចន្ទាយ ព្រះស្តេងរមិលមើលនូវសេចក្តីប្រមាទនៃមនុស្សម្នាមហាជនផងទាំងឡាយ ឯយើង

ឯគេនោះឲ្យសព្វគ្រប់ ចូរព្រះស្តែងបោះឲ្យជាដើម គឺទំចំណីត្រីសាច់ផង
ទាំងឡាយ ឮដឹមនុស្សនៃស្តេចចុលនីព្រហ្មទត្តរាជទាំងឡាយ ព្រះស្តែង
អាចឲ្យដោយផ្គាប់ចិត្តមនុស្សនោះ ហើយព្រះស្តែងថា អម្ភោ ម្នាលអ្នក
ទាំងឡាយអើយ! ចូរធ្វើចំណីត្រីសាច់នេះ កុំបីមុឹងមិនស្រណុកចិត្តឡើយ
ព្រះស្តែងចូរពិព្យាយាមដើម្បីនៅបានពីរ-បីថ្ងៃវិញទៀត រីឯមនុស្សផង
ទាំងឡាយ នៅក្នុងនគរនេះ នោះវាមិនស្រណុកចិត្តវា ឧបមាបីដូចមាន់
គេគ្របទុកក្នុងអគ្រុតប្រាកដ វានឹងនៅមិនយូរលង់ឡើយ ស្អែកហើយវា
នឹងបើកទ្វារចេញឲ្យអ្នកទាំងឡាយហោង ចូរព្រះស្តែងថាដូច្នេះ ហើយ
លំដាប់ពីនោះទៅ អ្នកទាំងឡាយចូរចាប់ស្តេចវិទេហរាជ ទំងំមហោសថ
ជាកូនគហបតីកំណាច ព្រះស្តែងទំងំខ្លាចអ្វី ឯមនុស្សទាំងឡាយនៃយើង
នោះ វាឮពាក្យព្រះស្តែងបង្កើតដេរតំរាមឲ្យយល់ស្តេចចុលនីព្រហ្មទត្តរាជ
ព្រះស្តែងធ្វើដូចគេវាយឮដំដើងដៃនៃអាចារ្យដាក់ចុះអំពីក្បាលបន្ទាយ ចង
សក់ជាប្រាំអន្ទើធ្វើឲ្យចុះដោយនូវលំអិតឥដ្ឋ ព្រះស្តែងរំសាយមាលាសន្ធ៌ា
រក ដែលពាក់នាកនោះ រីខ្លួនព្រះស្តែងនោះ យកបន្ទាខ្សែរូត ឲ្យយល់
ដូចគេវាយពីរ-បី ដង ឲ្យស្តេចថា ខ្សែព្រះស្តែងយកមកដោយនូវពួរដំ
ទុកនឹងសង្រែក ឲ្យគេដាក់ព្រះស្តែងចុះអំពីលើភាគបន្ទាយនោះ ព្រះស្តែង
ទៅធ្វើស្រដីបំបែក ទឹងចំណីមនុស្សនៃស្តេចចុលនីព្រហ្មទត្តរាជសំដែងឲ្យ

យល់ព្រះស្តេចឯង គេនឹងនាំព្រះស្តេចទៅសំណាក់ថ្វាយស្តេច រីស្តេច
ចុលនីសោត យល់ព្រះស្តេចហើយ គេនឹងដណ្តឹងព្រះស្តេចថា រីទោស
ខុសកំហុសតើដូចម្តេច? លំដាប់នោះព្រះស្តេចនឹងទូលប្រាប់ស្តេចចុលនី
នូវពាក្យថាដូច្នេះ មហារាជ បពិត្រមហារាជអើយ! រីសក្តិយសអញខ្ញុំ
កាលមុនឡើយជាធំ មហោសថជាកូនគហបតី សិរីវឌ្ឍកសេដ្ឋី ដោយ
ជាអ្នកកំណាញ់យសនោះមិញ គេខឹងនឹងអញខ្ញុំក្តាត់ គេកំចាត់អញខ្ញុំ
ចេញអំពីយស ហើយគេទៅទូលប្រាប់ស្តេចវិទេហរាជ ឲ្យបំបរបង់អញ
ខ្ញុំ ហើយគេរឹបយកអស់ទ្រព្យសម្បត្តិអញខ្ញុំអស់ហោង ព្រះស្តេចទូល
ប្រាប់ស្តេចចុលនីថា អំពីថ្ងៃនេះទៅ បូរអម្ចាស់នឹងឲ្យគេចាប់ក្បាលមហោ
សថចោរកំណាចជាកូនគហបតី សិរីវឌ្ឍកសេដ្ឋី ជាស្នងសក្តិយសអញ
ខ្ញុំវិញហោង ហេតុនោះហោង អញខ្ញុំយល់ឃើញមនុស្សទាំងឡាយនៃ
អម្ចាស់ គេគិតខ្លាចអំណាចមហោសថ គេមិនក្រសាលសប្បាយឡើយ
អញខ្ញុំឲ្យចំណីភោជនាហារមនុស្សទាំងអម្បាលនោះ ដ៏ស្មើដោយអំពើតែ
អម្បាលនោះហោង រីមហោសថគេធ្វើចិត្តនឹងអញខ្ញុំ ដូចនឹងជាពៀរពី
បុរាណ មហោសថធ្វើឲ្យចុះលុះកំចាត់អញខ្ញុំចេញអំពីយសសម្បត្តិ ឲ្យ
វិនាសបាត់ដូច្នេះឯង ព្រះស្តេចទូលថា មហារាជ បពិត្រមហារាជ
អើយ! អស់មនុស្សផងទាំងឡាយឯអម្ចាស់នេះ គេនឹងបានដឹងជាង ព្រះ
ស្តេចធ្វើឲ្យស្តេច នូវមនុស្សទាំងឡាយជឿដោយនូវប្រការនោះផង ។

គេនឹងបង្កើតជាស្រឡាញ់ស្និទ្ធស្នាល ព្រះស្តែងទូលថា មហារាជបពិត្រមហារាជអើយ! អម្ចាស់ ចាប់ដើមពីបាទអញខ្ញុំមកនៅហើយនោះ កុំបីអម្ចាស់អ្នកបារម្ភឡើយ ព្រះស្តែងទូលថា បពិត្រអើយ! ឥឡូវនេះ ជីវិតស្តេចវិទេហរាជក្តី នូវចៅមហោសថបុត្រគហបតីក្តី សមនឹងគ្មាន ព្រះស្តែងទូលថា នាបន្ទាយនគរនេះ ពោះស្ថានណាខ្ជាប់ក្តី ស្ថានណាចាស់បាក់បែកក្តី ទំនើបនាគូមានក្រពើសាហាវក្តី ស្ថានណាគ្មានក្តី ក៏អញខ្ញុំសឹងដឹងអស់ហោង ចូរព្រះស្តែងបាសំដែងថា បពិត្រអើយ! អញខ្ញុំយកនគរនោះនឹងឲ្យមហារាជមិនលង់ឡើយ លំដាប់នោះ ស្តេចទ្រង់ជឿព្រះស្តែង ហើយស្តេចទ្រង់រណ្តាប់សក្ការៈឲ្យព្រះស្តែងនោះច្រើនហោង ឰដ៏កាលនោះ នាស្តេចទ្រង់រណ្តាប់សេនាពាហនៈឲ្យនៅជុំនេះ ព្រះស្តែងនោះរណ្តាប់នូវពពួកសេនាយោធាជុំនេះ សេនាយោធាទាំងឡាយនៃស្តេចចុលនីក្តី ព្រះស្តែងនាំមកឲ្យជូនត្រង់ឋានណាមានក្រពើកាចសាហាវ រីសេនាយោធានៃស្តេចចុលនីនោះ ដោយខ្លាចក្រពើ ពុំអាចនឹងឆ្លងបានឡើយ ឰដ៏កាលនោះ ព្រះស្តែងទូលថា ទេវ បពិត្រអើយ! ក្រពើកាចសាហាវ សេនាយោធាស្តេចចុលនីអម្ចាស់នោះ គឺចៅមហោសថជាកូនគហបតីគេឲ្យរង្គាន់ រីអម្ចាស់កុំទុកចិត្តអស់មនុស្សស្តេចទាំងអម្បាលនេះ នឹងអាចារ្យកេវដ្តព្រាហ្មណ៍នេះឡើយ នាយករង្គាន់ចៅមហោសថនោះ មិនប៉ុន្មាក់ឡើយ នាអស់បរិវារអម្ចាស់នេះ ទាំង

អស់ហោង រីអស់អ្នកទាំងអម្បាលនេះ គេសឹងទៅសំណាក់ចៅមហោសថបុត្រគហបតីសិរីវឌ្ឍកសេដ្ឋីអស់ហើយ មានប៉ុន្តែអញខ្ញុំម្នាក់ឯង ជាបុរសអាមាត្យស្លូតនឹងអម្ចាស់មែនពិតហោង ព្រះស្តេចទូលថា បពិត្រអើយ ! ពោះយោបីអម្ចាស់មិនជឿនៃអញខ្ញុំ ចូរអម្ចាស់អ្នកប្រើហៅអស់ស្តេចទាំងអម្បាលនោះមក អម្ចាស់មើលគ្រឿងប្រដាប់ដោយពាក្យអញខ្ញុំហោង លំដាប់ពីនោះទៅ ចៅមហោសថអ្នកឲ្យសរសេរនាមឈ្មោះអាត្មានៅនាគ្រឿងជង្ហាយក្តី នៅនាសំពត់នូវគ្រឿងប្រដាប់មានទំនើប នូវគ្រឿងព្រះខាន់ក្តី ទំនើបអក្សរទាំងអម្បាលនោះ យល់ប្រាកដឡើងនៃស្តេចទាំងឡាយនោះ ពោធិសត្វអ្នកផ្តាំថា ព្រះស្តេចចូរទៅគាស់អក្សរនេះឡើងហោង រីអាចារ្យអនុកេវដ្ដ ក៏ធ្វើដូចបង្គាប់ពោធិសត្វនោះ ហើយធ្វើគាស់អក្សរនោះយល់អក្សរនោះយល់ប្រាកដឡើងក្តី អស់ស្តេចទាំងឡាយនោះភិតភ្វាច នឹងឲ្យស្តេចទាំងឡាយវិលទៅ ស្តេចទីងដណ្តឹងព្រះស្តេចថា ហៃអ្នកប្រាជ្ញអើយ ! យើងនឹងធ្វើម្តេច ឥឡូវនេះ ? ព្រះស្តេចឯងចូរទូលស្តេចនោះនូវពាក្យថាដូច្នេះ មហារាជ បពិត្រមហារាជអើយ ! រីចៅមហោសថបុត្រគហបតី គេបេះស្រដីកុហកមាយានោះច្រើន ពោះយោបីអម្ចាស់អ្នកទំនៅបានតែពីរ-បីថ្ងៃវិញទៀតហើយ រីចៅមហោសថគេនឹងចាប់អ្នកធ្វើទុក អស់សេនាយោធាអម្ចាស់ច្បាស់ឲ្យលង្វែកយាមអធ្រាត្រ ចូរអម្ចាស់អ្នកឡើងលើខ្នងសេះកាន់ខ្ញាប់ក្នុងកណ្តាប់ដៃនៃអាត្មា

គេហោង កុំបីអម្ចាស់ថ្រៃហសម្តេចផ្សងបន្ទន់ឲ្យយូរលន់ឡើយ ថ្ងៃ នេះ ថ្ងៃស្អែក នាលថ្ងៃកយាមអធ្រាត្រ ចូរអម្ចាស់អ្នកឡើងលើខ្នងសេះ យើងបររត់ទៅហោង ព្រះស្តេចទូលថា ធម្មតាហៅជាអ្នកប្រាជ្ញ កុំបី អាចឲ្យស្លាប់នឹងកណ្តាប់ដៃសត្រូវឡើយ ព្រះស្តេចថាដូច្នោះហើយ រី ស្តេចនោះស្តាប់ពាក្យព្រះស្តេចហើយ ស្តេចនឹងធ្វើដូចព្រះស្តេចថានោះ ហោង រីស្តេចចូលទីព្រហ្មទត្តរាជ ពេលានឹងនារត់ហើយ ព្រះស្តេច នឹងក្រឡាប់វិលមក រីមនុស្សនៃយើង ចូរព្រះស្តេចមកថាឲ្យគេដឹងផង ហោង ។

តំ សុត្វា អនុកេវដ្ដព្រាហ្មណោ សាធុ បណ្ឌិត ការិស្សាមិ តេ វចនន្តិ អាហ ។ រីអាចារ្យអនុកេវដ្ដព្រាហ្មណ៍ ស្តាប់ពាក្យពោធិសត្វហើយថា ឱ្យអ្នកប្រាជ្ញអើយ! សាធុ ពីរោះពេក ហោង អញនឹងធ្វើដោយនូវពាក្យអ្នកហោង ។ ពោធិសត្វអ្នកថា គួរ ហោង ពោះយោបីដូច្នោះ ចូរព្រះស្តេចអត់ឲ្យគេវាយបាទតីរ.បីផងហើយ សន្សំព្រះស្តេចទៅហោង ។ អាចារ្យអនុកេវដ្ដព្រាហ្មណ៍ថា ឱហៅ អ្នកប្រាជ្ញអើយ! វៀរប៉ុន្តែជីវិតអញកុំឲ្យស្លាប់ នឹងដើងដៃអញកុំឲ្យបាក់ បែក សំណល់អំពីនោះចូរអ្នកធ្វើដោយសម្មាចំណង់ចិត្តអ្នកហោង ។

សោ តស្ស គេហេ មនុស្សានំ សញ្ញាំ កត្វា . . . .

រីពោធិសត្វអ្នកឲ្យធ្វើណោប់លែងនៃមនុស្សទាំងឡាយ នាថ្ងៃអាចារ្យអនុកេវដ្ឋព្រាហ្មណ៍ រីមនុស្សផងបញ្ចុះទូវពួកជាក់សំយុងទូវអាចារ្យអនុកេវដ្ឋព្រាហ្មណ៍ ឲ្យជាវិប្បការដូចដំណើរនិយាយដែលពោធិសត្វផ្តាំហោង អជ គេ ព្រហ្មទត្តមនុស្សេ ត្វំ គហេត្វា ឆេត្វា ព្រហ្មទត្តស្ស ធស្សេសុំ ។ លំដាប់នោះ អាចារ្យអនុកេវដ្ឋព្រាហ្មណ៍ រីមនុស្សនៃស្តេចចុលនីព្រហ្មទត្តរាជនោះ គេយល់អាចារ្យអនុកេវដ្ឋព្រាហ្មណ៍នោះ គេនាំទៅថ្វាយស្តេចចុលនី រីស្តេចចុលនីព្រហ្មទត្ត ស្តេចឲ្យស្រាយលែងអាចារ្យអនុកេវដ្ឋព្រាហ្មណ៍ស្រេចហើយ ស្តេចឲ្យដណ្តឹងសួរ ទទួលដូចពាក្យយើងបានស្រដីពោលហើយនោះហោង ។ ស្តេចចុលនីព្រហ្មទត្តស្តាប់ហើយជឿ ស្តេចបង្គើររង្វាន់ឲ្យ ហើយបង្គើរសេនាយោធាទាំងឡាយ ឲ្យអាចារ្យអនុកេវដ្ឋព្រាហ្មណ៍ នាំសេនាយោធាទៅឲ្យចួងត្រង់ស្ពានមានក្រពើសាហាវ ។ រីក្រពើសាហាវនោះ ក៏ខាំមនុស្សផងដែលបិតនៅលើល្ហ តែងចាក់ខាងបណ្តោយទឹងសារលំពែងទូវស្នានោះ ឲ្យលុះវិនាសហោង ។ ម្ល៉ោះហើយ ចាប់ដើមអំពីនោះទៅ សឹងខ្លាចទឹងមានអ្នកឯណាមួយ ពុំអាចនឹងចូលទៅបានឡើយ ។ លំដាប់នោះ អាចារ្យអនុកេវដ្ឋព្រាហ្មណ៍ ចូលទៅទូលស្តេចថា ទេវ បពិត្រអើយ ! រីអស់ស្តេចទាំងអម្បាលនោះ នាថ់ហៅនឹងច្បាំងយកអាសាអម្ចាស់នោះគ្មានឡើយ រីអស់ស្តេចទាំងអម្បាលនោះ សឹងយករង្វាន់គេហើយ អាចារ្យ

អនុកេវដ្តព្រាហ្មណ៍ថា ពោះយោបីអម្ចាស់មិនជឿ អម្ចាស់ឲ្យហៅវិលមក ហើយ អម្ចាស់មើលមើលអក្សរទំនើប គឺសំបុត្រស្ដេចផ្ញើដូចពាក្យអាចារ្យ អនុកេវដ្តព្រាហ្មណ៍ថានោះហោង ។ ស្ដេចយល់អក្សរទំនើបនាសំបុត្រ អស់ស្ដេចតាំងនោះទើបបន្ទូលថា ស្ដេចតាំងអម្បាលនោះ សឹងយកស្នាទ គេហើយ គេធ្វើសឹងបញ្ចុះក្រឹត្យាគេអស់ហើយ ស្ដេចបន្ទូលដណ្ដឹងអា. ចារ្យអនុកេវដ្តព្រាហ្មណ៍ហើយថា: ឱហអាចារ្យអើយ ! ឥឡូវនេះហ្ម គប្បីនឹងធ្វើម្ដេច ? អាចារ្យអនុកេវដ្តព្រាហ្មណ៍ថា ទេវ បពិត្រអើយ ! អំពើគប្បីធ្វើវិញទៀតនោះគ្មានឡើយ ពោះយោបីអម្ចាស់ណ្ដាប់ឲ្យយូរ លង់ពេកនោះ ទៅមហោសថគេនឹងចាប់អ្នកហោង សូម្បីអាចារ្យកេវដ្ត- ព្រាហ្មណ៍ទៅធ្វើធម្មយុទ្ធនឹងអស់ស្ដេចតាំងពួងនោះ ទៅមហោសថគេធ្វើ ឲ្យលោករលាកថ្វស សូម្បីស្ដេចតាំងអម្បាលនោះ សឹងយកស្នាទគេ ហើយ រីអាចារ្យកេវដ្តព្រាហ្មណ៍នេះយល់មណីរតន៍ហើយ អម្ចាស់សោត រត់ទៅចម្ងាយ ៣ យោជន៍ហើយ អាចារ្យកេវដ្តព្រាហ្មណ៍ធ្វើឲ្យអម្ចាស់ ជឿ ឲ្យអ្នកត្រឡប់វិលមក ហើយអាចារ្យកេវដ្តព្រាហ្មណ៍នឹងលុកទំ. លាយជាមួយនឹងទៅមហោសថ រីអម្ចាស់សោតសូម្បីអ្នកនឹងនៅឲ្យអស់ រាត្រីមួយនោះមិនចូលចិត្តអញខ្ទុះឡើយ អាចារ្យអនុកេវដ្តព្រាហ្មណ៍ទូលថា នាថ្ងៃនេះឯង លុះដល់លង្វែកយាមអឌ្ឍរាត្រនោះ គួរយើងនឹងរត់ទៅហោង អាចារ្យអនុកេវដ្តព្រាហ្មណ៍ទូលថា បពិត្រអម្ចាស់អើយ ថាបើអម្ចាស់វៀរ

លែងពាក្យអញខ្ញុំហើយ នឹងមានអ្នកដទៃឯណាមួយ នាប់ហៅសួគនឹង
អ្នកនោះគ្មានឡើយ ស្តេចបន្ទូលថា អាចារ្យ ហៃអាចារ្យអើយ ! បើ
ដូច្នោះហើយ ចូរព្រះស្តែងធ្វើកាត់ យានជំនិះនេះ ចង់សេះនៃអញ
ហោង ។

ព្រាហ្មណោ តស្ស និច្ចយេន បលាយនកាំ
ញត្វា មា កាយិ មហាភជាតិ តំ អស្សាសេត្វា ....
អាចារ្យអនុកេវដ្តព្រាហ្មណ៍ ដឹងជាស្តេចចុលនីសុភាពនឹងរត់ហើយមិន
លង់ឡើយក្តី អាចារ្យអនុកេវដ្តព្រាហ្មណ៍ធ្វើជាលោមស្តេចនោះ ហើយ
ចេញទៅក្រៅថា ឲ្យដឹងនឹងមនុស្សតាំងឡាយជាខបទិក្កិត ហើយឲ្យផ-
ប្តូនាទថាដូច្នេះ ត្រូវម្ល ហៃព្រះស្តែងអើយ ! ថ្ងៃនេះ ស្តេចនឹងរត់ទៅ
ហើយ កុំបីព្រះស្តែងដេកឡើយ ស្តេចនឹងរត់ហើយ អញនឹងឈ្វៀស
សេះស្តេច អញនឹងដឹកយកសេះប្រសើរស្តេចនោះចេញ អញនឹង
ចង់គ្រឿងសេះមិនគួរបីនឹងចង់នោះ លុះដល់លង្វែកនាយាមអគ្រាត្រ
អាចារ្យអនុកេវដ្តព្រាហ្មណ៍ នាំមកនាសេះនោះហើយទូលថា បពិត្រ
អើយ ! អញខ្ញុំចង់ហើយសេះនោះ អម្ចាស់ចូរដឹងហោង វេលានា
នឹងរត់នោះ ចូរអម្ចាស់ឡើងគង់លើសេះរត់ហោង ។ សូម្បីអាចារ្យ
អនុកេវដ្តព្រាហ្មណ៍ ឡើងជិះសេះ ធ្វើហាក់ដូចនឹងទៅមួយអន្លើនឹងស្តេច
នាំទៅបន្តិចត្រឡប់វិលមកវិញ ។ អាចារ្យអនុកេវដ្តព្រាហ្មណ៍ ចង់

គ្រឿងមិនគួរបើចឹងនោះ នាំស្តេចរត់ទៅហោង ៗ អាចារ្យអនុកេវដ្ដ-ព្រាហ្មណ៍ យកសេះនោះដឹកចូលទៅក្នុងលង្វែក សេនាយោធាទាំងឡាយស្រែកបន្ទឺស័ព្ទឡើងថា រីស្តេចចុលនីមិញរត់ហើយ ៗ ស្រែកទៅមួយអន្ទើនូវមនុស្សទាំងឡាយ នឹងបុរស ៨ ខបទិក្កតអាក្នាឯងនោះ ក៏ស្រែកហៅកងរំពងឡើងថាព្រមជាមួយគ្នាហោង ៗ រីស្តេចសំណល់លែងនោះ ឮស័ព្ទអាចារ្យអនុកេវដ្ដព្រាហ្មណ៍នោះថា ហៅមហោសថអ្នកប្រាជ្ញគាត់បើកទ្វារមកហើយ ម្នោះហើយអស់អ្នកទាំងឡាយថាឥឡូវនេះ ហៅមហោសថបន្ទឺស័ព្ទគាត់មិនឱ្យយើងរស់ជីវិតឡើយ អស់ស្តេចទាំងឡាយ គិតខ្លាចមិនអាចនឹងរមិលមើលក្រោយឡើយ ហើយទ្រព្យគាត់គប្បីបរិភោគ មិនគួរបីបរិភោគនោះ គាត់រត់ទៅបោះអំពីទ្រព្យនោះ ៗ មនុស្សទាំងឡាយក៏ស្រែកនូវស័ព្ទនោះច្រើនថា សូម្បីតែស្តេចក៏រត់ហើយ ៗ សេនាយោធាទាំងឡាយ ដែលឋិតនៅនាទ្វារបន្ទាយល្អផង ឮស័ព្ទមនុស្សទាំងឡាយនោះស្រែកឡើងហៅ ខ្វះខះដៃទីទៃ ៗ អឹងកងអឹងកាប់ ស័ព្ទនោះរលំរលល់ទៅហោង ៗ ឥតិ តស្មឹ ខណេ បថវី ភិជ្ជមានា វិយ សមុទ្ទោ វិយ សំខុភិតោ សកលនគរំ អន្តោ ច ពហិ ច ឯក-និន្នាទមហោសិ ៗ ឮដំក្សណនោះ រីស័ព្ទនោះ ហាក់ដូច

---

នឹងធ្លាយទ្រូងមហាប្រថពី ឮដូចរលកមហាសមុទ្រពួដំផ្ទៃក្រោម រីអស់អ្នក

នៅក្នុងនគរនោះក្តី អ្នកនៅឯក្រៅនគរនោះក្តី សឹងបញ្ចេញស័ព្ទនោះអឺងកងជាមួយទៅហោង ។ សឹងថាដូច្នេះ ការ ដូចយើងព្រមក រវៅមហោសថអ្នកប្រាជ្ញ គាត់អាចចាប់ស្តេចចុលនីព្រហ្មទត្តផង នូវស្តេចមួយរយនឹងមួយ នឹងមនុស្សទាំងឡាយជាពល ១៨ អក្ខោភិនី សឹងភិតភ័យនានឹងស្លាប់ ឥតបាននានឹងតាំងអាត្មាពុំបានឡើយ ហើយលះបង់នូវទ្រព្យផង នៅគង់តែសំពត់មួយចង្កេះរត់ទៅ ។ ទាហានទ័ពនោះស្ងាត់ជ្រងំទទេហោង ។ រីស្តេចចុលនីយកអស់ស្តេចមួយរយនឹងមួយទៅកាន់នគរអាត្មាឯងហោង ។ បុនទិវសេ បាតោវ ទ្វារានិ វិវរិត្វា ពលនិកាយា នគរា និក្ខមិត្វា មហាវិលោបំ ទិស្វា កឹ ករោម បណ្ឌិតាតិ មហាសត្តស្ស អារោ-ចយិំសុ ។ លុះព្រឹកឡើង នាកាលថ្ងៃនោះ អស់ពលសកលយោធាទាំងឡាយ នៃព្រះមហោសថ បើកទ្វារពលចេញទៅអំពីព្រះនគរ យល់សម្បត្តិស្តេចចុលនីគេរត់ចោលច្រើនហើយ ក៏ទៅប្រាប់ព្រះមហាសត្វថា បណ្ឌិត ហៃអ្នកប្រាជ្ញអើយ ! តើយើងធ្វើម្តេច? ។ រីពោធិសត្វថា នាស្តេចទាំងអម្បាលនោះ បោះបង់ម្សៀតទ្រព្យនោះហើយ បានយើងហោង, សត្តូហិ ភដ្ឋំ សន្តកំ រញ្ញោ ធនំ . . . សូម្បីអស់ទ្រព្យស្តេចទាំងឡាយនោះ ចូរអ្នកទាំងឡាយ

ថ្វាយស្ដេចយើង ទ្រព្យរបស់សេដ្ឋីទាំងឡាយក្ដី របស់អាចារ្យកេវដ្ដ-ព្រាហ្មណ៍ក្ដី សំណាក់បាននាយើងហោង ។ ពោធិសត្វថា ទ្រព្យសំ-ណល់លែងនោះ ឲ្យអ្នកនគរយកហោង ។ ពោធិសត្វអ្នកឲ្យជញ្ជូនយកទ្រព្យផង នូវរ័តន៍សឹងមានដំឡៃច្រើននោះ កន្លះខែទើបអស់ ។ រីទ្រព្យសំណល់លែងនោះ លោកឲ្យជញ្ជូនយកបួនខែទើបអស់ ។ រីព្រះមហាសត្វ ឲ្យរណ្ដាប់រង្វាន់ផងច្រើនដល់អាចារ្យអនុកេវដ្ដព្រាហ្មណ៍នោះហោង ។ តតោ បដ្ឋាយ កិរ មិថិលនគរកាសិតោ សហ-រញ្ញសុវណ្ណា ជាតា ។ មហាភោគជាតិ ជាតាតិ ។ កិរ ដូចយើងឮមក ចាប់ដើមអំពីនោះទៅ រីអ្នកនៅមិថិលានគរសោត កើតមានមាសប្រាក់ និងរតនាករផងសឹងមានដំឡៃនោះច្រើនហោង ។

សូម្បីស្ដេចចូឡនីព្រហ្មទត្តរាជ នៅនាឧត្តរបញ្ចាលនគរនោះ មួយអន្ទើ និងស្ដេចមួយរយនិងមួយ នៅកន្ទងមកមួយឆ្នាំ ។

(ធម្មយុទ្ធមង្គលកាណ្ឌំ និដ្ឋិតំ ។ នេះយើងនឹងស្រដំ-ណើរកណ្ឌ កាលព្រះមហោសថតធម្មយុទ្ធជាមង្គល ក៏ស្រេចដោយនូវប្រការទាំងអម្បាលនេះឯងហោង) ។

( នៅមានត )

ផ្នែកអក្សរសាស្ត្រ

# ដើមកំណើតព្យញ្ជនៈខ្មែរ

បើចង់ចម្លងពាក្យខ្លះក្នុងអត្ថបទនេះ ត្រូវសុំសេចក្តីអនុញ្ញាតិពីអ្នកនិពន្ធ

រៀបរៀងដោយ ឌ. គាម

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថួន
ឲ្យបានខ្ជាប់ខ្ជួន គង់វង់គត់មត់ ។
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។

ប.ព.

អក្សរសាស្ត្រខ្មែរ មានល្បីឈ្មោះហើយខ្មែរយើងយកអក្សរខ្មែរមកប្រើជាផ្លូវការជាង ២.០០០ ឆ្នាំមកហើយ , ដល់មកសម័យនេះទៀត ក្រសួងអប់រំជាតិបានបញ្ចូលសៀវភៅខ្មែរជាច្រើនទៅក្នុងកម្មវិធីសិក្សា ។

អាស្រ័យហេតុនេះ សាស្ត្រាចារ្យនិងនិស្សិតត្រូវតែខំស្រាវជ្រាវរកប្រវត្តិ និងលំនាំអក្សរដោយខ្លួនឯង ព្រោះក្បួនច្បាប់ជាអក្សរខ្មែរ មិនសូវមានបរិបូណ៌ ។

ខ្ញុំជាអ្នកស្រឡាញ់អក្សរសាស្ត្រមួយរូបដែរ ហើយជាអ្នកចង់ដឹងថា តើអក្សរខ្មែរ ដែលយើងប្រើនៅសព្វថ្ងៃនេះ ចូលមកប្រទេសកម្ពុជា នៅសម័យណា ។ សេចក្តីព្យាយាមរបស់ខ្ញុំក៏បានសម្រេចដូចបំណង ខ្ញុំបានអានវចនានុក្រមសំស្ក្រឹតអង់គ្លេសរបស់លោក មូនីយេរ មូនីយេរ វិល្យាម្ស

(Sir Monier Monier Willianns) ។ លោកនេះបានប្រៀបធៀបអក្សរក្រិកនិងទេវនាគរី ព្រមទាំងអក្សរបែបព្រាហ្មីទៀត ។ បែបអក្សរព្រាហ្មីដែលខ្ញុំយកមកជូនមើលពេលនេះ សូមលោកយកទៅប្រៀបធៀបនឹងសិលាចារឹកនៅកុហាន់ជ័យ ខែត្រកំពង់ចាម ។ ពិតមែនតែខ្ញុំមិនបានចម្លងព្យញ្ជនៈតួព្រាហ្មីមកជូនទាំងអស់ តែលោកអ្នកអានអាចពិនិត្យមើលព្យញ្ជនៈខ្លះ ។ ហើយយកមកប្រៀបអក្សរសម័យនោះបាន ដូចតទៅនេះ =

តែមុននឹងលោកអ្នកអាន យកអក្សរព្រាហ្មីទៅប្រៀបធៀបនឹងអក្សរសិលាចារឹកនៅហាន់ជ័យ សូមលោកអ្នកយល់ឲ្យច្បាស់នូវន័យថាព្រាហ្មីសិន ។ អក្សរព្រាហ្មី គឺជាអក្សរបុរាណទី ២ របស់ឥណ្ឌា ។ អក្សរនេះបានជាគេឲ្យឈ្មោះថាព្រាហ្មី ពីព្រោះពួកព្រាហ្មណ៍ឲ្យឈ្មោះ ហើយពួកព្រាហ្មណ៍ជឿថាអក្សរនេះព្រះព្រហ្មបង្កើត (. . . The second kind of ancient Indian script is called Brāhma or Brāhmī: . . . . given to it by the Brāhmans because as they assert, it was invented by their God Brahma . . . . . អក្សរបុរាណទី២របស់ឥណ្ឌា ហៅថាព្រាហ្ម ឬ ព្រាហ្មី. . . . ដែលពួកព្រាហ្មណ៍ឲ្យឈ្មោះ ពីព្រោះពួកព្រាហ្មណ៍ជឿថាព្រះព្រហ្មបង្កើតអក្សរនេះ)

# បែបព្យញ្ជនៈធៀបគ្នារវាងអក្សរក្រិកព្រាហ្មីនាគរី នឹង ខ្មែរ



មុននឹងប្រៀបធៀបអក្សរព្រាហ្មី ទៅនឹងអក្សរដែលមកប្រតិស្ឋាន នៅប្រទេសកម្ពុជាមុន ខ្ញុំសូមជូនបែបព្យញ្ជនៈនៅសម័យសិលាចារឹកហាន់ជ័យកំពង់ចាម នៅសតវត្សទី ៦ ។

តាមការស្រាវជ្រាវរបស់លោក ហ្សក ម៉ាស្ប៉េរ៉ូ (George Maspéro) ថាព្យញ្ជនៈដែលចាស់ជាងគេអស់ គឺនៅសិលាចារឹកហាន់ជ័យ ។ តែបើតាមការសង្កេតស្រាវជ្រាវរបស់អ្នកប្រាជ្ញខ្មែរវិញ ថាអក្សរចារឹកចាស់ជាងគេ គឺអក្សរចារឹកនៅរ៉ូកាញ់ ។

ការធៀបគ្នារវាងអក្សរខ្មែរបច្ចុប្បន្ន នឹងអក្សរនៅសិលាចារឹកហាន់ជ័យ



បែបព្យញ្ជនៈខាងលើនេះ នៅក្នុងវគ្គទី ២ សម័យសតវត្សទី ៦ របស់លោក ហ្សក ម៉ាស្ប៉េរ៉ូ មិនឃើញមានព្យញ្ជនៈ ឈ ទេ ។ វគ្គទី ៣ មិនឃើញមានព្យញ្ជនៈ ឡ និងវគ្គទី ៥ មិនមានព្យញ្ជនៈ ឃ ទេ ។

សូមលោកពិនិត្យមើលអក្សរបែបព្រាហ្មី និងបែបសិលាចារឹកឃាន់ជ័យមានលំនាំដូចគ្នាម្ដេចខ្លះ ដូច្នេះខ្ញុំសូមជូនសេចក្ដីសង្កេតដូចតទៅ :

១– អក្សរ គ សម័យសិលាចារឹកឃាន់ជ័យ ឃើញមានលំនាំដូចព្រាហ្មីមែន ។ ហើយអក្សរ គ ក្រិកក៏មានលំនាំដូចគ្នាដែរ ។

២– អក្សរ ឋ ព្រាហ្មីកងមូលហើយមានគូសវះកណ្ដាល ឯសម័យសិលាចារឹកឃាន់ជ័យ តួនេះ កងមូលទ្រវែងហើយមានគូសវះកណ្ដាល ដូចគ្នា តែចំណែកក្រិកគូសខ្វែងជើងក្អែកកណ្ដាល ។

៣– ព្យញ្ជនៈ ឃ នៃអក្សរព្រាហ្មីក្វាយ និងអក្សរខ្មែរមានលំនាំដូចគ្នាបេះបិទ សូម្បីតែព្រាហ្មីមិនទាន់ក្វាយ ក៏នៅមានលំនាំដូចគ្នាដែរ ។

៤– ព្យញ្ជនៈ ង សម័យព្រាហ្មីនិងសិលាចារឹកឃាន់ជ័យ ក៏ស្រដៀងគ្នាដែរ (ផ្ទាំងទី២) ។

៥– ព្យញ្ជនៈ រ រវាងឃាន់ជ័យ និងព្រាហ្មីក្វាយក៏មានលំនាំដូចគ្នាដែរ ។

ការប្រៀបដូចនេះទៅ ឃើញថាសម័យអក្សរនៅសិលាចារឹកឃាន់ជ័យ ដែលចូលមកប្រទេសកម្ពុជាមុន ពិតជាអក្សរសម័យព្រាហ្មីនៅប្រទេសឥណ្ឌាមែន ។

ស្រៈខ្លះសម័យសិលាចារឹកហាន់ជ័យ

១)- ស្រៈ អ៊ិ នៅសិលាចារឹកហាន់ជ័យ មានពីរបែប

ក)-  = មាសន្ទេរវិណាសហ

ខ)-  = យានំ សុវណ៌ារចិតំ

តាមការពិនិត្យទៅឃើញថាស្រៈ អ៊ិ សម័យជាមួយគ្នានោះ មិនដូចគ្នាទេ ។ លេខ ១ ក ស្រៈ អ៊ិ មានសណ្ឋានដូចជាជើងព្យញ្ជនៈ ប្រ (គ្រ-វាត់) លេខ ១ ខ ស្រៈ អ៊ិ មានសណ្ឋានដូចជានិគ្គហិត ។

នៅឧទាហរណ៍ ខ- ខាងលើនេះ (យានំ សុវណ៌ារចិតំ) លោកអ្នកអាចសង្កេតឃើញវណ្ណយុត្តិ (របាទ) នៅខាងលើព្យញ្ជនៈ ណា ដូចជាសំ-យោគសញ្ញា ។

២) ស្រៈ អ៊ី សូមពិនិត្យមើលនូវពាក្យទាំងនេះ

ក)  =បក្រោទធិៈបក្រាទ+អធិ

ខ)  = គាសិទ្ធីក្ខុតមិទំ=គ+អា-សិទ្ធីក្ខុតំ + តទំ

ស្រៈ អុ : ស្រៈ អុ និស្ស័យមានរបៀបប្រើដូចស្រៈ អុ យើងបច្ចុប្បន្ននេះដែរ ។

ឩ-  = បុត្រា

៤) ស្រះ អ្ញូ ទិស្ស័យមានរបៀបដូច្នេះ



មុទ្ទិកាញ្ចនវិទ្ទុំ = ម + ឩ ទ្ទិកាញ្ចនវិទ្ទុំ

៥) ស្រះ អ្អេ ទិស្ស័យនៅសម័យសិលាចារឹកហាន់ជ័យឃើញមាន

ដូចឃ្លៀងឃ្លាតបន្តិច តែកង់ស្រដៀងគ្នា (សូមសង្កេត)



ស្វាមិគោចើ គុរុស្តេយ



មគាគសិនបេតសិ = ម + អគាគសិ + ន + បេតសិ

ដោយពិនិត្យតាមពាក្យទាំងនេះ ឃើញថាស្រះ អ្អេ ឃ្លៀងឃ្លាតគ្នានៅ

ត្រង់កន្លែងដែលស្រះសណ្ឋិត

ក)- ស្រះ អ្អេ ស្ថិតនៅលើព្យញ្ជនៈ:

៥)- ស្រះ អ្អែ ស្ថិតនៅអែបព្យញ្ជនៈ (មានលំនាំដូចជាស្រះ អ្អែ បច្ចុប្បន្ន)

៦) ស្រះ អ្អ សុទ្ធ (សូមលោកពិនិត្យមើលស្រះ អ្អ សុទ្ធនេះតាមង ព្យញ្ជនៈព្រាហ្មី) មានសណ្ឋានដូចអក្សរព្រាហ្មី តែប្លែកគ្នាត្រង់ស្រះ អ្អ បែប សិលាចារឹកហាក់ដ៏យកងគ្រាប់ក់ឡើងជាងបែបអក្សរព្រាហ្មី

១.  = អង្គ

៧) ស្រះ អ្អៃ មានលំនាំដូចស្រះ អ្អិ (សូមអានលេខ ១ ក) តែជា ស្រះ អ្អៃ មានគ្រាប់មួយកន្ទុះ ។ សូមពិនិត្យឧទាហរណ៍



យស្យ យោធៃម្ភរាបិត› យស្យ យោធៃ ករាបិត

៨)- ស្រះ អ្អោ មានសណ្ឋានលំនាំពីរបែប សូមលោកពិនិត្យ មើលនូវឧទាហរណ៍លេខ ៥ ក, និងលេខ ៧ ។ ឧទាហរណ៍លេខ ៥ក ស្រះ អ្អោ មានសណ្ឋានលំនាំដូច ស្រះ អ្អោ ដែលប្រើសព្វថ្ងៃ ឯឧទា- ហរណ៍លេខ៧វិញ ស្រះ អ្អោ មានលំនាំដូចស្រះ អ្អ សៀម ។

*សូមជូនឧទាហរណ៍ អក្សរសិលាចារឹកនៅហាន់ជ័យមួយឃ្លាទុកជា*

*គោល :*

## អឌ្ឍ ចិត្រា មលឆត្រ មុទ្ធិកាញ្ចនរុទ្ទមិ
## យានំសុវណ៌រចិតំ ហេស្ដ្យ គូបរិភេណាម

អឌ្ឍ ចិត្រា មលឆត្រ    មុទ្ធិកាញ្ចនរុទ្ទមិ

យានំសុវណ៌រចិតំ    ហេស្ដ្យ គូបរិភេណាម

*ប្រែថា ឆត្រដែលពាសដោយសំពត់លាត ខាងក្នុងមានបាក់ ខាងលើ មានកំពូលមាស ភជរថធ្វើដោយមាស ហើយទឹងហ្វូងគោទឹងដ៏វិមាស ៗ*

## ពាក្យខ្មែរប្រែពីបរទេស

## ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ « ក »

(តមក)

---

Contraindre (v.t.) បង្ខំ ។

Contrainte (n.f.) ការបង្ខំ ។

Conseil communal ក្រុមប្រឹក្សាឃុំ ។

Conseil de famille ក្រុមប្រឹក្សាញាតិ (ព.ប្ប.) ។

— D —

Corriger (v.t.) កែ ។

Devoir de fidèlité de la femme mariée ករណីយបិច្ចស្មោះត្រង់ នៃស្ត្រីមានប្ដី (ពប្ប)។

Devoirs d'aide et de secours entre époux ករណីយកិច្ចជួយនិងទំនុកបំរុងរវាងស្វាមី-ភរិយា (ព.ប្ប.) ។

Devoirs d'assistance entre époux ករណីយកិច្ចសង្គ្រោះរវាងស្វាមី ភរិយា- (ព.ប្ប.) ។

Divorce (n.m.) ការលែងលះគ្នា (ព.ប្ប.) ។

Diviser l'étude du droit ចែកការសិក្សានៃនីតិសាស្ត្រ (ព.ប្ប) ។

Division de l'étude du droit ការចែកការសិក្សានៃនីតិសាស្ត្រ (ព.ប្ប.) ។

En droit commun នីតិសាស្ត្រសាមញ្ញ (ព.ប្ប.) ។

Dissoudre le mariage រំលាយអាពាហ៍ពិពាហ៍ (ព.ប្ប.) ។

| | | |
|---|---|---|
| Dissolution du mariage | ការរំលាយអាពាហ៍ពិពាហ៍ | (ពញ) ។ |

— E —

| | |
|---|---|
| Erreur (n.f,) | ការកាន់ច្រឡំ ។ |
| Erroné (adj.) | ដែលកាន់ច្រឡំ ។ |

— F —

| | | |
|---|---|---|
| Faible d'esprit | អ្នកសតិទន់ខ្សោយ | (ពញ) ។ |
| Faiblesse d'esprit | ភាពសតិទន់ខ្សោយ | (ពញ) ។ |
| Femme de 1er rang | ភរិយាទី ១ | (ពញ) ។ |
| Femme de 2è rang | ភរិយាទី ២ ។ ពញ ។ បុរសម្នាក់អាចមានភរិយាទី ២ ច្រើននាក់បាន ។ | |
| Femme infidèle | ស្ត្រីអស្វាមីភក្តិ | (ពញ) ។ |
| Fille impubère | នារីអវយបត្ត | (ពញ) ។ |
| Foyer conjugal | គ្រានសង្វាស | (ពញ ។ |

— G —

| | | |
|---|---|---|
| Garçon impubère | នរៈអវយបត្ត | (ពញ) ។ |
| Gaspiller (v.t.) | ខ្ជះខ្ជាយ ។ | |
| Gaspilleur (n.m.) | អ្នកខ្ជះខ្ជាយ ។ | |
| Gaspillage (n.m.) | ការខ្ជះខ្ជាយ ។ | |
| Gens du peuple | ប្រជារាស្ត្រ ។ | |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ចាំង - ខាត់ រៀបរៀង*

(តមក)

---

អតិឝី ធាតុ. ដេក ។

អតិឝីត នបុំ. រងាក្រៃលែង ។

អតិឝុទ្ធ គុ. ដែលសុទ្ធក្រៃលែង, ដែលសុទ្ធកន្លង ។

អតិឝុភ ធាតុ. ល្អក្រៃលែង ។

អតិឝូរ គុ. ដែលក្លៀវក្លាកន្លង ។

អតិឝេឞ បុំ. សេសក្រៃលែង ។

អតិឝោភន គុ. សោភ័នកន្លង, ដែលល្អកន្លង ។

អតិឝោភាករ គុ. ដែលធ្វើនូវសោភាកន្លង ។

អតិឝៅច ន.បុំ. សេចក្ដីបរិសុទ្ធកន្លង ។

អតិឝ្រម បុំ.កិរិយាអត់កម្លាំងក្រៃលែង ។

អតិឝ្រី ស្រី. សិរីក្រៃលែង, សិរីប្រសើរ ។

អតិឝ្លិឞ្ដ គុ. ដែលស្អិតជាប់ក្រៃលែង ។



(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៨

ឧកញ៉ាវិបុលរាជសេនា ជួ-កាង ប្រែរៀបរៀង

( តមក )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ

យូរ - អ៊ុន

ឯចូឆូលុះតទូកចម្បាំងរួចហើយ ក៏ចាត់ចែងទាហានចុះទូកចម្បាំងជាបីកង លើកធ្លងចេញទៅ បំរើដែលចេញទៅស៊ើបល្បាត ក៏នាំយកសេចក្តីមកប្រាប់ម៉ាឈៀវ ៗ ក៏ចាត់ចែងទាហានឲ្យចេញទៅពួនបង្កប់ស្កាត់តាមរយៈផ្លូវ លុះកងទ័ពចូឆូធ្លងដល់ត្រើយ ចូឆូនឹងទាហានមួយពាន់ក៏ឡើងគោក ហើយរៀបតាំងបន្ទាយនៅទីនោះ ម៉ាឈៀវក៏ចុះទូកចម្បាំងព័ទ្ធស្កាត់ពីក្រោយចូលទៅ ទាហានចូឆូទាំងអស់ដែលនៅមិនទាន់ធ្លងដល់ត្រើយក៏បែកខ្ចាត់ខ្ចាយអស់ ពួកដែលនៅលើគោកក៏រត់ចុះទូក ចូឆូមិនបានដឹងថាសត្រូវនឹងមកផ្លូវលើនឹងផ្លូវក្រោមប្រការម្តេច ក៏កាន់ក្របីលើកឡើងឃាត់ ប្រាថ្នានឹងយកចិត្តទាហានទាំងពួងថា កុំឲ្យភ្ញាក់ផ្អើល

ជ្រួលច្របល់អ្វី យើងនៅនេះហើយនឹងខ្លាចអ្វី ។

ម៉ាឈៀវឃើញចូចូអង្គុយបង្គាប់ ប្រើទាហានឲ្យផ្ចើមឆ្ងាយនៅមាត់ច្រាំង ក៏អែបទូកទៅខាងឡើងគោក ហើយជិះសេះដេញកាប់ពួកកងទ័ពចូចូ ទាហានទាំងនោះក៏រត់ប្រញាប់ប្រញាល់ស្រែកថាម៉ាឈៀវមកហើយ ខៅជូឃើញម៉ាឈៀវដេញកាប់ទាហានចូលមកជិត នៅប្រមាណ ៥០ ព្យាម (១០០ ម.) នឹងដល់ខ្លួន ចូចូ ក៏ភ័យស្លុតចិត្ត ស្ទុះចូលទៅពយកខ្លួនចូចូចុះទូក ដៃស្តាំកាន់កន្ទុយខ្លា ដៃឆ្វេងច្រានទូកចេញពីច្រាំង ទាហានទាំងពួងក៏ភ័យស្លុតទាំងអស់គ្នា រត់ចុះទៅតាប់តែមទូកចូចូ ហើយស្រែកថាមហាឧបកដជួយយកជីវិតខ្ញុំផង ។

ខៅជូឃើញម៉ាឈៀវស្ទុះជិតចូលមក កន្ត្រាក់ក្របីកាប់ពួកទាហាននោះ ខ្លះដាច់ដៃខ្លះដាច់ជើង ហើយថយទូកចេញពីច្រាំងទៅកណ្តាលស្ទឹង ឆ្ងាយប្រហែល ៣ ព្យាម (៦ម.) ទទួលម៉ាឈៀវស្ទុះមកដល់ច្រាំង ចូចូឃើញជួរហោះភ័យខ្លាំងណាស់ញ័រអស់ទាំងខ្លួន ស្ទុះទៅឱបខៅជូ ។ ក៏ស្រែកបើទូកទៅ ម៉ាឈៀវក៏ឲ្យយកធ្នូបាញ់ចម្រុះគម្រង់ទៅបីដូចគ្រាប់ភ្លៀង ខៅជូខ្លាចក្រែងព្រួញធ្នូទឹងត្រូវចូចូ ក៏យកកែបសេះគ្របលើខ្លួនចូចូ ហើយយកក្របីក្រវីការពារព្រួញធ្នូជុំខ្លួន បង្ខំឲ្យបើទូកតម្រង់ទៅស្រុកអ៊ុយឡាំ គណៈនោះចៅហ្វាយស្រុកអ៊ុយឡាំក៏ចេញមកទទួលចូចូឡើងទៅ ទទួលម៉ាឈៀវចុះទូកចម្បាំងតាមទៅដល់ស្រុកអ៊ុយឡាំ លើក

ទាហានឡៀងគោកនឹងចូលទៅក់យដណ្តើមយកខ្លួនចូឆូ  តេងហ៊ុយទៅ-ហ្កាយស្រុកអ៊ុយឡាំ ឃើញដូច្នោះក៏គិតថា  ទាហានម៉ាឈៀវលើកមកពីស្រុកសែលៀងក៏យូរណាស់ហើយ តង់នឹងអស់ស្បៀងអាហារជាប្រាកដ ចាំអញគិតឧបាយកល់ធ្វើឲ្យកងទ័ពម៉ាឈៀវរញ្ញាក ដើម្បីឲ្យចូឆូរត់រួច ទើបបើកទ្វារដេញហ្វូងគោក្របីឲ្យចេញពីស្រុកជាច្រើន  នោះទាហានម៉ា-ឈៀវក៏នាំគ្នាចាប់គោក្របីសម្លាប់ស៊ីជាអាហារ មិនបាននឹងគិតលើកតាមចូឆូទៅទៀត ។

ឯចូឆូលុះទៅដល់បន្ទាយអ៊ុយហោ  ឃើញដែកចុងព្រួញជាប់នឹងក្រោះខៅជូជាច្រើន ក៏និយាយថា គ្រានេះបើយើងកុំបានខៅជូ កាលណាឡើយនឹងគង់ជីវិតរស់រួចមកដល់ទីនេះ  ទាហានទាំងពួងឮចូឆូថាដូច្នោះ ក៏នាំគ្នាក្រាបចុះទៀបបាទដើងចូឆូ ។ ក៏សើចថា  យើងធ្វើសឹកគ្រានេះ មិនគួរនឹងចាញ់ប្រៀបអាចោរកូនក្មេងសោះ បើកុំតែបានខៅជូជួយកៃខ យើងក៏មិនរួចជីវិតរស់មកឡើយ ខៅជូឮដូច្នោះក៏ថា កាលខ្ញុំបាទនឹងលោកឡៀងគោកបាន  ហើយម៉ាឈៀវលើកទាហានតាមមក តេងហ៊ុយធ្វើកលឧបាយបើកលែងហ្វូងគោក្របី ឲ្យចេញទៅទល់នឹងទ័ពម៉ាឈៀវលើកតាមមិនទាន់ ។

ទទួលតេងហ៊ុយមកដល់ ចូឆូក៏និយាយនឹងតេងហ៊ុយថា អ្នកបានជួយរិះគិតកៃខ ដើម្បីឲ្យយើងរួចពីចំណោមទ័ពម៉ាឈៀវគ្រានេះ អ្នកក៏

មានឧបការៈ នឹងយើងច្រើនណាស់ ហើយក៏តាំងគេងហ៊ុយជាទីទៀនគុយ ហៅហ៊ុយ ប្រែថា នាម៉ឺនស្និទ្ធិសម្រាប់ប្រឹក្សាការរាជការ គេងហ៊ុយក៏ជម្រាបចូចូថា ឥឡូវម៉ាឈៀវមានចិត្តកំរើបលើកគ្រឡប់ទ័ពទៅវិញហើយ ព្រឹកនេះមុខជានឹងលើកទ័ពមកធ្វើការទៀត មហាឧបរាជត្រូវគិតធ្វើឧ-បាយកលទុកសងសឹកទៅវិញចុះ ។

ចូចូថា អ្នកកុំវិតក្កឡើយ ឯការគេងនោះយើងក៏បានរិះគិតទុកជាស្រេចហើយ ចូចូឱ្យប្រមូលទាហានជីកដីធ្វើស្នាមភ្លោះជុំវិញបន្ទាយ ក្រៅបន្ទាយឱ្យជីកជុំកៅ ២ ព្យាម ឱ្យដោតចំរូងក្នុងគូ លើមាត់គូឱ្យយកឈើមកកាយជារនូត ហើយឱ្យយកដីគ្របលុបមិនឱ្យឃើញស្នាម ប្រាថ្នានឹងបញ្ឆោតឱ្យទាហានម៉ាឈៀវធ្លាក់ចុះក្នុងគូនោះ ហើយឱ្យទាហានក្នុងបន្ទាយដោតទង់ត្រៀមគ្រឿងសាស្ត្រាវុធទុកឱ្យព្រម ។

កាលម៉ាឈៀវគ្រឡប់ទៅដល់បន្ទាយហើយ ក៏និយាយប្រាប់ហ៊ានស៊ុយថា ខ្ញុំបាទទៅធ្វើការគ្រានេះមានជ័យជំនះ ហៀបតែនឹងចាប់ខ្លួនចូចូបាន តែមានទាហានម្នាក់រូបរាងយ៉ាងស្វាហាប់ កាចពេយកខ្លួនចូចូចុះទូករត់រួចទៅបាន ហ៊ានស៊ុយថា ទាហានចូចូមានថ្វៃដៃខ្លាំងពូកែ ២ នាក់ គឺទៀនអ៊ុយនឹងខៅជូ ឥឡូវទៀនអ៊ុយស្លាប់ទៅហើយ ដែលដោះធុរៈចូចូគ្រានេះក៏គឺខៅជូនោះឯង ឯខៅជូនោះជាមនុស្សមានកម្លាំងនឹងថ្វៃដៃពូកែជាងទាហានទាំងពួង ប្រៀបបីដូចខ្លាសាហាវ បើទៅបានទៅប្រទះនឹង

រាតបាំងគ្នា កុំគប្បីធ្វេសប្រហែស ចូររាំងរក្សាខ្លួនឲ្យមាំមួន ម៉ាឈៀវថា ខៅថូម្នាក់នោះខ្ញុំបាទបានឮល្បីឈ្មោះមកយូរហើយ ទើបនឹងបានឃើញរូបក្នុងគ្រានេះ ។

ហ៊ានស៊ុយថា ឥឡូវចូចូរត់ឆ្លងត្រើយទៅនៅក្នុងបន្ទាយគុយហោហើយ ខ្ញុំគិតថានឹងលើកទ័ពទៅច្បាំងកុំឲ្យវាតាំងខ្លួនជាមុនបាន បើបង្អង់ឲ្យយូរឲ្យចូចូតាំងបន្ទាយជាមាំបានហើយ មុខជាយើងនឹងធ្វើការលំបាក ចៅនៅឯក្រោយចូររាំងរក្សាបន្ទាយ នឹងផ្លូវក្រោយឲ្យមាំមួន ខ្លាចចូចូនឹងលើកទាហានទ័ពមកកាត់ស្បៀងរបស់យើង ម៉ាឈៀវបានស្តាប់ដូច្នោះក៏យល់ឃើញត្រូវ ទើបឆ្លើយថា គំនិតដែលបិតាគិតនេះប្រពៃណាស់ នឹងលើកទៅក៏ទៅចុះ អំពីបន្ទាយនឹងផ្លូវខាងក្រោយនោះ ជាភ្នាក់ងារខ្ញុំបាទនឹងរក្សាការពារមិនឲ្យអន្តរាយ ប្រសិនបើចូចូនឹងលើកឆ្លងមកត្រើយខាងណោះ ខ្ញុំបាទនឹងលើកទាហានទៅស្កាត់កាំងមិនឲ្យវាឆ្លងមកបាន ហើយម៉ាឈៀវក៏ចាត់ឲ្យប៉ាំងតេក ឃុំទាហាន៥ម៉ឺនជាទ័ពមុខទៅជាមួយនឹងហ៊ានស៊ុយ ៗ ក៏លើកទ័ពឆ្លងទៅបន្ទាយគុយហោ ។

ចូចូដឹងថា កងទ័ពម៉ាឈៀវលើកមកដូច្នោះ ក៏ចាត់ឲ្យមនុស្សចាស់ៗចេញរក្សាស្នាមភ្លោះនៅក្រោយបន្ទាយ ហើយបង្គាប់ថា បើប្រសិនជាទាហានម៉ាឈៀវរុករានទន្ទ្រានចូលមក ក៏ឲ្យធ្វើជារត់បញ្ឆោតឲ្យដេញឆ្លងតួចូលមកឲ្យបាន ហើយបង្គាប់ទាហានឲ្យត្រៀបខ្លួននៅក្នុងបន្ទាយ ។

លុះហ័នស៊ិយលើកទ័ពទៅដល់ ប៉ាំងគេកឃើញទាហានបូច្ចូរក្សាបន្ទាយនោះស្តើងស្តួចណាស់ កំលើកទ័ពចូលទៅវាយ ទាហានដែលរក្សាស្នាមភ្លោះនៅនោះ កំធ្វើជាថយរត់ឲ្យដេញ ប៉ាំងគេកនឹងទាហានឃើញបានការ កំដេញសន្ធុ [illegible]លទៅធ្លាក់ចុះក្នុងគូ បូច្ចូឲ្យចោរអេងលើកទាហានចេញដេញកាប់សម្លាប់ទាហានប៉ាំងគេកស្លាប់ក្នុងគូ ប្រហែល ២០០ ថ្ងាយ ស្លាប់ទាំងទៀវហ្វ៊ី ថេនងិនជានាយទាហាន ឯខ្លួនប៉ាំងគេកពាក់ក្រោះដែកទើបមិនមានអន្តរាយ លោតឡើងលើមាត់គូបានឃើញចោរអេងជិះសេះកាន់លំពែង ប៉ាំងគេកកំស្ទុះតម្រង់ទៅយកដាវកាប់ចោរអេងធ្លាក់ពីលើសេះស្លាប់ ហើយកំលោតឡើងខ្នងសេះនាំហ័នស៊ិយនឹងទាហានទាំងពួងកាប់ទំលាយចេញពីក្នុងបំណោមទ័ពត្រឡប់ទៅបន្ទាយក្នុងគួនវិញ បូច្ចូកំលើកទ័ពដេញតាមទៅ ។

ឯម៉ាឈៀវចាំមើលផ្លូវហ័នស៊ិយឃើញយូរហួសកំណត់ ខ្លាចក្រែងហ័នស៊ិយចូស់ការកំលើកទាហានជូងទៅតាម លុះទៅដល់មាត់ស្ទឹងឃើញបូច្ចូដេញហ័នស៊ិយមក កំលើកទាហានចូលទៅជួយនាំយកខ្លួនហ័នស៊ិយនឹងប៉ាំងគេកចុះទូកឆ្លងមកបន្ទាយក្នុងគួន ម៉ាឈៀវនិយាយនឹងហ័នស៊ិយថាបូច្ចូមានប្រាជ្ញាជ្រៅទូលាយណាស់ បើនឹងស្ងៀមទុកឲ្យយូរទៅឃើញថានឹងធ្វើការលំបាក ត្រូវតែយើងលើកទាហានយ៉ាងប្រញាប់ទៅប្លន់

បន្ទាយបួច្ចឲ្យបានក្នុងពេលយប់នេះទើបត្រូវ ហ៊ានស៊ុយក៏យល់ផង ទើបរៀបចាត់ចែងទាហានឲ្យម៉ាឈៀវឃុំនាំទាហានជាទ័ពមុខ ប៉ាំងតេកនឹងម៉ាតាយជាខាងក្រោយ ខ្លួនហ៊ានស៊ុយឃុំទាហាន ៤ កងជាសាវត្រមើលខុសត្រូវ ស្រួតលើកខ្លួនទៅត្រើយនាយ តាំងកណ្ដាលថ្ងៃ លុះដល់ច្រាំងហើយក៏ឲ្យទាហានឡើងបង្កប់ពួនព្រមគ្នាទៅក្នុងព្រៃ ចាំដល់ពេលយប់នឹងលើកចូលទៅប្លន់បន្ទាយបួច្ច ។

ឯបួច្ចកាលបើមានជ័យជំនះលើហ៊ានស៊ុយហើយ ក៏លើកទ័ពត្រឡប់ទៅបន្ទាយ ហើយហៅទៅឃួមកបង្គាប់ថា ម៉ាឈៀវវាមកធ្វើអង់អាចហ៊ានច្បាំងនឹងយើងវេលានេះ ព្រោះវាមិនឲ្យយើងតាំងខ្លួនជាប់ ក្នុងថ្ងៃនេះវាចាញ់ប្រៀបយើងហើយ គង់វានឹងមានចិត្តឈឺក្ដៅ វិលមកប្លន់បន្ទាយយើងវិញក្នុងពេលយប់នេះមិនខាន ខ្លួនអ្នកឯងត្រូវចាត់ចែងទាហានចេញទៅពួនបង្កប់រាយគ្នាខាងក្រៅបន្ទាយ បើដល់ពេលយប់ហើយ ម៉ាឈៀវលើកមកប្លន់បន្ទាយ យើងត្រូវអុចផាវជាសញ្ញាឡើង ហើយឲ្យទាហានដែលបង្កប់នោះ ចេញមកព័ទ្ធខ្ទប់ប្រសប់គ្នាពីមុខពីក្រោយចូលមក គង់តែយើងនឹងមានជ័យជំនះចាប់យកខ្លួនម៉ាឈៀវឲ្យបានជាប្រាកដ ទៅឃួទទួលបង្គាប់ហើយ ក៏ចេញទៅចាត់ចែងការទុកព្រមតាមបួច្ចបង្គាប់នោះគ្រប់ប្រការ ។

លុះដល់ពេលយប់ក្នុងថ្ងៃនោះ   ម៉ាឈៀវក៏ចាត់ប្រើសេងនីនឹងទាហាន ៣ ពាន់លបចូលទៅល្បាតស៊ើបការឯបន្ទាយចូចូ តើនឹងត្រួតត្រៀមបំរុងការទុកដូចម្តេចខ្លះ   ឯម៉ាឈៀវនឹងប៉ាំងតេកក៏លើកទាហានទៅជាក្រោយនោះ   សេងនីនឹងទាហាន ៣ ពាន់   បានទៅដល់បន្ទាយចូចូហើយ   ក៏ឃើញស្ងាត់ច្រៀបមិនឃើញមានទាហានត្រៀមបំរុងការដូចធម្មតា   ក៏មានអំណរណាស់   ទើបនាំទាហានសេះ ៣០ ចុងស្ទាមក្តោះចូលទៅ   ចូចូឃើញដូច្នោះ ក៏ឲ្យអុជផាវជាសញ្ញាឡើង   នោះពួកទាហានដែលបង្កប់ក្រៅបន្ទាយក៏ស្រុះស្រូចេញមកពីក្នុងព្រៃជុំវិញបន្ទាយ   ហែហូអឿនក៏ឡើងសេះកាន់លំពែងចាក់សេងនីធ្លាក់ពីលើសេះស្លាប់   ហើយក៏ដេញកាប់ទាហានសេងនីបែកខ្ចាត់ខ្ចាយជាច្រួលច្របល់   ម៉ាឈៀវនឹងប៉ាំងតេកដែលលើកតាមទៅពីក្រោយដឹងដូច្នោះ   ក៏វាយញែកគ្នាជា ៣ កងតាំងតែកាប់ពុះពារទំលាយទាហានចូចូចូលទៅជួយគ្នា   នោះបណ្តាទាហានកងទ័ពទាំងសងខាងក៏ប្រឡូកកាប់ផាប់ដៃគ្នាទៅវិញទៅមក   ទាំងសងខាងក៏ស្មើកំឡាំងគ្នាហើយថយរកចូលបន្ទាយវិញ ។

ម៉ាឈៀវចាត់ទាហានឲ្យចេញទៅប្លន់បន្ទាយចូចូតែរាល់ថ្ងៃ   ចូចូក៏ចាត់ការត្រួតត្រាបន្ទាយដែលតាំងនៅក្បែរស្ទឹងអ៊ុយហោនោះមាំមួនណាស់ហើយឲ្យធ្វើស្ពានចងស្ទឹងនោះ   នឹងបានទៅមកជួយគ្នា   ដល់បន្ទាយហោយ៉ិន   ឯម៉ាឈៀវដឹងការដូច្នោះ   ក៏បង្គាប់ទាហានឲ្យមានគប់ភ្លើង

គ្រប់គ្នា ហេតុទៅដល់ទាហានហ៊ានស៊ុយ ហើយលើកចូលវាយបន្ទាយបូច្ឆ យកភ្លើងដុតបន្ទាយនោះឆេះគ្រប់ទិស កងទ័ពបូច្ឆតទល់ពុំឈ្នះ ក៏បែកបាក់ព្រាត់ព្រាយរត់ចេញអស់ពីក្នុងបន្ទាយទៅទិសផ្សេង ៗ ម៉ាឈៀវ ហ៊ានស៊ុយក៏ចាត់ទាហានឲ្យកធ្វើជាបន្ទាយយ៉ាងមាំ គ្រង់ទីបន្ទាយចាស់បូច្ឆនោះ បូច្ឆបែកទ័ពថយទៅពីនោះចម្ងាយប្រហែល ៨០ ស៊ិន (២ គី) ឃើញម៉ាឈៀវឲ្យតាំងបន្ទាយគ្រង់ទីចាស់របស់ខ្លួនដូច្នោះ លុះនឹងតាំងបន្ទាយទទួលវិញក៏មិនទាន់ការ ទើបឲ្យទាហានដឹកដីយកមកបូកជាប់គ្នាជាជុំៗ ហើយរៀបឡើងជាស្នាមភ្លោះនៅក្នុងទីនោះ ៗ

មានបំរើសេះចូលទៅជំរាបម៉ាឈៀវថា បានឃើញបូច្ឆឲ្យរៀបធ្វើស្នាមភ្លោះ ម៉ាឈៀវបានឮដូច្នោះ ក៏យុំនាំទាហានទៅដល់មុខស្នាមភ្លោះបន្ទាយបូច្ឆៗដឹងដូច្នោះក៏ឡើងសេះចេញទៅឈរនៅមុខបន្ទាយជាមួយនឹងទៅជូ ហើយស្រែកប្រាប់ទៅទាហានម៉ាឈៀវថា ឲ្យប្រាប់នាយឯងថា យើងចេញមកចាំនៅទីនេះតែម្នាក់ឯងទេ ឲ្យម៉ាឈៀវចេញមក យើងនឹងចរចាផង ម៉ាឈៀវបានឮបូច្ឆស្រែកមកដូច្នោះ ក៏បរសេះចេញមកឈរនៅត្រង់មុខបូច្ឆៗក៏ស្រែកថា អ្នកឯងឃើញថ្វីដៃយើងឬទេ ? អ្នកឯងគិតថាដុតបន្ទាយយើងចេញ មុខជាកេបន្ទាយនៅទៀតគ្មានឬ? យើងគ្រាន់តែធ្វើមួយស្របក់ក៏កើតជាបន្ទាយបានដូចទេពតាមកនិម្មិតឲ្យ អ្នកឯងនឹងកស៊ូ

នោះ កាលណាទីងមានជ័យជំនះយើងបាន ត្រូវគំនាប់ចុះចាញ់ឲ្យហើយ ទៅវិញជាដាង ។

ម៉ាឈៀវឈ្មួលក្នុងចិត្តខ្លាំងណាស់ ក៏បរសេះសំរុកចូលទៅទីងចាប់យកខ្លួនបួឆ ទទួលក្រឡេកឃើញខៅជូកាន់លំពែងសំឡក់ក្អែកក្រឡោត នៅពីក្រោយបួឆ ក៏នឹកខ្លាចទាញសេះឈប់គិតថា ទាហាននេះហើយ ឬដែលឈ្មោះថាខៅជូនោះ ឮល្បីថាដៃខ្លាំងពូកែណាស់ឬក៏មិនមែនទេឬ? ទើបស្រែកសួរថា ទាហានខ្លាំងរបស់លោកឈ្មោះអ្វី នៅទីឯណាខ្លះ ខៅជូឮដូច្នោះក៏បរសេះចេញមកខាងមុខហើយស្រែកថា ខ្លួនយើងនេះហើយជាទាហានខ្លាំងឈ្មោះខៅជូ អ្នកឯងទីងចង់ធ្វើយើងយ៉ាងម៉េច ម៉ាឈៀវក្រឡេកឃើញរូបខៅជូមែបច្រូនធំអង់អាច គួរឲ្យញញើតខ្លាចមែន ក៏មិនបានតបថាប្រការម្តេច ទាញសេះត្រឡប់ចូលបន្ទាយ ។

(នៅមានត)

លោក ហ៊យ-ប៊ុត ប្រែរៀបរៀង

(តមក)

## ៣– រឿងជក់ទិព្វ

គេបាននិទានថា: តាំងតែពីអតីតកាលមក មានកុមារតូចម្នាក់ប្រកបដោយប្រាជ្ញាដ៏មោះមុត នាមថា: "ម៉ាលៀង" ។ កុមារនេះពេញចិត្តខាងគូរគំនូរហើយមានបំណងចង់ធ្វើជាជាងវិចិត្រសិល្បៈខាងគំនូរពណ៌ ។ បិតាមាតាទទួលមរណភាពតាំងពីកុមារនេះនៅជាទារក ។ ការកាប់អុសនិងការកាត់ស្មៅយកទៅលក់ធ្វើឲ្យកុមារនោះរស់កនមានជីវិតបាន តែមានសភាពក្រីក្រលំបាកពន់ពេកហើយពុំអាចរកប្រាក់មកទិញជក់បាននោះ ។

មាន១ថ្ងៃ ម៉ាលៀង បានដើរទៅមុខសាលារៀនមួយ ស្រាប់តែឃើញលោកគ្រូម្នាក់បានយកជក់គូរទិដ្ឋភាពដោយពណ៌ស្រស់ឆ្អៅ ៗ ជក់នោះបានប្រព្រឹត្តចុះឡើងលើផ្ទាំងសំពត់ ធ្វើឲ្យម៉ាលៀងពេញចិត្តពន់ពេក ទាល់តែទ្រាំពុំបានក៏ចូលទៅជិតលោកគ្រូហើយពោលពាក្យថា:

"លោកគ្រូ ខ្ញុំចង់រៀនខាងវិជ្ជាវិចិត្រសិល្បៈគំនូរពណ៌ ! សូមលោកគ្រូមេត្តាឲ្យជក់មកខ្ញុំបន្តិច" ។

លោកគ្រូក្រឡេកសំឡក់ដោយខឹងយោរយៅឥតប្រមាណ ហើយក៏ស្ដោះទឹកមាត់ដាក់មុខម៉ាលៀងរួចពោលថា :

នែអាប្រម៉ក់! ឯងក្រលំបាកតោកយ៉ាកយ៉ាងនេះ ឯងចង់រៀនវិចិត្រសិល្បៈគំនូរពណ៌? ឯងប្រហែលជាយល់សប្តិទេដឹង? រួចលោកគ្រូក៏ដេញក្មេងនោះចេញពីទីនោះទៅ ។

ម៉ាលៀងមានចំណង់ពេកក៏ពោលថា: "ម្តេចក៏ដូច្នោះ! ក្មេងតូចរៀនវិចិត្រសិល្បៈគំនូរពណ៌មិនបានទេឬ? យើងចាំមើលទៅថ្ងៃក្រោយ!" ។

តាំងពីថ្ងៃនោះមក ម៉ាលៀង ក៏ព្យាយាមរៀនវិជ្ជាដោយមានបំណងចង់ធ្វើជាជាងវិចិត្រសិល្បៈគំនូរពណ៌ថ្ងៃណាមួយឲ្យបាន ។ នៅពេលដែលវាទៅរើសអុសនៅភ្នំ វាយកមែកឈើគូសវាសលើដី នូវរូបបក្សាបក្សីហិចហើរពេញដំអាកាស ។ នៅពេលដែលទៅកាត់ស្មៅតាមមាត់ស្ទឹង វាយកចង្អុលដៃជ្រលក់ទឹកយកមកគូសទីងថ្មនូវមច្ឆា ដែលវាឃើញហែលក្នុងទឹកជ្រៅ ។ នៅជញ្ជាំងក្នុងរូងភ្នំដែលជាលំនៅរបស់វា ។ ព្យាយាមគូរវាសនូវរូប នូវគ្រឿងប្រដាប់ដណ្តាំបាយធ្វើម្ហូប ។ ជញ្ជាំងទាំងបួនសុទ្ធតែមានគំនូរគ្រប់បែបយ៉ាង ។

លុះជាច្រើនឆ្នាំតមក ម៉ាលៀងក៏បានព្យាយាមគូរវាសរាល់ថ្ងៃជានិរន្តរ ។ មែនពិត ម៉ាលៀង ក៏បានចម្រើនខាងវិជ្ជានេះជាអនេកប្បការ ។ វាគូរបក្សាបក្សី មច្ឆជាតិយ៉ាងល្អរស់រវើកដូចជាបក្សានោះចេះយំ មច្ឆាចេះ

ហែលក្នុងទឹកទៅតាមធម្មជាតិពិត ៗ ។ តែម៉ាលៀងមិនមានជក់សម្រាប់គូរទេ ហើយវាចង់បានជក់នោះមួយ តែមិនដឹងជាទីងធ្វើយ៉ាងណាឲ្យបាន។

ពេលសាយណ្ហសម័យមួយ ម៉ាលៀង ទទួលបានដំណេក ក្រោយដែលបានព្យាយាមសិក្សាវិជ្ជាគំនូរជាយ៉ាងម៉ាំមួនពេញមួយថ្ងៃ ។ ដល់វាលក់ស៊ុប ស្រាប់តែនិមិត្តឃើញតាចាស់ម្នាក់ មានពុកចង្កាសឈរពីមុខ ហើយឲ្យជក់មួយមកវា ។ តាចាស់នោះពោលថា: " នេះជាជក់ទិព្វមួយ ឯងយកទៅប្រើតាមសេចក្ដីប្រាថ្នាចុះ " ។

ម៉ាលៀងបានពិនិត្យមើលជក់ទិព្វនោះ គឺជាជក់មានដងលាបមាសភ្លឺចាំងហើយធ្ងន់ផង ។

ម៉ាលៀង មានចិត្តសោមនស្សឥតឧបមា ហើយស្រែកថា " ឱជក់ទិព្វនេះល្អណាស់ ខ្ញុំសូមអរគុណលោកតាហើយ . . . " ។

ម៉ាលៀង និយាយមិនទាន់ផុតពីមាត់ ស្រាប់តែតាចាស់នោះបាត់ពីទីនោះទៅ ។ ម៉ាលៀងនឹកងឿងឆ្ងល់ពន់ពេក . . . ភ្ញាក់ខ្លួនឡើងទើបដឹងថាខ្លួនយល់សប្ដ . . . តែម៉ាលៀងកាន់ជក់ទិព្វនឹងដៃ ហើយនឹកកាន់តែឆ្ងល់ ៗ ឡើង ។

ម៉ាលៀង បានយកជក់ទិព្វនោះគូរជាបក្សាមួយ ៗ បក្សានោះស្រាប់តែទទះស្លាបហើរទៅលើនភាល័យហើយយំយ៉ាងពិរោះអស្ចារ្យ ។ ដល់ក្រោយទៀត ម៉ាលៀងគូរត្រីមួយ ៗ ស្រាប់តែត្រីនោះបក់កន្ទុយហែល

ទៅតាមស្ទឹងធ្វើជាវង់មូលច្រើនលើក.គ្រា ។ ម៉ាលៀង ឃើញដូច្នោះ ត្រេកអរពន់ប្រមាណ ។

ម៉ាលៀង បានយកជក់ទិព្វនោះ គូរជាប្រយោជន៍ដល់ពួកកសិករ ដែលក្រខ្សត់នៅក្នុងភូមិ ។ អ្នកណាគ្មាននង្គ័ល ម៉ាលៀងគូរនង្គ័លឲ្យ ។ អ្នកណាគ្មានចបចូក ក៏គូរចបចូកឲ្យ ។ អ្នកណាគ្មានចង្កៀងក៏គូរចង្កៀងឲ្យ ។ អ្នកណាគ្មានថាំងដងទឹក ក៏គូរថាំងឲ្យ ។

រឿងជក់ទិព្វបានលេចឮទៅដល់កុដុម្ពិកម្នាក់នៅទីនោះ ។ កុដុម្ពិកចាត់ឲ្យទាសាពីរនាក់ទៅចាប់ម៉ាលៀង ដល់ចាប់ម៉ាលៀងយកមកដល់គេហដ្ឋាន កុដុម្ពិកឲ្យម៉ាលៀងគូរគំនូរផ្សេងៗ ។ ម៉ាលៀងពិតមែនតែខ្លួននៅក្មេង តែមានគំនិតចាស់ ។ ម៉ាលៀងស្គាល់ជាក់ច្បាស់នូវចិត្តលោភនៃកុដុម្ពិកនេះហើយ បើទុកណាជាកុដុម្ពិកសន្យាថាឲ្យកោតទ្រព្យច្រើន ក៏មិនព្រមគូរសោះឡើយ សូម្បីតែកុដុម្ពិកកំហែងគំរាមយ៉ាងណាក៏ដោយ ក៏នៅតែស្ងៀមព្រងើយមិនព្រមគូរអ្វីពាល់តែសោះ ។ ឃើញអាការរឹងចឹងដូច្នោះ កុដុម្ពិកបានចាប់ម៉ាលៀងទៅឃុំខាំងនៅក្នុងក្រោលសេះហើយហាមប្រាមមិនឲ្យអ្នកណាយកម្ហូបអាហារទៅឲ្យបរិភោគ ។

ដល់បីថ្ងៃក្រោយមក ក្នុងពេលរាត្រី មានព្រិលធ្លាក់ត្រជាក់ខ្លាំង កុដុម្ពិកគិតក្នុងចិត្តថា: ប្រហែលជាម៉ាលៀង បើមិនស្លាប់ដោយអត់អាហារ គង់អនិច្ចកម្មដោយរងាខ្លាំងមិនខាន អញចង់ដឹងតើយ៉ាងណាទៅ ។

លុះទៅដល់ជិតក្រោលសេះ កុដុម្ពិកបានឃើញស្មៅក្រហមក្លាំង តាមប្រឡោះទ្វារ មានក្លិនឈ្ងុយឆ្ងាញ់ចេញសាយពីក្រោលសេះ ។ លោកបានឈ្ងោកក្បែរមើលតាមប្រឡោះទ្វារ បានឃើញមាលៀងកំពុងបរិភោគនំក្តៅ ៗ អង្គុយជិតដើងក្រានមានផើងកន្ទើងក្រហមឆ្អៅ ៗ កុដុម្ពិកនឹកឆ្ងល់ថា តើជើងក្រានេះអ្នកណាយកមកដាក់ក្នុងទីនេះ តើនំបង់ឆ្ងាញ់នេះបានមកពីណា លោកបានយល់ជាក់ច្បាស់ថានំនេះប្រហែលជាបានមកពីផ្ទះទិព្វនោះទេដឹង ! កុដុម្ពិកមានចិត្តតោមនស្សខ្លាំង ក៏បង្គាប់ឲ្យពួកទាសាដណ្តើមយកផ្ទះទិព្វពីមាលៀងហើយប្រហារជីវិតក្មេងនេះបង់ ។

ពួកទាសាកុដុម្ពិកជាង ១០ នាក់ បានចូលទៅក្នុងក្រោលសេះ តែមាលៀងរត់បាត់ពីទីនោះទៅ ដោយផ្លោះលើជញ្ជាំងក្រោលសេះទៅក្រៅដែលមានដណ្តើរវែងដាក់នៅលើកំផែងស្រាប់ ។ កុដុម្ពិកស្ទុះឡើងទៅលើដណ្តើរវែង ទើបនឹងជាន់បានពីរបីកាំស្រាប់តែធ្លាក់មកដីវិញ ហើយសំឡឹងមើលដណ្តើរស្រាប់តែបាត់មិនដឹងជាទៅឯណា ។

លុះតែចេញពីគេហដ្ឋានកុដុម្ពិកកាលណា មាលៀងសម្រេចចិត្តថាត្រូវតែចាកចេញពីភូមិនេះ ទៅកាន់ភូមិដទៃ ។ មាលៀងដឹងច្បាស់ថាបើពួនលាក់ខ្លួននៅកន្លែងណាមួយក៏បាន តែកុដុម្ពិកនេះនឹងអាចរកខ្លួនឃើញបានដោយងាយ ហើយរឿងនេះនឹងនាំឲ្យមានភ័យន្តរាយដល់អ្នកដែលឲ្យទីលំនៅជ្រកពួនរនោះមិនខាន ។ មាលៀងមានកតញ្ញូចំពោះអ្នកភូមិ

នោះថា "ខ្ញុំសូមលាចន័ប្អូនហើយ" ។ រួចម៉ាលៀនបានយកដក់ទិពគ្គូរព័សជាសេះមួយមានលំអអស្ចារ្យ រួចកំឡៀងជិះលើសេះនោះបំផាយទៅរកថ្នល់ធំ ។

ម៉ាលៀនមិនទាន់បានធ្វើដំណើរឆ្ងាយប៉ុន្មាន ស្រាប់តែមានមនុស្សអ៊ូអរពាសពេញដេញតាមពីក្រោយ ។ ដល់ក្រឡេកបែរក្រោយ ម៉ាលៀនស្រាប់តែឃើញកុដុម្ពិក៍ជិះសេះកាន់ដាវ មានពាំងពួកពាសាជាង ២០ នាក់តាមពីក្រោយផង ។ នៅពេលយប់ មានភ្លើងចន្លុសចាំងពន្លឺ ឃើញច្បាស់នូវទេសភាពផ្សេង ៗ ។

ដល់ឃើញថាកុដុម្ពិក៍តាមជិតទាន់ខ្លួន ម៉ាលៀនគ្មានតក់ស្លុតអ្វីសោះឡើយ ហើយយកដក់ទិពគ្គូរជាព្រញទឹងធ្នូ ។ ម៉ាលៀនយកធ្នូរាកបាញ់មកក្រោយ ព្រួញនោះត្រូវចំដើមកនៃកុដុម្ពិក៍ធ្លាក់ពីលើខ្នងសេះដល់ដី ។ ម៉ាលៀនយកខ្សែតីព័យសេះដោយយ៉ាងលឿន ឥតឈប់ឈរ រួចមកឈប់ត្រង់ភូមិមួយតូច ដោយយល់ឃើញថាអ្នកដែលជិះសេះតាមនោះស្ថិតនៅឆ្ងាយដាច់ស្រយាល ។ ដោយយល់ឃើញថាខ្លួនគ្មានការអ្វីធ្វើ ម៉ាលៀនគិតចិញ្ចឹមជីវិតដោយវិជ្ជាគ្គូរព័ស ។ ដល់គ្គូរបានជារូបកងហើយ ម៉ាលៀនយកគំនូរនោះទៅលក់តាមផ្សារ តែដោយមិនចង់ឲ្យគេស្គាល់ខ្លួនបាន ក៏ធ្វើរូបនោះកុំឲ្យកម្រើកបាន ។ ដើម្បីនឹងសម្រេចនូវគោលបំណងនេះ ម៉ាលៀនគ្គូររូបសត្វ ឬបក្សាដោយគ្មានដំពុស ឬគ្មានជើង ។

(នៅមានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់ នៃខេមរជាតិ
ខ្មែរគួរខ្មីឃ្មាត សក្បាពេញទី ។
ព្រោះខេមរជាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប.ព

## រឿងទាក់ដំរី

ជាដំបូង សូមជំរាបថា ដំរីមាន ២ បែប គឺដំរីភ្នំនិងដំរីរនាម ឬដំរីព្រែង ។ ឯការទាក់ដំរីក៏មាន ២ បែបដែរ ។

ដំរីភ្នំមានកងធំ ក្បាលខ្ពស់ជាងខ្លួន ដែលគេតែងជួបប្រទះនៅក្នុងខេត្រដែលមានភ្នំច្រើន ដូចជាកំពត កំពង់ស្ពឺ ពោធិសាត់ ។ល។ ពួកដំរីម្យ៉ាងទៀត ដែលមានរូបរាងតូចល្មម ហើយក្បាលនឹងដងខ្លួនមានកំពស់ស្មើគ្នា ហៅថាដំរីរនាមឬដំរីព្រែង ។ គេច្រើនប្រទះឃើញនៅក្នុងខេត្រកំពង់ឆ្នាំង កំពង់ធំ សៀមរាប និងតាមមាត់ទន្លេសាបផង ។

តាមធម្មតា គេមិនសូវទាក់ដំរីធំទេ គេច្រើនទាក់ដំរីតូចៗល្មមងាយនឹងផ្សាំងប្រើបាន ។ ឯដំរីដែលគេត្រូវទាក់ហៅថាបាកស ។ ពួកហ្មដំរីដែលត្រូវការចេញទៅទាក់ដំរី ត្រូវធ្វើពាក្យសុំអនុញ្ញាតទាក់ពីចៅហ្វាយខេត្រ ដោយមានបង់ពន្ធផង ។ សំបុត្រអនុញ្ញាតដែលកជការ

មានសមត្ថកិច្ចចេញឲ្យនោះ មានដាក់ឈ្មោះអ្នកសុំទាក់ ចំនួនដំរីសុំទាក់ និងកំណត់ពេល ៣ ខែ គិតពីថ្ងៃចេញច្បាប់អនុញ្ញាតនោះ ថែមទាំងមានបំរាមមិនឲ្យសម្លាប់ដំរីផង លើកលែងតែដំរីណារំលោភលើអ្នកទាក់ហួសកម្លាំងនឹងការពារពុំឈ្នះ ។ ហើយប្រសិនបើជាមានការសម្លាប់ដំរី ត្រូវនាំយកភ្លុកនឹងប្រអប់ជើងទៅប្តឹងដល់រាជការដែលនៅជិតជាងគេ ។

ពេលត្រឡប់មកពីទាក់វិញ ហ្មត្រូវនាំយកដំរីដែលទាក់បានទៅជូនរាជការឲ្យកាត់តម្លៃលក់ ហើយរាជការត្រូវហូតភាគខ្លះ ជាប្រយោជន៍ថវិកាជាតិ ទើបចេញសំបុត្រសំគាល់កិនភាគដំរីឲ្យម្ចាស់កាន់ ។

## របៀបទាក់ដំរីភ្នំ

ចំពោះរបៀបនេះ ហ្មនិយមចេញទៅទាក់នៅរដូវប្រាំង គឺពីខែមាឃទៅខែពិសាខ ។ មុននឹងចេញទៅទាក់ ពួកហ្មបបួលគ្នាឲ្យបានច្រើន គឺពី ១០ នាក់ឡើងទៅ ។ លុះបានសំបុត្រអនុញ្ញាតស្រេច គេត្រូវរៀបចំស្បៀងអាហារ មានអង្ករ ត្រីងៀត ត្រីឆ្អើរប្រហុក អំបិល កាំបិត ចាន ឆ្នាំង (ឆ្នាំងដីមិនយកទេខ្លាចបែក) ហើយដាក់ត្រណមឲ្យប្រពន្ធកាន់រៀងខ្លួន ។ ប្រពន្ធហ្មទាំងឡាយដែលប្តីចេញទៅទាក់ដំរី ត្រូវតមមិនឲ្យមានសហាយ មិនឲ្យលូកកកាយបាយនឹងដៃចេញពីឆ្នាំង មិនឲ្យគងវែកលើមាត់ឆ្នាំង សើតសក់កាត់សក់យប់ គោះទាក់កំទេចហិបស្លាពេល លេង

ចាក់ចង្កេះគ្នា ឬគក់គ្នាក៏មិនបាន ។ល។ តែមិនកាន់ត្រណមទាំងនេះ មុខជាប្តីនឹងមានគ្រោះថ្នាក់ដល់ស្លាប់ផងក៏មាន ។

រួចហើយ ទើបហ្មរៀបចំគ្រឿងទាក់-ចាប់ ដូចជាព្រ័ត្រ(១) ប្រកាំ កន្ទេរ ពូថៅ ក្រវិលសម្រាប់វាយផែង ស្នែងជើងរង ដងកញ្ចាម(២) ។ល។ ផ្ទុកលើខ្នងដ្នាក់ជាមួយនឹងគ្រឿងបរិភោគ ប៉ុន្តែរបស់ទាំងនេះ ផ្ទុកលើខ្នងដ្នាក់តែពីកាលធ្វើដំណើរទៅទេ តែដល់ព្រៃ គេទំលាក់មកព្រយុងពីក្រោមពោះដ្នាក់វិញ ព្រោះកុំឲ្យទទើសទទែងនៅពេលចូលព្រៃ និងនៅពេលជួបហ្វូងដំរីព្រៃ ។ ហ្មនឹងគង្វាលរើសរកថ្ងៃល្អឈ្នះសត្រូវខ្មោចបីសាចទើបហ៊ានចេញទៅ ។ នៅតំបន់ខ្លះ អ្នកទាក់ដំរីធ្វើពិធីសែនព្រេនដល់ម្រេញគង្វាល នឹងអ្នកតាបង់បត់សុំបើកព្រៃ នឹងសុំឲ្យចេញទៅមានជ័យជំនះផង ។ របៀបសែនម្រេញគង្វាលមានប្រទាស ១ បំពង់ទឹក ១ គូ កន្ទោង ១ ស្នែងផ្លុំ ១ កន្ទេរ ១ ពន ៣ ថ្នាក់ ប្រម ៨ រាជវតិ ដុំវិញពន ម្លូ ៥ ស្លា ៥ បារី ៥ បន្ថែមធ្មេញ-ស្តាំ នឹងសំពត់សក្រហម ។ លុះរៀបចំសព្វគ្រប់ហើយ ទើបគេនាំគ្នាចេញដំណើរទៅ ។ ដំរីឈ្នាក់ខ្លះមានស្នាមហើម ២-៣ អន្ទើ ដែលពួកហ្មរាយពោកទឹងកង ឲ្យហើមសាច់

---

១- ធ្វើអំពីស្បែកគោ ឬ ក្របីចាស់ ដើម្បីឲ្យជាប់ប្រើបានដល់កូន ដល់ចៅក៏មាន ។

២- ជាឫស្សីអមព្រ័ត្រសម្រាប់លួកទាក់ជើងដំរីព្រៃ ។ ដងកញ្ចាមនេះ គេច្រើនប្រើតែនៅទីវាល តែដំរីរត់ចូលព្រៃ គេមិនប្រើទេ ព្រោះនាំឲ្យទើសទែងណាស់ ។

ទុកជាមុន សម្រាប់ដល់ពេលដេញប្រយុទ្ធនឹងដំរីព្រៃ វាយលើស្នាមហើមស្រាប់នេះ ទើបធ្លាក់ឈើរត់លៀនតាន់ការ ៗ នៅលើខ្នងធ្លាក់នីមួយៗ មានហ្មាក់តាមក្បាល កាន់ប្រកាំចាំតែចាក់ កិច្ចការអ្វីដទៃស្រេចលើគង្វាលដែលជិះនៅចង្កេះទាំងអស់ ៗ

កាលណាឈប់ចាក់ គង្វាលត្រូវមើលរៀបចំព្រ័ត្រប្រកាំនឹងគ្រឿងចាក់ចាប់ទាំងឡាយ ធ្វើផ្ទះ ឬគូបកំពស់ប្រមាណជា ៣ ឬ ៤ ម៉ែត្រ ពីដី ដើម្បីដាក់គ្រឿងទាំងនោះ ខ្លាចក្រែងភ្លៀងត្រូវបែង ៗ គូបនោះត្រូវធ្វើនៅក្រៅភូមិចម្ងាយប្រហែលជា១០០ ឬ ១៥០ ម៉ែត្រ ៗ គូបនេះ បើស្រីមានផ្ទៃពោះដើរកាត់មុខ នឹងមានអន្តរាយដល់ទារកក្នុងផ្ទៃ ៗ

អំពីការចាក់ដំរីនេះ មិនមែនចូលព្រៃភ្លាមចាក់បានភ្លាមទេ ជួនកាលដើរ ដប់-ម្ភៃថ្ងៃ មិនទាន់ប្រទះហ្វូងដំរីមួយផង ៗ

នៅពេលចូលព្រៃ ហ្មមានអំណាចធំជាងគង្វាល ៗ គង្វាលត្រូវរៀបចំដំណេកហ្ម ការុងអង្ករទុកនៅចុងជើង ហើយខ្លួនឯងត្រូវដេកនៅចុងជើងហ្មផង ៗ គង្វាលត្រូវគោរពហ្មយ៉ាងក្រៃលែង សូម្បីតែចាប់បានសត្វ ដូចជាអណ្តើក ទន្សង គង្វាលមិនហ៊ានអាស្រ័យផងទេ ត្រូវជូនទៅហ្មទាំងអស់ ខ្លួនអាស្រ័យបានតែសាច់ ៗ នៅពេលដេកលក់ បើមានការណ៍អ្វី ហ្មមិនយកដៃគោះហៅគង្វាលទេ ក្រែងដំរីស្តូវព្រៃតដៃនឹងធ្លាក់ ត្រូវយកជើងឈូសដាស់ ៗ ឯដំរីធ្លាក់ នោះជាឈ្មោលមានភ្លុកក្តី ស្តុក្តី ឬមេក្តី ក៏អាចយកធ្វើជាធ្លាក់ទាំងអស់បានគតាស់ទេ ៗ ពេល

ដូចទឹកក្នុងព្រៃ ហ្មមិនហ៊ានដុសក្អែលទីវាល ឬដុសក្អែលតួតទីងក្រមា ទេ ខ្លាចក្រែងដំរីព្រៃ ផ្ទុសគង្វាលទម្លាក់ពីលើខ្នងធ្លាក់ ។

ពួកហ្មនាំគ្នាទៅស្តាប់សម្រែកដំរីតាមដងអូរ ទីងច្រកភ្នំដែលមាន ទឹក ក្រែងមានហ្វូងដំរីចុះផឹកទឹក ។ តែកាលណាគេដឹងថា មានដំរីនៅ ទីណាហើយ គេក៏ប្រញាប់ដណ្តាំឃ្វាយបរគោគឲ្យហើយស្រេច ព្រោះ គិតថាមុខជាជាប់ដៃប្រយុទ្ធជាមិនខាន ហើយសម្រួតអីកទ់មកដាក់ក្រោម ពោះធ្លាក់វិញ រួចបរសំដៅទៅរកហ្វូងដំរីព្រៃ ។

ដល់ប្រទះទីងហ្វូងដំរីព្រៃ ហ្មទាំងឡាយក៏បរធ្លាក់ចូលសម្រុកទៅ ក្នុងហ្វូងដែលមានដំរីពី ៤០ ទៅ ៦០ ហើយស្រែកសន្ធាប់បន្លឺលកង រំពង ។ ពេលនោះ ដំរីព្រៃក៏យស្លុន់តក់បែកខ្ញែកគ្នាប្រសេចប្រសាច ។ លុះឃើញឱកាសល្អហើយ ទើបពួកហ្មបោះព្រ័ត្រទៅទាក់កូនដំរីណាដែល ខ្លួនស្រឡាញ់តែរៀងខ្លួន (តូចពេកខ្លាចស្លាប់ ធំពេកក្រែងការពារពុំឈ្នះ គឺយកតែល្មម) ។ តែកាលណាព្រ័ត្រប្រកាំទាក់ជាប់ជើងកូនដំរីហើយ គង្វាលលើកព្រ័ត្រទាំងចង្វាយបោះទៅដី ហើយលោតខ្លួនឯងចុះទៅតាម ដើម្បីទៅចាប់យកកន្ទុយព្រ័ត្រពទ្ធចងនឹងគល់ឈើ ។ ចុងព្រ័ត្រនេះ អ្នក ខ្លះមានចងស្នែងជើងរង ឬក្រឆាវធ្វើអំពីស្នែងក្របីពេលក្មេងពត់ឲ្យខុចក្ដក់ គេមិនយកដែកឬឈើធ្វើទេខ្លាចបាក់ ។ តែកាលណាជាប់បាកស ។ ទូសព្រ័ត្រទៅ ឲ្យស្នែងនេះថ្ពក់ជាប់នឹងគល់ឈើ កុំឲ្យទៅបានឆ្ងាយ ។

ពេលនោះពួកស្តព្រៃ វាមិនមែនបណ្ដោយឲ្យគេចាប់កូនទៅវាតាមអំពើចិត្តទេ រួចពីផ្អើលមួយភ្លែត វាត្រឡប់មកតដៃនឹងឆ្នាក់ ដើម្បីដណ្ដើមយកដំរីពីប្រកាំវិញ ។ ខណៈនោះ ហ្មរត់ឡើងលើខ្នងឆ្នាក់ចាប់ដាវនឹងពូថៅតដៃនឹងដំរីព្រៃ គង្វាលគិតតែវាយចាក់ឆ្នាក់ឲ្យរត់ដេញដំរីព្រៃពាល់តែបាក់បបរត់ព្រាត់ព្រាយទៅ ។ ពេលដែលបាពសជាប់ប្រកាំហើយរត់ ហ្មអាចសំគាល់បានថា បាពសនោះ មានកម្លាំងប៉ុន្មាន ៗ ។ តែកាលណាជាប់ប្រកាំហើយ បាពសនោះរត់ពាល់តែដួលដេក ហ្មគេប្រញាប់លក់ចោល បើទុកទៅមុខជាស្លាប់ខាតប្រយោជន៍ ។ ម្យ៉ាងទៀត ដំរីដែលទើបនឹងទាក់បាននោះ បើពួកហ្មឈ្លោះប្រកែកគ្នាពីរឿងចែកភាគមិនស្មើនោះ គេត្រូវលក់ចោលដែរ សុះចិត្តឲ្យខាតខ្លះ តែទុកទៅដំរីនោះអាយុខ្លី ។

តាមទម្លាប់ ហ្មនឹងគង្វាលដែលធ្វើការរួមគ្នា ត្រូវទាក់ឲ្យបានបាពស ៣ គឺ បាពសមួយចំណែកហ្ម បាពសមួយចំណែកម្ចាស់ឆ្នាក់ បាពសមួយទៀតចំណែកគង្វាល ។

ឯការថែរក្សាកូនបាពសស្រេចនៅលើគង្វាល ។ មួយថ្ងៃៗ គង្វាលជិះឆ្នាក់ទៅផែបមើលទន្លឹងតិបិដង ផែបនាំបាពសទៅឲ្យផឹកទឹក ទៅលាងទឹក ។ ម្យ៉ាងទៀត ការនាំបាពសពីព្រៃទៅស្រុកជាការលំបាកក្រៃលែង ព្រោះថា ធម្មតាសត្វព្រៃមិនមែនចង់ចូលទៅនៅស្រុក ឲ្យមនុស្សធ្វើបាបគ្រប់ពេលវេលាទេ ណាមួយព្រាត់ហ្វូង ព្រាត់មេបងប្អូន

ដែលធ្លាប់សប្បាយជាមួយគ្នាផង ។

កាលមកដល់ស្រុកភូមិហើយ ហ្មក៏ដាក់គ្រណាមពីប្រពន្ធចេញ រួចបង្គាប់ឲ្យគង្វាលរកឈើណាធ្វើជាឆាញ៉ា ឬ សន្ទុងសម្រាប់ផ្សាំងបាកស ។ រកបានហើយ គង្វាលយកបាកសទៅចងព្រយុង បង្អត់ស្មៅ ៣ ៤ ថ្ងៃ ឲ្យហេវកុំឲ្យក្លាពេក ជាហេតុនាំឲ្យឆ្ងាយផ្សាំង ហើយគង្វាលបណ្ដាក់ទៅអែបបង្ហាត់បន្តិចម្ដងៗ ពាល់តែមនុស្សពាល់បានឥតផ្អើល ។ ក្រោយពីនោះ មានការបង្ហាត់ឲ្យចេះស្ដាប់ភាសាទ្រមាក់ដូចជាថា ៖

ហារ់ៗ = ឈប់

ដុនៗ = ថយ

ដូនៗ = លើកជើងមុខ

ទ្រោម = ក្រាប

ដាក់ = លុតជង្គង់ក្រោយ

ដៃ = ហាមមិនឲ្យបោចពេច

កាន់ = ចាប់ កាច់ ឬ ដក ។ ល ។

លុះបាកសចេះស្ដាប់បង្គាប់លែងផ្អើលហើយ ទើបហ្មរៀបចំធ្វើពិធី "ចាប់ជើង" ឲ្យឈ្មោះដំរីនោះ ។

តាមសេចក្ដីឲ្យការរបស់លោក ឈួង-អ៊ុច អតីតមេឃុំៗ អង្កាញ់ ស្រុកព្រៃកប្បាស (តាកែវ) ដែលធ្លាប់បានឃើញគេធ្វើពិធីនេះនៅជំបន់

របស់លោកប្រមាណជា ៥០ ឆ្នាំមកហើយនោះ ថាមានធ្វើប្រម ៤ ជាយ សង់ក្រាដក់ដាក់ក្នុងកន្ទោង ៤ ស្លាធម៌ ៤ ស្លាក ៤ មានសរសេរឈ្មោះសត្វតាមម្ចាស់ស្រឡាញ់ ហើយដឹកសត្វនោះមកបញ្ឈរនៅក្បែរកន្លែងពិធី ។ ហ្មតាំងបាប់អុជទៀន-ធូបបួងសួងអធិដ្ឋានឡើងថា ៖

«ឱតេជៈ! ថ្ងៃនេះជាថ្ងៃជាពេលាល្អ ព្រះភូមករ ព្រះធរណី អ្នកតាចាស់ស្រុកម្រេញគង្វាល ដែលរក្សាទឹកដី បឹង បួ ទួលទីនេះ ឥឡូវនេះ ខ្ញុំត្រូវការឲ្យឈ្មោះសត្វដំរីនេះ បើឈ្មោះណាដែលសុខចំរើនដល់ម្ចាស់ទ្រព្យ សូមឲ្យសត្វនេះ ដើរជាន់ស្លាកឈ្មោះនោះមុនគេទៅ» ។

លុះបួងសួងគ្រប់ ៣ ដងហើយ ទើបដឹកដំរីដើរប្រទក្សិណកន្លែងពិធី ៣ ជុំ ។ បើដំរីនោះ ជាន់ទៅលើស្លាកឈ្មោះណា ក៏ហៅដំរីតាមឈ្មោះនោះទៅ មានឈ្មោះ អាជៀប អាស្ត អាកន្ទង់ មេក្រពុំជាដើម ហើយគេនាំគ្នាស៊ីផឹកសប្បាយទៅ ។ បើអ្នកណាទៅកន្លែងនោះហើយ មិនព្រមទទួលបរិភោគចំណីអាហារជាមួយនឹងគេ តែដល់ក្រោយមក ដំរីគេឈឺ គេថាមកពីអ្នកនោះមិនព្រមទទួលអំណារគេ ។ នេះជាទំនៀមក្នុងកាសពិធីដាក់ឈ្មោះឲ្យដំរី ។

ចំណែកនៅខាងខែត្រពោធិ៍សាត់វិញ ពិធីនេះជំប្រហែលនឹងរៀបអាពាហ៍ពិពាហ៍មួយដែរ ប៉ុន្តែគេច្រើនហៅថា “សែនផ្តាច់ព្រៃ” ឲ្យឈ្មោះដំរីទៅវិញ ហើយការឲ្យឈ្មោះទៀត មិនមែនធ្វើផ្សងតាមកន្ទោង

ឬស្លាកទេ គឺស្រេចនៅលើការស្រឡាញ់របស់ប្រពន្ធហ្ន ។ ឯរបៀបសំណែនក៏ខុសគ្នាដែរ ។ របៀបខាងខែត្រពោធិសាត់ មានបាយស៊ុបាក់ឆាម តែត្រូវ ស្លាធម៌ ១ គូ ទៀន ៤ ធូប ៤ ជម បន្ថែមចំអាបគូធ្វើង ស្លាំ សំពត់ចូត មាន់ស្ងោរ ទឹកស្រា ១ ដប ព្រមទាំងមានធ្វើពិធីព្រោះព្រំទឹកមន្តរម្ងាប់ចង្រៃបាពសផង ។

## របៀបទាក់ដំរីរនាម ឬ ដំរីត្រែង

តាមសេចក្ដីឲ្យការរបស់លោក មាស-បាំ កាលដែលលោកនៅធ្វើជាបាឡាត់ស្រុកកំពង់ស្វាយ ខែត្រកំពង់ធំនៅឡើយថា ការទាក់ដំរីរនាមឬដំរីត្រែង ច្រើនធ្វើនៅរដូវវស្សា ពិសេសគឺនៅពេលដែលព្រៃរនាមលិចទឹកអស់ ហើយហ្វូងដំរីត្រូវនាំគ្នាចូលទៅរកព្រៃដីទួលដែលមិនលិចទឹក ។ នៅរដូវសម្រក ដំរីរនាមត្រូវត្រឡប់ចុះពីព្រៃដីទួលទៅស៊ីស្មៅទឹកនៅមាត់ទន្លេសាប ប៉ុន្តែ អ្នកស្រុកមិនហ៊ានទាក់ក្នុងរដូវនេះទេ ខ្លាចរត់ឆ្លើសជាន់របស់ណាំផ្សេង ៗ ។ គេត្រូវរង់ចាំរដូវវស្សា កាលណាព្រៃរនាមលិចទឹកអស់ ទើបគេតាំទូទាប់ ។

ការទាក់ដំរីរនាម ក៏មានការសុំច្បាប់ដូចជាដំរីក្ដៃដែរ ថ្វីតែការទាប់ទាក់ប៉ុណ្ណោះ ។ ការទាក់ដំរីរនាមគ្មានគ្រណាមតឹងរឹងដូចជាការទាក់ដំរីក្ដៃទេ មានគ្រណាមតែមួយមុខថា បើទាក់បានហើយ ៗ មានការឈ្លោះប្រកែកគ្នាពេង្អ្នកទាក់ ដំរីនោះនឹងអាយុខ្វីតែប៉ុណ្ណោះ ។

ក្នុងពេលចាក់ដំរី មនុស្សផ្អើលទៅស្ងាត់ស្រុកភូមិ សូម្បីអ្នកដែលមិនចាក់ក៏ទៅមើលលេងនឹងគេដែរ ព្រោះជាការកំសាន្តមួយ ប៉ុន្តែ បើមនុស្សមានធម៌សប្បុរស ត្រឡប់ជាមានការសង្វេគណាស់ទៅវិញ ។

ដំរីនាមច្រើនដើរជាហ្វូងៗ មានចំនួនពី ១០០ ទៅ ២០០ តាមហ្វូងធំ-តូច ។ អ្នកស្រុកចាត់គ្នាឲ្យយាមល្បាត តាមផ្លូវដែលវាធ្លាប់ដើរ ។ បើកាលណាឃើញដំរីឡើង គេនាំគ្នាគោះគ្រឡោកជុតគប់ភ្លើងបង្អើលឲ្យវារត់ចុះទៅក្រោមវិញ ។ លុះដល់ទឹកឡើងបន្តិចហើយ គេបបួលគ្នា ១០០ ឬ ១៥០ នាក់ លបយកទូកជាច្រើនផ្ទុកស្បៀងអាហារព្រ័ត្រប្រកាំ ហើយអុំទៅចតចាំលាក់ស្ងាត់ផ្លូវដំរី បណ្តាក់គ្នាប្រហែលជា២០នាក់ពីកន្លែងមួយទៅកន្លែងមួយ ចាប់ពីទឹករាក់ទៅទឹកជ្រៅ ។ អ្នកដែលកៀងដេញពីទឹករាក់ទៅដល់កន្លែងទូកចត ក៏នាំគ្នាឡើងទូកស្រែកសន្ធាប់កងរំពង ។ ឯហ្វូងដំរីភ័យខ្លាំង ក៏ស្រែកពេញតែក្នុងទឹក អ្នកអុំអ្នកចែវខំស្រូតប្រកិតអ្នកចាក់បោះព្រ័ត្រប្រកាំចាក់យកដំរីណាធំៗ ហើយទាញកន្ទុយព្រ័ត្ររ៉ាត់ចងភ្ជាប់ទៅដើមឈើណាជិតជាងគេ ហើយទុកឲ្យវាប្រទាញប្រទង់តាមចិត្តវាចុះ ។ អ្នកចាក់បានក៏ឈប់រកបាយទឹកទៅ អ្នកមិនទាន់បានក៏ដេញតទៅទៀត ព្រោះគេដឹងថាដំរីកាន់តែជ្រុលទៅទឹកជ្រៅហើយ ។ នៅពេលប្រយុទ្ធចាក់នោះ កាលបើអ្នកចាក់ដេញសន្ធឹញខ្លាំងពេក ដំរីធំៗ មានឆាកមកគគៃ ហើយបុកទូកពន្លិច មនុស្សហែលព្រាតព្រោងក៏

មានដៃ ។ អ្នកទាក់ក៏មិនក ស្ទុះគេចតៃមួយកៀត រួចវិលចូលមកចាក់កាប់បាញ់វិញឲ្យខានតែឈ្នះ ។

ដំរីដែលទាក់បាន គេចងទុកនៅកន្លែងនោះរវាង៣-៤ថ្ងៃ ដោយចាត់គ្នាឲ្យយាមផង ។ ក្រោយពីនោះមក គេយកដំរីស្រុកទៅអែប នាំមកផ្សាំងឯភូមិ ។ របៀបក្រៅពីនេះ ធ្វើដូចដំរីកំពាំងអស់ ។

ការទាក់ដំរីនោមមួយលើក ៗ បានពី ១០ ទៅ ២០ ដំរីក៏មាន ថែមទាំងមានស្លាប់ខ្លះនៅពេលប្រយុទ្ធផង ។

## អំពីហ្មថារ

ពួកហ្មថារប្រហែលនឹងពួកបារគូដែរ គឺបើមានហ្មថារធំស្លាប់ ត្រូវរើសយកកូនប្រុសរបស់ហ្មនោះឲ្យធ្វើជាជំណាតទៅទៀត ពោះជាកូននោះនៅក្មេងសេចក្តីពុំទាន់ដឹងការអ្វីក៏ដោយ គេត្រូវឲ្យកូននោះរៀនរបៀបហ្មដើម្បីតំណាងត្រកូលខ្លួនតទៅ ពុំមែនរើសយកពូជហ្មដទៃទៀតទេ ។ នៅក្រោមបង្គាប់ហ្មថារ មានហ្មស្នងស្តាំ-ឆ្វេងពីរនាក់ ។ ហ្មរងពីរនាក់នេះ មិនចាំបាច់រើសតពីឪពុកទៅកូនប្រុសទេ ហ្មណាចេះដឹងជ្រៅជ្រះអំពីកិច្ចការហ្មថារ គេអាចតាំងជាហ្មស្តាំ ឬហ្មឆ្វេងបាន ។

នៅក្នុងខែត្រពោធិសាត់ ហ្មថារជាគ្រូជាមេ លើហ្មទ្រមាក់គង្វាលទាំងឡាយដែលនៅក្រោមអំណាចហ្មថារនេះ ។ ពួកនេះ តែដល់ខែមាឃតែងនាំគ្នាធ្វើពិធីឡើងព្រះកាំបិតស្តាំ ដែលជាគ្រឿងសក្តិសិទ្ធិដែលហ្មថារថែ

រក្សា ដូចពួកសិស្សគេ ឬមេមត់ធ្វើពិធីឡើងរេងលៀងគ្រូបូជាដែរ ៗ

លុះដល់រដូវឡើងព្រះគ្រូកាំបិតស្ដាំ ហ្មស្នងស្ដាំ · ធ្មេង ធ្វើសំបុត្រ កំណត់ថ្ងៃ-ខែ នឹងពេលវេលាប្រជុំប្រាប់ទៅគ្រប់ហ្ម ទ្រមាក់ គង្វាលដែល នៅក្រោមអំណាចខ្លួនទាំងប៉ុន្មាន ឲ្យចូលមករួមនៅពេលប្រជុំឡើងព្រះ គ្រូកាំបិតស្ដាំ ព្រមទាំងឲ្យនាំធ្លាក់នឹងបាពស ព្រ៊ត្រប្រកាំទៅផង ដើម្បី ធ្វើពិធីការតាមទំនៀមដូចរាល់ឆ្នាំរៀងមក ហើយរៀបសង់រោងពិធីមួយនៅ ជិតអាស្រមដំកល់ព្រះគ្រូកាំបិតស្ដាំនោះ ៗ

នៅថ្ងៃចូលរោងបុណ្យ ពួកហ្ម ទ្រមាក់ គង្វាល បាពស ធ្លាក់ នឹងបរិវារហ្មមកជួបជុំទាំងអស់ ។ នៅពេលរសៀល គេនាំគ្នាដង្ហែព្រះ គ្រូកាំបិតស្ដាំចេញពីអាស្រមប្រទក្សិណ ៣ ជុំ ហើយទើបនាំទៅដំកល់ក្នុង រោងលើអាសនៈមួយដ៏វិចិត្រ ដែលគេបានរៀបគ្រឿងសក្ការបូជាផ្សេង ៗ តាមទំនៀមទម្លាប់ ដូចជាជមពារ ស្លាធម៌ បាយសី ធ្មេង-ស្ដាំ សំពត់ ហូលព្រែ នំ ចំណី ផ្លែឈើ បេក អំពៅ មានទាំងតែរួត កន្ទ្វាងបាយ កន្ទោងញាំភ្លា រណ្ដាប់ដូចគ្នានឹងពិធីការព្រះពិស្ណុការ ឬក្រុងពាលីដែរ ៗ ឯហ្មថាវត្រូវស្លៀកពាក់ស ៗ យប់មានពួកដន្ត្រីប្រគំកំដរបុណ្យរាល់ព្រឹក។

ព្រឹកឡើង ហ្មធ្មេង·ស្ដាំ ក៏រៀបពិធីការបួងសួង សូត្រមន្តប្រោះព្រំ ព្រះកាំបិតស្ដាំរម្លាប់ចង្រៃ ចប់ហើយទើបហ្មថាវធ្វើពិធីហូតព្រះកាំបិត ចេញពីស្រោម ដើម្បីទឹងទំនាយភេទស្រុក តាមចំណាំជាយូរអង្វែង

ណាស់មកហើយនោះ ។ ហ្លថាវរៀបចំស្រាយស្រោមសំពត់ រូបស្រោមព្រៃ រូបស្រោបជាតិ រូបស្រោមគម្ពី ។ ដូនកាលគេឃើញមានគ្រាប់-ស្រូវ-អង្ករ-សណ្តែក-ល្ង ឬពងស្រមោចនៅក្នុងស្រោមនោះ ។ ទឹងហូតព្រះកាំបិតចេញពីបំពង់ស្រោម ហ្លថាវត្រូវកាន់ព្រះកាំបិតសំយុងចុងចុះក្រោម មុខឈមមកមុខហ្លថាវ ហូតចេញផុតមកហើយ ក៏ដាក់ទៅក្នុងទឹកផ្តិលមួយនៅក្បែរនោះ ហើយនាំគ្នាពិនិត្យមើលរូបរាងព្រះកាំបិតនោះទៀត ។ គេសង្កេតតាំងពីពេលហូតថា ដូនកាលធូរ ដូនកាលតឹង ដូនកាលមុខព្រះកាំបិតមានច្រែះ មានស្នែះរេចឆែប ឬឃើញស្នាមដូចជាមានប្រឡាក់ឈាមយូរមកហើយ ដូនកាលឃើញក្លិហាក់ដូចជាគេទើបនឹងសំលៀងហើយថ្មីៗ រូបទើបហ្លថាវទំនាយគេទស្រុក តាមការដែលបានសង្កេតឃើញនោះទៅ ។

ក្រោយពីនោះមក ពួកហ្លថាវក៏នាំគ្នាសំលៀងដុះខាត់ឲ្យជ្រុះអស់មន្ទិល ហើយលាបប្រេងស្អិតស្អាងឲ្យយ៉ាងស្អាតរៀបរុំខ្ចប់ប្រកទុកក្នុងស្រោមដូចដើមវិញ ។

ស្រេចហើយ គេដង្ហែព្រះកាំបិតស្តាំនោះ ចូលទៅដំកល់ក្នុងអាស្រមវិញ មានទាំងភ្លេងដូរ្យតន្ត្រីប្រគំកំដរផង ។

តពីនោះមក មានការលេងទាក់ដំរី ហ្លស្នងស្តាំ-ឆ្វេង ចាត់ឲ្យរៀបដំរីឈ្នាក់ដោយឈ្នាក់ បាកសដោយបាកស នៅចម្ងាយពីគ្នាប្រហែល ៥០ ម៉ែត្រ ។ ហ្លស្នងចាត់ឲ្យទ្រមាក់ជិះបាកស ឲ្យហ្លនឹងគង្វាលជិះឈ្នាក់ មាន

តាំងពីត្រប្រកាំដូចចេញទៅតាក់ដ័រមែន ៗ ។ ហើយទ្រមាក់ បំបោល បោកសចេញទៅ ឲ្យហ្វូនឹងគង្វាលវាយបំបោលផ្ទាក់ដេញតាមក្រោយ ។ គេធ្វើដូច្នេះ ចំនួនជា ៣ ឬ ៤ លើក ជាការកំសាន្ត ពួកអ្នកមើលហោកញ្ជ្រៀវសើចសប្បាយ រួចក៏នាំគ្នាស៊ីផឹកអឹងកង ។

តាមសេចក្ដីឲ្យការរបស់លោក ឈួង-អ៊ុណ អតីតយោក្បាត់ នៅឃុំលលកស ស្រុកបាកាន ខេត្តពោធិសាត់ កាលពីឆ្នាំ ១៩៥០ គឺកាលដែលគាត់រស់នៅឡើយ ហើយធ្វើជាសមាជិករបស់ក្រុមជំនុំទំនៀមទម្លាប់នោះ លោកបានសរសេរទុកថា : តាំងពីរវាងឆ្នាំ ១៩០៦ – ១៩០៧ មក ពួកហ្វូទាំងឡាយ ពុំមានការគោរពហ្វូថាវ ហ្វូស្នឹងឆ្វេង-ស្ដាំទៀតឡើយ ព្រោះពួកពូជហ្វូនេះ កាន់តែរវើរពេយផុតរលត់អស់ទៅ នៅតែស្រី ៗ ហើយតែដល់រដូវ ក៏គ្រាន់តែរៀបចំបន្ដិចបន្តួចបង្គ្រប់កិច្ច ។

តមកទៀតថា ក្នុងឆ្នាំ ១៩៤៥ មានចោរបានចូលទៅលួចព្រះកាំបិតស្ដាំយកបាត់ទៅ ដែលជាហេតុនាំឲ្យរឿងហ្វូថាវនេះ សាបសូន្យបណ្ដោយតែម្ដង ។

សព្វថ្ងៃនេះ រូបហ្វូថាវក៏គ្មាន ហ្វូឆ្វេង-ស្ដាំក៏គ្មាន កាលឆ្នាំ ១៩៥០ នៅមានគ្រឿងដំណែលខ្លះរបស់ហ្វូថាវ ដូចជាទូ ស្នែងធំ-តូច សម្រាប់ផ្លុំ នៅផ្ទះក្រុមញាតិហ្វូថាវ នៅឯភូមិបាក់ខ្នារ ឃុំលាជ ស្រុកភ្នំក្រវាញ ខេត្តពោធិសាត់ គេរក្សាទុក ។ ឥឡូវរបស់ទាំងអស់នេះ មិនដឹងជានៅមាន ឬបាត់បង់អស់ទៅហើយទេ ។

## ផ្នែកកំណត់និងប្រវត្តិការណ៍

# សុន្ទរកថាលោករដ្ឋលេខាធិការក្រសួងធម្មការ

---

*សូមទូលសម្តេចទាំងពីរព្រះអង្គ*

*ព្រះថេរានុត្ថេរៈ*

*ទ្រង់*

*សូមជំរាបឯកឧត្តម*

*លោកជំទាវ*

*ឯកឧត្តមឯកអគ្គរដ្ឋទូត*

*លោកស្រី*

*អស់លោក*

ក្នុងនាមព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ដែលមានអង្គសម្តេចព្រះនរោត្តម-សីហនុ ជាព្រះប្រមុខរដ្ឋ និងក្នុងនាមប្រជាជាតិខ្មែរទាំងមូល ព្រមទាំងក្នុងនាមខ្ញុំព្រះករុណាខ្ញុំជារដ្ឋលេខាធិការក្រសួងធម្មការ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះរដ្ឋាភិបាលប្រទេសឥណ្ឌា ដែលមានឯកអគ្គរដ្ឋទូតឥណ្ឌា ប្រចាំប្រទេសកម្ពុជាជាប្រធាន បានជួយឧបត្ថម្ភលោកបណ្ឌិត ជាត់ ជាតិឥណ្ឌា ជាអ្នក

ប្រាជ្ញខាងបរមត្ថវិជ្ជា និងខាងព្រះពុទ្ធសាសនាឲ្យបានមកធ្វើសន្និសីទនៅប្រទេសកម្ពុជានេះ ស្តីពីអានុភាពព្រះពុទ្ធសាសនា ហើយជាពិសេសសូមថ្លែងអំណរគុណចំពោះលោកបណ្ឌិត ដាក់ ដែលបានអញ្ជើញមកធ្វើសន្និសីទនេះដើម្បីញ៉ាំងចិត្តលោក-អ្នកស្តាប់ឲ្យបានជ្រួតជ្រាប នូវព្រះអនុត្តរធម៌របស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូ រឹងរឹតតែទ្វេឡើង ។

អស់លោកអ្នកស្តាប់ទាំងឡាយ មានសេចក្តីអរគុណចំពោះលោកបណ្ឌិតជាអនេក ។

ក្នុងឱកាសដ៏ថ្លៃនេះ សូមសម្តេច ព្រះថេរានុត្ថេរៈ ទ្រង់ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក អនុញ្ញាតឲ្យខ្ញុំព្រះករុណា ខ្ញុំ ថ្លែងនូវប្រវត្តិរបស់លោកបណ្ឌិត ដាក់ ដោយសង្ខេបដូចតទៅនេះ៖

លោកបណ្ឌិត ដាក់ អាយុ ៧០ ឆ្នាំ មានសញ្ញាប័ត្រដុកទ័រ ខាងបរមត្ថវិជ្ជា បានរង្វាន់ឈ្មោះថា " អនុស្សាវរីយ៍គ្រិហ្វហ្វីត (Griflith) ក្នុងការស្រាវជ្រាវ " ហើយនិង ១ ទៀតឈ្មោះ " រង្វាន់ការស្រាវជ្រាវនៃមហាវិទ្យាល័យហ្ស៊ូយប៊ីលី (Jubilee) និងមេដាយមាស ។

លោកបានបម្រើនៅមហាវិទ្យាល័យ ទីវដែល ពីឆ្នាំ ១៩២៤ ទៅ ១៩៤៩ ជានាយកវិទ្យាល័យ រ៉េប៉ស និងធ្វើជាប្រធានសន្និសីទនៅមហាវិទ្យាល័យអង់គ្លេស ។

លោកបានទទួលរង្វាន់ទី ២ របស់ទ្វីបអាស៊ី ក្នុងការប្រឡងតែងសេចក្តីសាកលលោក ក្រោមការឧបត្ថម្ភនៃរដ្ឋាភិបាលព្រះចៅអធិរាជជប៉ុន ដោយបានតែងសេចក្តី មានចំនួន ៨.០០០ ពាក្យអំពី "វប្បធម៌ជប៉ុនជាភាសាហិណ្ឌូ" ហើយបានប្រែជាភាសាជប៉ុន បោះពុម្ពផ្សាយក្នុងសារពត៌មានធំមួយនៅតូក្យូពីឆ្នាំ ១៩៤០ ។

លោកជាអ្នករដ្ឋការទាក់ទងខាងកិច្ចការវប្បធម៌ក្នុងស្ថានទូតចិនជាតិនិយមនៅនីវដែលីរវាង ១៩៤៨ ដល់ ១៩៥០ លោកបានសិក្សាប្រវត្តិសាស្ត្រចិន និងព្រះពុទ្ធសាសនានៅប្រទេសចិន ក្នុងសម័យធ្វើការនោះបានសរសេរអំពីសាលាសិក្សា ១០ ខាងព្រះពុទ្ធសាសនានៅប្រទេសចិន បានសរសេរអំពីប្រវត្តិសាស្ត្រ ផ្នែកបរមត្ថវិជ្ជាខាងជនជាតិបូព៌ាប្រទេស និងបស្ចិមប្រទេស ដែលរដ្ឋាភិបាលឥណ្ឌាបានទទួលបោះពុម្ពសៀវភៅនោះផ្សាយហើយ ។

លោកបានធ្វើការជាមួយសាស្ត្រាចារ្យ ទូកស៊ី (Tucci) នៅមហាវិទ្យាល័យរោម និងអ៊ីស្មេអូ (ISMEO) ចំនួន ៣ ខែ ពីឆ្នាំ ១៩៥៣-១៩៥៤ ។

លោកជាព្រឹទ្ធបុរសនៃសមាជិកអមមហាវិទ្យាល័យខាងការស្រាវជ្រាវ នៅមហាវិទ្យាល័យនីវដែលី ពីខែមករា ឆ្នាំ ១៩៥៨ ដល់ខែមិថុនា

ឆ្នាំ ១៩៦០ ជាអ្នកចាត់ចែងខាងការិយាល័យ ការសិក្សាព្រះពុទ្ធសាសនា ។

លោកជាអ្នកនិពន្ធសៀវភៅខាងព្រះពុទ្ធសាសនា មានឈ្មោះដូចតទៅនេះ ៖

ក- អំពីប្រថមក្សត្រដែលទ្រទ្រង់ព្រះពុទ្ធសាសនា

ខ- អំពីព្រះសម្មាសម្ពុទ្ធ និងក្រោយពុទ្ធនិព្វាន ៥០០ ឆ្នាំ

គ- អំពីបព្វជិតពុទ្ធសាសនិក និងវត្តនៅប្រទេសឥណ្ឌា ។

ដំណើរដែលលោកបណ្ឌិត ជាត់ បានអញ្ជើញមកធ្វើសន្និសីទ ស្ដីពីព្រះពុទ្ធសាសនានេះ ជាដំណើរដ៏ប្រកបដោយសុមង្គលក្រៃពេក នាំឲ្យព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា និង ប្រជាពលរដ្ឋខ្មែរដែលជាពុទ្ធសាសនិក រលឹកឃើញជាថ្មីនូវប្រវត្តិសាស្ត្រ និង ព្រះពុទ្ធសាសនារបស់ខ្លួន ហើយសង្ឃឹមថា ប្រទេសឥណ្ឌា និង ប្រទេសកម្ពុជា ដែលធ្លាប់មានសម្ពន្ធភាពខាងលទ្ធិសាសនា និងខាងវប្បធម៌ចាក់ចែងគ្នាតាំងពីបុរាណរៀងមក ហើយថែមទាំងក្នុងបច្ចុប្បន្នកាលនេះ មាននយោបាយអព្យាក្រឹត្យបរិសុទ្ធដូចគ្នាផង មុខជាពង្រឹងសម្ពន្ធភាពនេះ ឲ្យរឹតតែរឹងប៉ឹងមាំមួនចំរើនឡើង ហើយជាពិសេសអាចញ៉ាំងព្រះពុទ្ធសាសនា ជាសាសនាប្រកបដោយព្រះធម៌ជាសន្តិវរបទធំ ៗ មានអហឹង្សាជាដើម ដែលនាំឲ្យពិភពលោកបានសន្តិភាព និងសេចក្ដីសុខចំរើនថ្កើងរុងរឿងផង ។

ជាអវសាន ក្រសួងធម្មការតាងនាមព្រះរាជរដ្ឋាភិបាលខ្មែរ និងពុទ្ធសាសនិកខ្មែរ ក្នុងព្រះរាជអាណាចក្រកម្ពុជាទាំងមូល សូមប្រសិទ្ធីពរជូនដល់រដ្ឋាភិបាលឥណ្ឌា ដល់ឯកឧត្ដមឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំប្រទេសកម្ពុជា ដល់ប្រជាជាតិឥណ្ឌាទាំងមូល ដល់លោកបណ្ឌិត ជាត់ និងលោកស្រី សូមឲ្យបានប្រកបដោយសេចក្ដីសុខបរិបូណ៌ និងប្រកបដោយសិរីសួស្ដីជ័យមង្គលគ្រប់ប្រការ តរៀងទៅកុំបីឃ្លាត ។

---

# សន្និសីទស្តីពីពុទ្ធសាសនានៃបណ្ឌិតដាត់

## ពុទ្ធសាសនាក្នុងអាស៊ីទ្វីប

សាស្ត្រាចារ្យពុទ្ធសាសនិកហៀងជាតិជប៉ុនម្នាក់ឈ្មោះ ស៊ុហ្ស៊ុគិ បានពោលថា៖ រវាងបូព៌ាប្រទេសនឹងបស្ចិមប្រទេសទាំងឡាយ គេត្រូវតែស្រាវជ្រាវរកនូវសភាពផ្សេងគ្នាក្នុងគំនិតទ្រឹស្តី ដែលឋិតនៅក្នុងព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនាគឺជាមតិកសាធារណៈរបស់ប្រជាជាតិជាច្រើននៃអាស៊ីទ្វីប គឺថាព្រះពុទ្ធសាសនាផ្តល់ឲ្យនូវលក្ខណៈនឹងកិត្តិយសដ៏ខ្ពង់ខ្ពស់ ចំពោះវប្បធម៌នៃប្រជាជាតិទាំងនេះ ។ ពុទ្ធសាសនាគឺជាអានុភាពដែលធ្វើប្រវត្តិសាស្ត្រ នៃប្រជាជាតិទាំងនេះឲ្យមានសណ្ឋានទ្រង់ទ្រាយក្នុងសម័យដើមបំផុត ។ អាស្រ័យហេតុនេះ គេមិនអាចសិក្សាប្រវត្តិពុទ្ធសាសនា ដាច់ដោយឡែកអំពីការវិវត្តន៍ខាងប្រវត្តិសាស្ត្រនៃប្រទេសទាំងនេះឡើយ ។

សព្វថ្ងៃ ប្រវត្តិសាស្ត្រនៃអាស៊ីទ្វីបបុរាណ នៅខ្វះសម្បូណ៌ភាពនឹងសហសម្ពន្ធភាពនៅឡើយ ។ ការសរសេរប្រវត្តិសាស្ត្រអាស៊ីទ្វីបដែលធ្លាប់ជាស្នាដៃនៃពួកអ្នកប្រាជ្ញបស្ចិមប្រទេស បានរួមនៅក្នុងមតិយោបល់របស់ជនជាតិអឺរ៉ុបស៊ើរតែទាំងអស់ ។ តាមធម្មតា អ្នកប្រាជ្ញទាំងនោះ តែងមានយោបល់យល់ឃើញថា ប្រទេសទាំងឡាយក្នុងអាស៊ីទ្វីប បានលូតលាស់ចំរើនឡើងដោយអាស្រ័យការទាក់ទងនឹងបស្ចិមប្រទេស ដោយ

ភាគច្រើន ឯសម័យប្រវត្តិសាស្ត្របរមបុរាណនៃប្រទេសទាំងនេះ គឺជាបរិច្ឆេទ ឬចំពីរកយរងនៃប្រវត្តិសាស្ត្រ គ្មានសេចក្តីសំខាន់ប៉ុន្មាន ហើយដែលលាយឡំទៅដោយទេវកថានិងរឿងព្រេងប៉ុណ្ណោះ ។ ដោយបស្ចិមប្រទេសទាំងឡាយបានដកចេញនូវអំណាចគ្រប់គ្រងរបស់ខ្លួនអំពីប្រទេសជាច្រើនក្នុងបូព៌ាទ្វីប សព្វថ្ងៃនេះ កែវទុះនៃប្រវត្តិសាស្ត្រក៏បានផ្លាស់ប្តូរទ្រង់ទ្រាយដែរ ។ ឥឡូវនេះ គេបានឃើញថា សម័យប្រវត្តិសាស្ត្របុរាណដែលអ្នកប្រវត្តិសាស្ត្របស្ចិមទិសបានមើលរំលង ឬថាព្រងើយកន្តើយមិនយកចិត្តទុកដាក់ពិនិត្យមើលផងនោះ គឺជាផ្នែកសំខាន់នៃដំណប្រវត្តិសាស្ត្ររបស់ប្រទេសទាំងនេះ ។ ចំពោះប្រជាជាតិជាច្រើន ក្នុងអាស៊ីអាគ្នេយ៍ ការនាំផ្សាយចូលមកនៃព្រះពុទ្ធសាសនា គឺជាគោលដើមដ៏នៃអារ្យធម៌ ។ ទេពកោសល្យជាតិ គឺប្រាជ្ញាដើមកំណើតនៃប្រទេសទាំងនេះ បានបញ្ចេញនូវផ្កាគឺស្នាដៃដ៏ឧត្តមបំផុតក្រោមអានុភាពលើកទឹកចិត្តនៃពុទ្ធសាសនា ។

បើយើងយល់ថាព្រះពុទ្ធសាសនាជា « លទ្ធិនិយម » ជាជំនឿមួយបែប ឬថាជារបបនៃទស្សនវិជ្ជាមួយបែបនោះ ប្រហែលយើងនឹងមានកំហុសជាមូលដ្ឋានមួយ ។ តាមសេចក្តីពិត ពុទ្ធសាសនាមានប្រតិបត្តិការនិងលទ្ធផលច្រើនលើសលុបជាងនោះទៅទៀត ។ ព្រះសាស្តានៃសាសនានេះ បានទុកនូវនិកាយនៃដំបូន្មានទាំងឡាយ ដែលត្រូវបាន

រៀបរៀងឲ្យមានរបៀបបែបផែនជាបិដកក្នុងសម័យក្រោយមកទៀត ។ ប៉ុន្តែក្នុងពាក្យប្រៀនប្រដៅទាំងនេះ ព្រះអង្គមិនបានបណ្ដុះភ្ជាប់នូវជំនឿបែបណាមួយជាស្ថាពរឡើយ ទ្រង់បានទុកបញ្ញា (គឺសមត្ថភាពពិចារណារកហេតុផល ) ឲ្យបុគ្គលគ្រប់ ៗ រូបប្រើប្រាស់ដោយសេរី និងដោយមិនមានការខ្វាំងខ្វប់ ។ ព្រះអង្គទ្រង់បានឲ្យដំបូន្មានដ៏ខ្ពង់ខ្ពស់ចំពោះសាវ័ករបស់ព្រះអង្គថា "ចូរអ្នកទាំងឡាយជាប្រទីប ( ឬជាកោះ ) របស់ខ្លួន ចូរអ្នកទាំងឡាយទីពឹងខ្លួនឯង ទីពឹងព្រះធម៌ ចូរកុំទីពឹងអ្នកដទៃឡើយ" ។ នេះគឺជាព្រះសីហនាទដ៏ខ្ទរខ្ទារ ដែលហៅរកវិចារណញ្ញាណនិយម ។ ក្នុងសម័យដើមបំផុត ពុទ្ធសាសនាពុំមែនជាលំអាននៃលទ្ធិ និងទស្សនៈវិជ្ជាទេ ៖ ព្រះអភិធម្មបិដក គឺជាធម៌លូតលាស់ឡើងក្នុងសម័យក្រោយ ។ តាមសេចក្ដីពិត ពុទ្ធសាសនាគឺជាឧបាយនៃជីវិត ជារបបមួយនៃវប្បធម៌ ជាមាគ៌ាមួយ ( សម្រាប់ ) ប្រតិបត្តិ ។ កាលដែលគេបាននាំពុទ្ធសាសនាអំពីប្រភពនានាចូលមកក្នុងប្រទេសផ្សេង ៗ នៃអាស៊ីទ្វីបនេះ អានុភាពនៃពុទ្ធសាសនាដែលគ្របដណ្ដប់លើប្រជាជាតិទាំងនេះ មិនមែនគ្រាន់តែជាលទ្ធិ ឬសាសនាប៉ុណ្ណោះទេ ពុទ្ធសាសនាបាននាំមកផ្ដល់ឲ្យប្រជាជាតិទាំងនេះជាដំបូងបំផុតនូវទស្សនថ្មីមួយចំពោះជីវលោក នូវរបបថ្មីមួយនៃការឲ្យតម្លៃមនុស្ស នូវចរិយាសាស្ត្រនិងរបៀបបែបផែននៃការពិចារណាឲ្យតម្លៃចំពោះចរិយាសាស្ត្រ សីលធម៌ថែមទៀត ដែលផ្ទុយគ្នានឹងរបប

លទ្ធិអត្តនិយម ឬបិសាចនិយម ដែលគេប្រកាន់ជឿក្នុងសម័យនោះ ។

ពុទ្ធសាសនាពុំបានប្រឆាំងជាដាច់ខាត នឹងជំនឿដើមទាំងនោះទេ ប៉ុន្តែ ដោយការទទួលប្រើវិចារណញ្ញាណនិងបញ្ញាញាណ ពុទ្ធសាសនាបាន ធ្វើលទ្ធិទាំងនោះឲ្យអស់មានសារៈសំខាន់អ្វីតទៅទៀត ។ ដោយឧបាយ បែបនេះ ពុទ្ធសាសនា បានដឹកនាំប្រជាជាតិទាំងនោះ ឲ្យដើរតាមមាគ៌ា មួយឆ្ពោះទៅកាន់ជីវភាពនឹងគំនិត ដែលប្រកបដោយអារ្យធម៌គ្រប់គ្រាន់ ដោយបានដាស់តឿនក្រើនរំលឹកប្រជាជាតិទាំងនោះ ឲ្យមានសមត្ថភាព ខាងវិចារណញ្ញាណ នឹងទម្លាប់ខាងការវិនិច្ឆ័យឲ្យតម្លៃខ្លួនឯង ។ ពុទ្ធសា-សនា មានគម្ពីរអក្សរសាស្ត្របរិបូណ៌ ហើយសេចក្តីត្រូវការ (នៃប្រជា ជាតិនានា) ដើម្បីរៀនគម្ពីរទាំងនេះ បានពង្រីកនូវអក្សរសិក្សាក្នុងចំណោម ប្រជាជាតិសម័យមុនអក្សរសាស្ត្រថែមទៀត ។ មិនតែប៉ុណ្ណោះ ពុទ្ធសាស-នា មានបាដិមាករណសាស្ត្រ មានពិធីគោរពបូជាព្រះពុទ្ធរូប ដែលជា ហេតុនាំឲ្យមានការអភិវឌ្ឍន៍ខាងចម្លាក់នឹងសិល្បៈផ្សេងៗទៀតជាច្រើន ។ ទីបំផុត ពុទ្ធសាសនា មាននិមិត្តរូបទាំងឡាយដែលជាទីគោរពបូជាថែម ទៀត គឺវត្តអារាម វិហារ ចេតិយ ដែលជាវត្ថុត្រូវការសេចក្តីស្ទាត់ជំនាញ ខាងផ្នែកស្ថាបនកម្មដើម្បីកសាងស្ថាបនា ។ ទាំងនេះ សឲ្យឃើញថា មូលដ្ឋាននៃអារ្យធម៌របស់ប្រជាជាតិទាំងនេះ បានកើតមានឡើងជាស្ពាន ដោយសារការនាំចូលមកនូវព្រះពុទ្ធសាសនា ។

ខ្ញុំមិនបាច់ពោលអំពីប្រវត្តិសាស្ត្រពុទ្ធសាសនានៅភូមិភាគផ្សេងៗទេ ទាំងមិនបាច់អធិប្បាយឲ្យវែងឆ្ងាយអំពីអតីតកាល ដែលពុទ្ធសាសនាបានមកបលនាសកម្មភាព ក្នុងប្រវត្តិសាស្ត្រនៃប្រជាជាតិនានាក្នុងអាស៊ីទ្វីបនេះឡើយ ។ ប៉ុន្តែ គឺជាការពិតណាស់ថា: កាលណាគេសរសេរសៀវភៅប្រវត្តិសាស្ត្រអាស៊ីទ្វីបសម័យបុរាណ កាលនោះ ភាគច្រើននៃវិជ្ជានិពន្ធក្នុងសៀវភៅនោះ នឹងត្រូវពោលអំពីការនាំចូល នឹងការផ្សាយពុទ្ធសាសនាលើផ្ទៃអាស៊ីផ្នែកអគ្នេយ៍ នឹងដំណើរការណ៍ខាងវប្ប-ធម៌ដែលចំរើនឡើងតាមលំអានពុទ្ធសាសនា ។ ការពិនិត្យស្រាវជ្រាវខាងប្រវត្តិសាស្ត្រ នឹងខាងស្ថាបនកម្មក្នុងប្រទេសនានា គឺជាការចាំបាច់ជាទីបំផុត ដើម្បីបំពេញហើយបញ្ចប់នូវវិជ្ជានិពន្ធប្រវត្តិសាស្ត្រនោះៗ ។

ប៉ុន្តែ កិច្ចដែលមានសារៈសំខាន់ជាងវត្ថុបាក់បែក ដែលគេគាស់កកាយឡើងក្ដី សំខាន់ជាងឯកសារដែលគេអាចរកឃើញនោះទៅទៀត គឺការៈកិច្ចដែលចង្អុលបង្ហាញឬបំភ្លឺឲ្យឃើញច្បាស់នូវពុទ្ធសាសនា ដែលឋិតនៅយ៉ាងកំប៉ាំងក្នុងជីវភាពប្រជាជាតិ នឹងវប្បធម៌នៃប្រទេសនីមួយៗ ។ ក្នុងប្រទេសទាំងឡាយនៃអាស៊ីភាគអគ្នេយ៍ គឺ ប្រទេសភូមា ថៃ នឹងកម្ពុជា ដែលត្រូវរាប់បញ្ចូលទាំងប្រទេសសិរីលង្កាផងនោះ ព្រះពុទ្ធ-សាសនា ជាសាសនារស់រវើក ដែលត្រូវទទួលស្គាល់ក្នុងរដ្ឋធម្មនុញ្ញ ហើយដែលរដ្ឋការពារគ្រប់គ្រងផង ។ ប៉ុន្តែ ប្រទេសដទៃទៀត ដែល

លែងប្រតិបត្តិតាមពុទ្ធសាសនា ហើយលែងទទួលពុទ្ធសាសនាជាជា សាសនាសម្រាប់រដ្ឋទៀត ហើយសូម្បីក្នុងអតីតកាលព្រះពុទ្ធសាសនាជា សាសនាសម្រាប់រដ្ឋរបស់ប្រទេសទាំងនោះក៏ដោយ ។ ប្រទេសឥណ្ឌៀ ដែលជាស្រុកកំណើតនៃពុទ្ធសាសនា គឺជាឧទាហរណ៍មួយច្បាស់លាស់ ជាងគេក្នុងរឿងនេះ ។ ប៉ុន្តែ បើអស់លោកយល់ថា ពុទ្ធសាសនាបាន រលត់អស់រលីងអំពីប្រទេសឥណ្ឌៀដូច្នេះ នោះនឹងជាកំហុសមួយចំពោះ ខ្លួនលោក ។ សិល្បៈនិងអារ្យធម៌ ទស្សនវិជ្ជានិងអាកប្បកិរិយាចំពោះ ជីវភាព ព្រមទាំងទិដ្ឋភាពដ៏ច្រើននៃវប្បធម៌នឹងច្បាប់ដើមសំរាប់ជាតិរបស់ ប្រទេសនេះ បានបង្ហាញឲ្យឃើញច្បាស់ថា ពុទ្ធសាសនាជាមហាពល មួយពុំទាន់រលត់រលាយចេញពីប្រទេសឥណ្ឌៀនៅឡើយទេ ។ ពុទ្ធសា-សនាបានរលត់ចេញពីរដ្ឋធម្មនុញ្ញមែន ប៉ុន្តែ នៅរស់រវើកក្នុងវប្បធម៌ សង្គមធម៌នៃប្រទេសឥណ្ឌៀដរាបដល់សព្វថ្ងៃនេះ ។ សភាពកំបាំងនៃ ពលភាពរបស់ពុទ្ធសាសនាក្នុងឥណ្ឌៀសព្វថ្ងៃ បានត្រូវបង្ហាញជាក់ស្ដ-តាងច្បាស់លាស់ដោយសេចក្ដីពិតថា ប្រជាជនឥណ្ឌៀសព្វថ្ងៃនៅតែមាន គំនិតចង់ស្វែងរកការណែនាំបណ្ដុះប្រាជ្ញា អំពីនិមិត្តរូបសាសនាច្រើនបែប យ៉ាង នឹងអំពីវត្ថុបាក់បែកពីបុរាណកាល ដែលឋិតនៅរាត់រាយពាសពេញ ប្រទេសទាំងមូល ហើយដែលបង្ហាញនូវរូបភាពនៃអតីតកាលដ៏រុងរឿង អស្ចារ្យ នៃព្រះពុទ្ធសាសនាក្នុងប្រទេសនេះអស់រយៈកាល ១៧ សតវត្ស

គឺតាំងពីសតវត្សទី ៩ មុនគ្រិស្តសករាជ ដល់សតវត្សទី ១២ ក្រោយគ្រិស្តសករាជ ។ សាសនាហិណ្ឌូដែលបានឈរជំនួសពុទ្ធសាសនាក្នុងប្រទេសឥណ្ឌា អស់ជាង ៨ សតវត្សទៅហើយនោះ បានរួមបញ្ចូលលាយឡំគ្នានូវភាគច្រើននៃពុទ្ធសាសនា និងពុទ្ធទស្សនវិជ្ជា ហិណ្ឌូសាសនាបានតាំងលើកដំកល់ព្រះពុទ្ធជាម្ចាស់ក្នុងកន្លែងមួយ នៃទេវគណៈរបស់ខ្លួន គឺរាប់ព្រះអង្គថាជា អវតារ(១) នៃព្រះវិស្ណុ ។ ហើយក្នុងគម្ពីរហិណ្ឌូបុរាណៈ យើងបានឃើញគេចាត់ទុកតិថីមួយ ក្នុងប្រក្រតីទិនថា ជាតិថីសក្តិសិទ្ធិសំរាប់គោរពបូជាព្រះពុទ្ធរូបផង ។ ព្រះពុទ្ធជាម្ចាស់ គឺជាទេវតាមួយក្នុងចំណោមទេវតាទាំងឡាយនៃហិណ្ឌូសាសនា បើទុកជាក្នុងប្រទេសឥណ្ឌាសព្វថ្ងៃ គេពុំប្រតិបត្តិឲ្យខ្ជាប់ខ្ជួនតាមព្រះពុទ្ធវចនៈនោះក៏ដោយ ។

កាលដែលប្រទេសអង់គ្លេសដកអំណាចខ្លួនចេញពីឥណ្ឌា ហើយប្រទេសឥណ្ឌាបានឯករាជ្យឡើងនោះ សកម្មភាពដំបូងបំផុតនៃការប្រកាសខ្លួនឯងរបស់ប្រទេសឥណ្ឌា គឺការអនុម័តយកកង់ចក្រដែលមហារាជាធិរាជពុទ្ធសាសនិកនៃអាស៊ីទ្វីបក្នុងសតវត្សទី ៣ មុនគ្រិស្តសករាជ ( គឺ

---

១_ នេះជាយោបល់នៃអ្នកប្រទេសឥណ្ឌា ដែលជឿកាន់សាសនាព្រាហ្មណ៍ តាមការណ៍ពិត ព្រះពុទ្ធមិនមែនជាអវតារពីព្រះវិស្ណុដូចលោកបណ្ឌិតជាតិថានោះទេ ព្រះអង្គគឺជាមនុស្សពិត ៗ ដែលបានបំពេញបារមីទាំង ៣០ អស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធសំរាប់ប្រោសសត្វលោក ។

ព្រះបាទអសោក) បានដំកល់ជានិមិត្តរូបនៃព្រះរាជាណាចក្ររបស់ព្រះអង្គនោះ មកធ្វើជាសញ្ញាទង់ជាតិរបស់ប្រទេសឥណ្ឌា ហើយយករូបសីហៈដែលគេឆ្លាក់ដាក់លើចុងសសរស្តម្ភព្រះបាទអសោកមកធ្វើជាសញ្ញាពិសេសរបស់ជាតិ ។ នេះគឺជាការផ្ទុះចេញជាផ្លែផ្កាក្នុងពន្លឺស្មើផាដំបូងបំផុតនៃឯករាជ្យក្នុងខណៈដែលប្រទេសឥណ្ឌាមានសមត្ថភាព ប្រកាសដោយខ្លួនឯងបានឡើងវិញ នូវធម្មជាតិដែលបិតនៅលាក់កំបាំងអស់កាលយូរក្នុងជីវភាពនិងវប្បធម៌របស់ខ្លួន ។ ដោយអាស្រ័យហេតុនេះ ប្រទេសឥណ្ឌាមានចិត្តគំនិតនឹងទំនៀមទម្លាប់មិនឆ្ងាយអំពីអស់លោក-អ្នក នឹងប្រជាជាតិដទៃឯទៀតក្នុងអាស៊ីភាគអគ្នេយ៍ ដែលបានរក្សាទុកនូវពន្លឺនៃពុទ្ធសាសនាឲ្យភ្លឺរុងរឿងដរាបមកដល់សព្វថ្ងៃនេះប៉ុណ្ណោះទេ ។

(ខ្ញុំសង្ឃឹមថា) ការទាក់ទងគ្នាខាងផ្នែកវប្បធម៌ និងការយោគយល់គ្នាខាងចិត្តគំនិត រវាងប្រទេសឥណ្ឌា និងប្រទេសពុទ្ធសាសនិកទាំងនេះ ប្រហែលជានឹងដឹកនាំយើងទៅកាន់អនាគតមួយ ប្រកបដោយលទ្ធផលល្អ ដែលយើងពុំអាចបង្ហាញរូបជាមុន ឬឃើញទុកជាមុនក្នុងសម័យសព្វថ្ងៃនេះ ។ ប៉ុន្តែ ទោះបីលទ្ធផលបែបណាក៏ដោយដែលនឹងមានមកនោះ លទ្ធផលនោះ ប្រាកដជានឹងពង្រីកនូវមតិខាងចិត្តគំនិតនៃសកលលោក ដោយឥតមានសង្ស័យឡើយ ។

ក្នុងរវាងពីរសតវត្សកន្លងទៅហើយ ដែលប្រទេសឥណ្ឌាបានស្ថិត

នៅក្រោមអំណាចគ្រប់គ្រងនៃប្រទេសអង់គ្លេសនោះ ការទាក់ទងគ្នាខាងផ្នែកវប្បធម៌ និងវិស័យដទៃទៀត រវាងប្រទេសឥណ្ឌា និងប្រទេសជ-ទៃក្នុងអាស៊ីទ្វីប បានទទួលនូវការសទឹងរាំងសទាតិចពេកណាស់ ៗ យើងបានដឹងដំណឹងដែលនិយាយអំពីប្រទេសផ្សេង ៗ ក្នុងអាស៊ីទ្វីប ដោយសារតែការសែត ដែលគេបញ្ជូនត្រឡប់មកវិញ (អំពីប្រទេសអង់គ្លេស) ហើយដំណឹងទាំងនោះ ក៏ច្រើនតែទាក់ទងនឹងហេតុការណ៍នយោបាយប៉ុណ្ណោះ ៗ យើង (ជាតិឥណ្ឌា) មិនត្រឹមតែល្ងង់ខ្លៅក្នុងរឿងសម្ពន្ធភាពច្រើនបែបច្រើនយ៉ាងខាងផ្នែកវប្បធម៌និងសាសនា ជាមួយប្រទេសទាំងឡាយដែលជិតនៅក្រៅព្រំប្រទល់ដែនយើងប៉ុណ្ណោះទេ ថែមទាំងត្រូវគេអប់រំហ្វឹកហាត់កាច់ពត់ឲ្យយើង ក្រឡេកទៅតែខាងលិចម្យ៉ាងប៉ុណ្ណោះដើម្បីស្វែងរកឧបោជនកម្ម និងមគ្គុទ្ទេសក៍ ៗ ព្រោះហេតុនោះ ព្រំដែននៃចិត្តគំនិតរបស់យើង បានត្រូវគេព័ទ្ធសីមាឲ្យជិតនៅតែក្នុងប្រទេសឥ-ណ្ឌា និងក្នុងវប្បធម៌ និងការសិក្សាបែបអឺរ៉ុបតែប៉ុណ្ណោះ ៗ អ្នកប្រាជ្ញជាតិអង់គ្លេសទាំងឡាយដែលបានផ្តល់ចំពោះយើង នូវប្រវត្តិសាស្ត្រប្រទេសយើង តែងតែបានចាប់ផ្តើមសរសេរឡើងដោយសេចក្តីពណ៌នាយ៉ាងវែងអំពីការញែកប្រទេសឥណ្ឌា ឲ្យនៅតែឯកឯងផុតស្រឡះអំពីប្រទេសឯទៀត ៗ ក្នុងអាស៊ីទ្វីប ដោយដាក់របាំងដោយជួរភ្នំហិមាល័យពីខាងជើង ហើយសមុទ្រនិងមហាសាគរ ពីខាងទិសដទៃនៃប្រទេសនេះ ៗ

យើងបានដឹងថា អង្គបុគ្គលទាំងនេះហើយដែលទទួលខុសត្រូវក្នុងការធ្វើឲ្យឯកភាពនៃការ្យធម៌របស់យើង និងវិសិដ្ឋភាពនៃការពង្រីកវប្បធម៌របស់យើង ឲ្យឃ្លាតចេញឆ្ងាយអំពីប្រទេសដទៃៗ ទៀតនៃអាស៊ីទ្វីប ។ យើងត្រូវតែលុងលោមបំពោរឲ្យជឿថា ប្រទេសឥណ្ឌាស្ថិតនៅដោយឡែកដាច់អំពីអាស៊ីទ្វីប ហើយជាប្រទេសអាស៊ីគ្រាន់តែក្នុងរូបកាយ និងភូមិសាស្ត្រប៉ុណ្ណោះ ។

ជាក់សន្តាល្អណាស់ ឥឡូវនេះ ជំនឿនិងយោបល់បែបនេះ បានត្រូវអន្តរធានចេញអស់ហើយហើយ ។ ការស្រាវជ្រាវរបស់អ្នកប្រាជ្ញនិងអ្នកប្រវត្តិសាស្ត្រទាំងឡាយ បានបញ្ជាក់ឲ្យយើងឃើញច្បាស់ថា: គឺមានតែក្នុងសម្ពន្ធភាពពីបុរាណកាលជាមួយប្រទេសដទៃ ។ ក្នុងអាស៊ីទ្វីបទេ ដែលប្រទេសឥណ្ឌាបានរកឃើញនូវឧត្តមភាពរបស់ខ្លួន ។ អ្នកប្រាជ្ញនិងអ្នកភូមិវិជ្ជាជាតិបារាំង បានគាស់ដីរកឃើញនូវអ្វីដែលគេបានឲ្យឈ្មោះថា "ឥណ្ឌាខាងក្រៅ" ក្នុងផែនទីអាស៊ីទ្វីប គឺភូមិភាគដែលអាទិភាពឥណ្ឌាបានធ្វើឲ្យរីងរុំងអស់រយៈកាលច្រើនសតវត្ស ហើយបានរកឃើញនូវសម្បូណ៌ភាពក្នុងការលូតលាស់ជាផ្លែផ្កាឡើង នៃស្នាដៃសិល្បៈនិងវប្បធម៌ របស់ជាតិទាំងនោះ វិហារធំ ។ និងព្រះរាជវាំងទាំងឡាយ ដូចខ្ញុំបានឃើញនៅរាជធានីចាស់របស់លោកអ្នកក្នុងខេត្តសៀមរាបនោះ គឺជាឯកទេគ្គកម្មយ៉ាងធំសម្បើម (ដែលបញ្ជាក់ឲ្យឃើញច្បាស់)

នូវការរួមចូលគ្នាយ៉ាងរីករាយនៃវប្បធម៌ឥណ្ឌានឹងទេពកោសល្យខ្មែរ គឺការរៀបចំរឿងព្រេង នឹងទេវកថាឥណ្ឌាក្នុងរបៀបនិទានថ្មីមួយដែលកើតឡើងអំពីមតិប្រាជ្ញារបស់ខ្មែរ ។ អ្នកប្រាជ្ញជាតិឥណ្ឌាក្នុងជំនាន់មុនដែលជាអ្នកស្រាវជ្រាវការសិក្សានូវអ្វីដែលបាក់ងបានឲ្យឈ្មោះថា " ឥណ្ឌាខាងក្រៅ " នោះ បានផ្សាយទ្រឹស្ដីមួយថា ប្រទេសទាំងឡាយដែលបានទទួលអារ្យធម៌នឹងវប្បធម៌ឥណ្ឌានោះ គឺជាប្រទេសអាណានិគមរបស់ឥណ្ឌាក្នុងសម័យបុរាណ ប៉ុន្តែ ឥឡូវនេះ គេពុំជឿទ្រឹស្ដីនោះទេ ព្រោះទ្រឹស្ដីនេះមិនស្របគ្នានឹងសេចក្ដីកត់ហេតុរបស់ចិនពីបុរាណកាល ដែលបង្ហាញនូវទិដ្ឋភាពផ្សេងនៃប្រទេសទាំងនេះ ថាពុំមែនជាប្រទេសអាណានិគមរបស់ឥណ្ឌាទេ ប៉ុន្តែ គឺជាទឹកដែនលំនៅដើមនៃប្រជាជាតិដែលក្នុងសម័យខាងដើមនៃការរៀបចំប្រវត្តិសាស្ត្ររបស់ខ្លួន បានបើកចំហឲ្យអានុភាពឥណ្ឌាចូលមកដល់ជាប់តាមត្រូវការ ។ ប្រទេសអាស៊ីអាគ្នេយ៍នឹងចុងបូព៌ាប្រទេសទាំងអស់បានបង្ហាញនូវឯកសារអក្សរសាស្ត្រ នឹងក្នុងបុរាណវត្ថុរបស់ខ្លួន នូវវិសាលភាពរបស់ខ្លួនដ៏ទូលំទូលាយនៃអានុភាពឥណ្ឌាបុរាណដែលបញ្ជាក់ឲ្យឃើញច្បាស់ឥតសង្ស័យថា ប្រទេសឥណ្ឌាមិនដែលបានស្ថិតជាប់តែឯកឯងអំពីប្រទេសឯទៀត ក្នុងអាស៊ីទ្វីបខាងផ្នែកវប្បធម៌ ដូចដែលអ្នកប្រវត្តិសាស្ត្រជាតិអង់គ្លេសបានពោលនោះទេ ។

ទោះបីយ៉ាងណាក៏ដោយចុះ ឱកាសនឹងការផ្លាស់ប្ដូរនៃប្រវត្តិសាស្ត្រ

គឺជាអាថិកំបាំងដែលពិបាកនឹងយល់ ៗ ក្នុងអាស៊ីទ្វីបបូព៌ា ព្រះពុទ្ធសាសនាជាអានុភាពសំរាប់រួបរួមមួយ ៗ ក្នុងកាលដែលពុទ្ធសាសនាផ្សាយចេញទៅបន្តិច ៗ ម្តងលើទ្វីបនេះ ប្រហែលជាមនុស្សជាតិផ្សេងដែលប្រើភាសាផ្សេង ៗ គ្នា មានចិត្តគំនិតនឹងការចាប់អារម្មណ៍ផ្សេង ៗ គ្នា មានការពិសោធខាងប្រវត្តិសាស្ត្រផ្សេងគ្នាច្រើន ដែលបែកចេញដាច់ពីគ្នាដោយហេតុភេទគ្រប់យ៉ាង ដែលជាគ្រឿងបែងចែកប្រជាជាតិមួយ អំពីប្រជាជាតិមួយទៀត- (ប្រជាជាតិទាំងនេះ) បានចូលរួមជាតិជាមួយគ្នាក្រោមការឧបត្ថម្ភនៃពុទ្ធសាសនា ពុទ្ធសាសនាបានផ្តល់ឲ្យប្រជាជាតិនីមួយ ៗ នូវគំរូគម្រោងដែលសមរម្យល្អទៅតាមទេពកោសល្យរបស់ខ្លួន ធ្វើប្រជាជាតិនោះ ៗ ឲ្យមានសណ្ឋានជាបែបផែន ដែលគ្រាន់ទុកដើម្បីបំ.ពេញនូវសេចក្តីត្រូវការផ្នែកខាងចិត្តគំនិត ហើយតាមសេចក្តីពិត គឺបានណែនាំប្រជាជាតិនោះ ឲ្យប្រកបដោយសម្បទាប្លែក ៗ គ្នាមួយបែប ដែលសព្វថ្ងៃនេះយើងតែងនិយាយថា "ពុទ្ធសាសនាឥណ្ឌា" "ពុទ្ធសាសនាលង្កាទ្វីប" ពុទ្ធសាសនាចិន" "ពុទ្ធសាសនាជប៉ុន" "ពុទ្ធសាសនាខ្មែរ" ជាដើម ៗ នៅពេលជាមួយគ្នានេះ យើងបានដឹងឮតាមប្រវត្តិសាស្ត្រពុទ្ធសាសនា អំពីចលនាសកម្មភាពនៃសមណៈទូតទាំងឡាយពីប្រទេសមួយទៅប្រទេសមួយទៀត- ដូចពីឥណ្ឌាទៅប្រទេសទីបេត៍ ពីប្រទេសលង្កាទ្វីបទៅប្រទេសភូមា ថៃ (កម្ពុជា) ពីប្រទេសចិនទៅប្រទេស

គួរជាដើម (សមណៈទូតទាំងនោះ) ខំប្រឹងប្រែងព្យាយាមដើម្បីដឹកនាំ ប្រទេសទាំងអស់នោះឲ្យចូលរួមក្នុងសម្ពន្ធសាសនាដូចគ្នា បើទុកជាមាន រនាំងរាំងខានផ្លូវកាយ សេចក្តីលំបាកខាងភាសានិងរបៀបគួរសមគ្នា តាមលទ្ធិផ្សេងៗ យ៉ាងណាក៏ដោយ ។ នៅលើភាគធំនៃអាស៊ីទ្វីប ព្រះពុទ្ធសាសនាបានប្រព្រឹត្តទៅជាមូលដ្ឋានសាធារណៈនៃផ្លូវចិត្ត និង បញ្ញា ដែលជាឧបាយនាំឲ្យមានសម្ពន្ធភាពខាងវប្បធម៌រវាងប្រជាជាតិទាំងឡាយ ដែលមានការយោគយល់គ្នា និងសមានចិត្តស្រដៀងគ្នាទៅវិញទៅមក ។

សព្វថ្ងៃនេះ ពុទ្ធសាសនាពុំមានមុខងារក្នុងអាស៊ីទ្វីប ដូចដែលបាន ពោលមកខាងលើនេះទេ ។ ការយល់ផលប្រយោជន៍ខាងនយោបាយ និងសេដ្ឋកិច្ច តែងតែបំបែកយើងចេញពីគ្នា ផលប្រយោជន៍ទាំងនេះ តែងធ្វើជាតិនិយមឲ្យលាយចូលគ្នា ជាមួយនឹងលក្ខណៈឈ្លានពានមួយបែប ហើយដាក់របាំងគ្រប់បែបគ្រប់យ៉ាង ដើម្បីរាំងផ្លូវនៃសមានចិត្ត និងការយោគយល់គ្នា ។ (ដូច្នេះ) សេចក្តីត្រូវការធំបំផុតរបស់យើង ក្នុងសម័យនេះ គឺការលើកស្ទួយចិត្តយើងឲ្យខ្ពស់ផុតផលប្រយោជន៍ទាំងនេះហើយនាំគ្នាស្វែងរកឧយ្យោជនកម្ម ដើម្បីសាមគ្គីរួបរួមគ្នានៅក្នុងមតិករួមគ្នាខាងផ្លូវចិត្ត ដោយសំគាល់នូវជនជាតិទាំងឡាយដែលទទួលមតិករួមគ្នានេះ ជាជាបងប្អូនបង្កើតខាងផ្លូវចិត្តរបស់យើង ។

សូមអរគុណ !